**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ

# សណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌសែនសុខ

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក.**លី បុត្រា**

លោកស្រី.**លី ដារ៉ា**

សាស្ត្រាចារ្យណែនាំ

លោក.**បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៧

ឆ្នាំចូលរៀន ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ**លី បុត្រា** និងនាងខ្ញុំឈ្មោះ**លី ដារ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៦-២០១៧។

កូនទាំងពីរសូមថ្លែងអំណរគុណចំពោះលោកឪពុកឈ្មោះ**ខូច បានលី** និងអ្នកម្តាយឈ្មោះ**ប៉ាន់ ផល្លា** ដែលលោកទាំងពីរជាអ្នកមានគុណចំពោះកូន។ កូនសូមសម្តែងក្តីកតញ្ញូជាអនេកប្បការចំពោះអ្នកមានគុណទាំងពីរដែលបានផ្តល់កំណើត និងខិតខំជម្រុញឲ្យកូនបានសិក្សាខ្ពង់ខ្ពស់។ កូនមិនភ្លេចនូវព្រះគុណដ៏ថ្លៃថ្លារបស់អ្នកមានគុណទាំងពីរនេះទេ កូនសូមចងចាំទុកក្នុងចិត្ត និងប្រឹងប្រែងរៀនសូត្រដោយយកក្តីនឹករលឹកដល់អ្នកមានគុណទាំងពីរ មកធ្វើជាហេតុដែលជម្រុញកូនទាំងពីរក្នុងការបង្កើតនូវស្នាដៃ ហើយកូនសូមផ្ញើស្នាដៃនេះជូនចំពោះលោកអ្នកមានគុណទាំងពីរជាទីសក្ការៈដ៏ខ្ពង់ខ្ពស់។

សូមគោរពឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រមទាំងសាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជួយតម្រង់ទិសអប់រំដល់ខ្ញុំទាំងពីររហូតបានទទួលជោគជ័យ និងឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

សូមថ្លែងអំណរគុណលោកអភិបាលខណ្ឌសែនសុខ និងអភិបាលរងខណ្ឌ ព្រមទាំងមន្ត្រីនៃសាលាខណ្ឌសែនសុខទាំងអស់ ដែលបានជួយផ្តល់នូវឯកសារមួយចំនួនពាក់ព័ន្ធនឹងប្រធានបទសារណារបស់ខ្ញុំទាំងពីរ។

ជាពិសេសលោកសាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សកក្កដា** ដែលបានដឹកនាំ ចង្អុលបង្ហាញនិងពន្យល់ពីវិធីសាស្ត្រល្អៗទាក់ទងនឹងប្រធានបទសារណា រួមទាំងការចំណាយពេលវេលាដ៏មានតម្លៃតាំងពីដើមរហូតដល់បញ្ចប់ការសិក្សាស្រាវជ្រាវនេះ។

សរុបមកវិញ ខ្ញុំទាំងពីរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងបួងសួងសូមឲ្យព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទេវតា វត្ថុស័ក្តសិទ្ធិនៅក្នុងលោកសូមជួយប្រទានពរជ័យ និងថែរក្សាដល់លោកអ្នកមានគុណទាំងអស់ សូមឲ្យមានសេចក្តីសុខ មានសុខភាពល្អ និងអាយុយឺនយូរតរៀងទៅ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល៣ឆ្នាំកន្លងទៅនេះឃើញថាទទួលបានការអប់រំ ទទួលបាននូវចំណេះដឹងជាច្រើន មានជំនាញច្បាស់លាស់ និងមានភាពភ្លឺស្វាងត្រចះត្រចង់ក្នុងវិស័យផ្នែកច្បាប់ពីសំណាក់សាស្ត្រាចារ្យដែលបានបណ្តុះបណ្តាល។ ស្ថិតក្នុងដំណាក់កាលនេះគឺជាឆ្នាំទី៤របស់ខ្ញុំទាំងពីរនៃថ្នាក់បរិញ្ញាបត្រ ដោយខ្ញុំទាំងពីរមានចិត្តសរសេរសៀវភៅដើម្បីសម្រួលដល់វិស័យផ្នែកច្បាប់ និងមានចិត្តចង់បង្កើតស្នាដៃទុកដើម្បីមនុស្សជាតិជំនាន់ក្រោយ ទើបខ្ញុំទាំងពីរបានជ្រើសរើសប្រធានបទមួយដែលទាក់ទងទៅនឹងនីតិនគរូបនីយកម្ម និងសំណង់។

ខ្ញុំទាំងពីរបានជ្រើសរើសប្រធានបទមួយឈ្មោះថា " ***ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌសែនសុខ*** " ហេតុផលដែលធ្វើឲ្យជ្រើសរើសប្រធានបទនេះ គឺដោយសារតែខ្ញុំទាំងពីរបានរស់នៅក្នុងខណ្ឌសែនសុខ និងមានចិត្តស្រលាញ់ខាងវិស័យនេះ។

គោលបំណងសំខាន់មួយទៀតនោះ គឺចង់ឲ្យសាធារណជន សិស្ស និស្សិតជំនាន់ក្រោយបានយល់ដឹងពីបញ្ហាសណ្តាប់ធ្នាប់ និងបរិស្ថាន ព្រមជាមួយនឹងវិធានការក្នុងការដោះស្រាយទៅលើប្រទេសជាតិរបស់ខ្លួន មិនថារាជធានី ក្រុង ស្រុក ខណ្ឌ ឃុំ ឬសង្កាត់ណាមួយនោះឡើយ។ ម្យ៉ាងវិញទៀតក៏ដើម្បីឲ្យគ្រប់គ្នាបានដឹងពីការអភិវឌ្ឍន៍នៅក្នុងខណ្ឌសែនសុខ និងជួយសម្រួលដល់ប្អូនៗជំនាន់ក្រោយក្នុងការសិក្សា ហើយអាចយកមកធ្វើជាឯកសារពិគ្រោះបាន។

ខ្ញុំទាំងពីរជឿជាក់ថាស្នាដៃនេះអាចនឹងមានកំហុសខ្លះ ឬនៅមានភាពខ្វះចន្លោះត្រង់កន្លែងណាមួយជាក់ជាពុំខាន ហើយខ្ញុំទាំងពីរសូមទទួលនូវការរិះគន់ក្នុងន័យស្ថាបនា និងកែលំអររាល់ចំណុចខ្វះខាតទាំងអស់ពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងនិស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវទាំងអស់ដើម្បីឲ្យស្នាដៃនេះក្លាយជាស្នាដៃមួយដែលល្អ។

ជាចុងក្រោយខ្ញុំទាំងពីរ សូមគោរពជូនពរដល់អស់លោកមិត្តអ្នកអាន អ្នកស្រាវជ្រាវទាំងអស់សូមឲ្យចាកផុតទុក្ខទាំងឡាយ ហើយជួបតែសេចក្តីសុខ សេចក្តីចម្រើន ជាអនេកប្បការនៅក្នុងក្រុមគ្រួសារ និងជោគជ័យក្នុងជីវិតរបស់ខ្លួន។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១.ការរៀបសណ្តាប់ធ្នាប់ក្នុងខណ្ឌសែនសុខ** ............ ៤

**១.១.ទិដ្ឋភាពទូទៅ** ............ ៥

**១.១.១.មូលហេតុដែលនាំឲ្យមានការរៀបចំ** ............ ៩

១.១.១.១.កំណើនប្រជាជន ............ ៩

១.១.១.២.ភាពក្រីក្រ ............ ១២

១.១.១.៣.កម្រិតជីវភាពនៃការរស់នៅ ............ ១២

១.១.១.៤.ការដាក់សម្ពាធបរិស្ថាន ............ ១៣

១.១.១.៥.គមនាគមន៍ ............ ១៤

១.១.១.៦.សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ............ ១៥

**១.១.២.រចនាសម្ព័ន្ធខណ្ឌសែនសុខ** ............ ១៦

**១.២.បច្ចុប្បន្នភាព និងទិសដៅអនាគតនៃការរៀបចំខណ្ឌសែនសុខ** ............ ២០

**១.២.១.បច្ចុប្បន្នភាពនៃការរៀបចំ** ............ ២១

១.២.១.១.ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ............ ២១

ក.ការកសាងផ្លូវ ............ ២១

ខ.ប្រព័ន្ធលូបង្ហូរទឹកក្នុងខណ្ឌសែនសុខ ............ ២៣

គ.ការដាក់បង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈ ............ ២៤

ឃ.ស្ពាន ............ ២៥

១.២.១.២.ការអភិវឌ្ឍន៍សំណង់លំនៅដ្ឋាន ............ ២៥

ក.ការងារសំណង់ខណ្ឌសែនសុខ និងដីធ្លី ............ ២៧

ខ.ការអភិវឌ្ឍន៍បុរីក្នុងខណ្ឌសែនសុខ ............ ២៨

១.២.១.៣.ការងាររៀបចំសណ្តាប់ធ្នាប់ និងការងារសាធារណការ . ២៨

ក. ការងាររៀបចំសណ្តាប់ធ្នាប់ ............ ២៨

ខ.ការងារសាធារណការ ..................................................៣០
**១.២.២.ទិសដៅអភិវឌ្ឍន៍ទៅថ្ងៃអនាគត**...............................................៣២
១.២.២.១.គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទៅថ្ងៃអនាគត......៣៣
ក.ការអភិវឌ្ឍន៍លើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងការដឹកជញ្ជូន.៣៣
ខ.ការអភិវឌ្ឍន៍លើវិស័យអគ្គីសនី .....................................៣៣
គ.ការអភិវឌ្ឍន៍លើវិស័យទឹកស្អាត និងអនាម័យ.....................៣៤
ឃ.ការអភិវឌ្ឍន៍លើវិស័យដីធ្លី...........................................៣៤
ង.ការអភិវឌ្ឍន៍លើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
..................................................................................៣៤
**ជំពូកទី២.បរិស្ថានក្នុងខណ្ឌសែនសុខ**...................................................៣៦
**២.១.លក្ខណៈទូទៅទាក់ទងនឹងហេតុបង្កនាំឲ្យមានការបំពុលបរិស្ថាន**............៣៦
**២.១.១.ការបំពុល ទឹក ដី ខ្យល់**.....................................................៣៧
២.១.១.១.ការបំពុលទឹក.........................................................៣៧
ក.មូលហេតុបង្កនៃការបំពុលទឹក........................................៣៧
ខ.ផលប៉ះពាល់នៃការបំពុលទឹក.........................................៣៨
គ.ការបំពុលទឹកក្នុងប្រទេសកម្ពុជា......................................៣៩
២.១.១.២.ការបំពុលដី ...........................................................៤១
២.១.១.៣.ការបំពុលខ្យល់ .......................................................៤៣
ក.មូលហេតុនៃការបំពុលខ្យល់...........................................៤៣
ខ.ផលប៉ះពាល់នៃការបំពុលខ្យល់......................................... ៤៤
គ.ការបំពុលខ្យល់នៅក្នុងលំនៅដ្ឋាន .................................... ៤៥
**២.១.២.ការបំពុលសំណល់រឹងរាវ និងសម្លេង** ........................................ ៤៦
២.១.២.១.ការបំពុលសំណល់រឹងរាវ ........................................... ៤៦
ក.សំណល់រឹង និងសំណល់រាវ........................................... ៤៦
ខ.ផលប៉ះពាល់ ............................................................... ៤៨
២.១.២.២.ការបំពុលសម្លេង ..................................................... ៤៨

ក.មូលហេតុបង្ក ........................................................ ៤៨
ខ.ផលប៉ះពាល់នៃការបំពុលដោយសម្លេង................................ ៤៩
**២.២.បរិស្ថានក្នុងខណ្ឌសែនសុខ** ........................................ ៥០
**២.២.១.បណ្ដាញខៀវ និងបណ្ដាញបៃតង**.................................... ៥០
២.២.១.១.បណ្ដាញខៀវ.................................................. ៥១
២.២.១.២.បណ្ដាញបៃតង ................................................ ៥១
**២.២.២.វិធានការការពារទាក់ទងនឹងបរិស្ថាន**................................ ៥២
**២.២.៣.បញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍បរិស្ថាន** ................................ ៥៣
**២.៣.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលបរិស្ថាន**................................ ៥៤
**២.៣.១.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលទឹក ដី ខ្យល់** ........................ ៥៤
២.៣.១.១.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលទឹក .................. ៥៤
២.៣.១.២.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលដី...................... ៥៥
២.៣.១.៣.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលខ្យល់................ ៥៥
**២.៣.២.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលសំណល់រឹងរាវ និងសម្លេង**... ៥៧
២.៣.២.១.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលសំណល់រឹងរាវ... ៥៨
ក.សំណល់រឹង........................................................ ៥៨
ខ.សំណល់រាវ ........................................................ ៦០
២.៣.២.២.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលសម្លេង ............ ៦១
**សេចក្ដីសន្និដ្ឋាន** ........................................................................ ៦៧
**អនុសាសន៍** ........................................................................ ៦៩
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅលើសាកលលោកនេះ គ្រប់បណ្តាប្រទេសទាំងអស់តែងតែមានការអភិវឌ្ឍន៍ និងរៀបចំក្នុងប្រទេសរបស់ខ្លួន ដើម្បីឲ្យមានសណ្តាប់ធ្នាប់ និងបរិស្ថានល្អ។ ដោយឡែកប្រទេសកម្ពុជាក៏មានការអភិវឌ្ឍន៍ទៅលើរាជធានី ក្រុង ស្រុក ខណ្ឌរបស់ខ្លួនដែរ ថែមទាំងត្រូវថែរក្សាការពារបរិស្ថាន និងគុណភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភោគោត្តសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម ខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផលផងដែរ។[១]

ជាទូទៅទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គឺត្រូវបានធ្វើការបែងចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។[២] ម្យ៉ាងវិញទៀតស្ទើរតែគ្រប់សម័យកាលទៅហើយ ដែលមានការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បណ្តាញប្រព័ន្ធធារាសាស្ត្រ គមនាគមន៍ និងបរិស្ថាន ដើម្បីឲ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មានសណ្តាប់ធ្នាប់ និងបរិស្ថានល្អផងដែរនោះ ដូចនេះក៏ជ្រើសរើសនូវប្រធានបទមួយគឺ "***ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌសែនសុខ***" ដោយខណ្ឌនេះចែកជា៩សង្កាត់។

យោងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងគណៈអភិបាលខណ្ឌសែនសុខឃើញថានៅក្នុងខណ្ឌនេះមានការលិចលង់ផ្លូវ និងការកកស្ទះប្រព័ន្ធលូជាច្រើន ព្រមជាមួយនឹងកាកសំណល់ (សម្រាម) ការកកស្ទះផ្លូវគឺធ្វើឲ្យមានការខូចខាតផ្លូវ រួមទាំងការបំពុលបរិស្ថានជាដើម។ ការនេះទើបជាហេតុធ្វើឲ្យមានការអភិវឌ្ឍន៍ទៅលើខណ្ឌសែនសុខ។

## ២.ចំណោតបញ្ហានៃការស្រាវជ្រាវ

នៅក្នុងខណ្ឌសែនសុខ គឺមានទាំងអភិបាលខណ្ឌ និងអភិបាលរងខណ្ឌ ព្រមជាមួយលោកលោកស្រីដែលជាមន្ត្រី ជាអ្នកមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍ នឹងការរៀបចំក្នុងខណ្ឌនេះអោយបានល្អ។

[១] មាត្រា៥៩ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣។

[២] មាត្រា១៤៥ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣។

ទោះជាយ៉ាងនេះក្តីដើម្បីឲ្យសិស្សនិស្សិត មិត្តអ្នកអាន ឬអ្នកស្រាវជ្រាវ និងសាធារណជនទាំងអស់បានយល់ដឹងច្បាស់ពីខណ្ឌសែនសុខនេះ គឺបានចោទជាសំនួរថា "**តើគួរធ្វើយ៉ាងដូចម្តេចដើម្បីឲ្យខណ្ឌសែនសុខនេះមានសណ្តាប់ធ្នាប់ និងបរិស្ថានល្អ**"? និង "**តើខណ្ឌនេះមានការអភិវឌ្ឍន៍អ្វីខ្លះនៅពេលបច្ចុប្បន្ននេះ**"?

ដូចនេះនិស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ និងសាធារណជនទាំងអស់ប្រាកដជាយល់ដឹងពីការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌសែនសុខ ថែមទាំងអាចយកស្នាដៃស្រាវជ្រាវមួយនេះទៅធ្វើជាឯកសារពិគ្រោះ និងជំនួយដល់ស្មារតីបានទៀតផង។

**៣.គោលបំណងនៃការស្រាវជ្រាវ**

រាល់ការសិក្សាស្រាវជ្រាវទាំងអស់ គឺសុទ្ធសឹងតែមានគោលបំណងនៅក្នុងការស្រាវជ្រាវ។ ដោយឡែកក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះគឺចង់ឲ្យនិស្សិត សាធារណជនបានយល់ដឹងពីការអភិវឌ្ឍន៍ ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានជុំវិញខ្លួន។ អ្វីដែលពិសេសជាងនេះទៅទៀតនោះ គឺចង់ឲ្យនិស្សិតជំនាន់ក្រោយៗបានយល់ដឹង ហើយវាអាចជាស្មារតីជួយបន្ថែមលើការស្រាវជ្រាវដល់ប្អូនៗ។

**៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**

ការស្រាវជ្រាវទាំងឡាយ គឺតែងតែមានដែនកំណត់របស់ខ្លួន។ អ្វីដែលទាក់ទងនឹងប្រធានបទ "***ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌសែនសុខ***" គឺនឹងបកស្រាយទៅលើអ្វីដែលទាក់ទងនឹងសណ្តាប់ធ្នាប់ បរិស្ថានតែប៉ុណ្ណោះ។

**៥.សារៈសំខាន់នៃការស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវទៅលើអត្ថបទនេះ គឺមានសារៈសំខាន់ដល់និស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ សាធារណជនទាំងអស់ អាចជួយសម្រួលដល់ការអភិវឌ្ឍន៍ ឬការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌសែនសុខទៀតផង។ ជាពិសេសមិត្តអ្នកអាន សាធារណជនទាំងអស់អាចធ្វើការផ្សព្វផ្សាយពីការអភិវឌ្ឍន៍ខណ្ឌសែនសុខយកទៅអភិវឌ្ឍន៍ខណ្ឌដទៃ ឬក្នុងស្រុកណាមួយបានថែមទៀត។

**៦.វិធីសាស្ត្រស្រាវជ្រាវ**

ការស្រាវជ្រាវលើប្រធានបទ "***ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌសែនសុខ***" គឺបកស្រាយ និងបំភ្លឺទៅលើបទដ្ឋានគតិយុត្តមួយចំនួនព្រមជាមួយនឹងបទសំភាសន៍ ឯកសារដែលទទួល

បានពីសាលាខណ្ឌសែនសុខ ដោយលោកអភិបាលខណ្ឌបានអនុញ្ញាត្តនិងផ្តល់ឲ្យ ហើយនិងឯកសារមួយចំនួនទៀតបានពីគេហទំព័រផ្សេងៗ។

**៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

ស្ថិតក្នុងប្រធានបទនេះដែរ គឺបានធ្វើការចែកចេញជា២ជំពូក ក្នុងនោះមានៈ

**១.ជំពូកទី១** ការរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌសែនសុខ ហើយជំពូកទី១នេះបានចែកចេញជាពីរផ្នែក ដោយផ្នែកទី១បកស្រាយពីទិដ្ឋភាពទូទៅ រីឯផ្នែកទី២វិញ បកស្រាយអំពីបច្ចុប្បន្នភាពនិងទិសដៅអនាគតនៃការរៀបចំខណ្ឌសែនសុខ។

**២.ជំពូកទី២** បរិស្ថានក្នុងខណ្ឌសែនសុខ ដែលក្នុងជំពូកទី២នេះគឺចែកចេញជាបីផ្នែក ដោយផ្នែកទី១ បកស្រាយទៅលើលក្ខណៈទូទៅទាក់ទងនឹងហេតុបង្កឲ្យមានការបំពុលបរិស្ថាន ផ្នែកទី២ បកស្រាយទៅលើបរិស្ថានក្នុងខណ្ឌសែនសុខ ហើយផ្នែកទី៣ គឺបកស្រាយទៅលើដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលបរិស្ថាន។

# ជំពូកទី១
# ការរៀបចំសណ្ដាប់ធ្នាប់
# ក្នុងខណ្ឌសែនសុខ

# ជំពូកទី១
# ការរៀបចំសណ្តាប់ធ្នាប់ក្នុងខណ្ឌសែនសុខ

បើយោងតាមការវិភាគអំពីស្ថានភាព ក៏ដូចជាបញ្ហាសណ្តាប់ធ្នាប់នៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះឃើញថា ការរៀបចំសណ្តាប់ធ្នាប់នៅតាមទីសាធារណៈក្នុងខណ្ឌសែនសុខត្រូវបានសាលាខណ្ឌសែនសុខយកចិត្តទុកដាក់ជាខ្លាំង ដោយរក្សាបាននូវសុវត្ថិភាពល្អជូនប្រជាពលរដ្ឋ និងមានសណ្តាប់ធ្នាប់ក្នុងខណ្ឌនេះផងដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយបញ្ហាសណ្តាប់ធ្នាប់នៅក្នុងខណ្ឌនេះនៅតែចោទជាបញ្ហា ព្រោះតែនៅមានបងប្អូនប្រជាពលរដ្ឋមួយចំនួនតូចដែលពួកគាត់មិនបានយល់ដឹងច្បាស់ពីច្បាប់ ឬបានយល់ដឹងពីច្បាប់តែមិនគោរពច្បាប់ដែលធ្វើឲ្យបញ្ហាសណ្តាប់ធ្នាប់នៅតែកើតមាន ទាំងនេះហើយដែលអាជ្ញាធរគ្រប់ជាន់ថ្នាក់គួរតែប្បីរួមគ្នាដោះស្រាយឲ្យទាន់សភាព-ការណ៍ដែលបានកើតឡើង ដើម្បីឲ្យមានសណ្តាប់ធ្នាប់ប្រកបដោយសោភ័ណ្ឌភាព។

ម្យ៉ាងវិញទៀតមុននឹងឈានដល់ការរៀបចំ ឬការអភិវឌ្ឍន៍ត្រូវពិនិត្យមើលទៅលើប្លង់គោលជាមុនសិនក្នុងការរៀបចំសណ្តាប់ធ្នាប់ឲ្យមានរបៀបរៀបរយ និងមានសោភ័ណ្ឌភាព។

ប្លង់គោលជាឯកសារ ឬគម្រោងដែលមានលក្ខណៈជាយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍រាជធានីដល់ឆ្នាំ២០២០។ ប្លង់គោលជាប្លង់គ្រឹះ និងជាអ្នកតំរង់ទិសក្នុងការរៀបចំបែងចែក កំណត់ផ្ទៃដីសំរាប់តំបន់សំណង់ តំបន់ចាក់សម្រាម តំបន់សាលារៀន តំបន់ដែលត្រូវការពារ តំបន់ដែលត្រូវអភិវឌ្ឍ។[៣]

ដូចមានក្នុងច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រង់មាត្រា៧បានចែងថាដីអាចសាងសង់បាន ឬសាងសង់មិនបានមានដូចតទៅ៖

-ដីសំរាប់សួនច្បារ និងឧទ្យាន
-តំបន់ដែលមានដង់ស៊ីតេខ្ពស់ ឬទាប
-តំបន់ទេសចរណ៍
-តំបន់ឧស្សាហកម្ម
-តំបន់ពាណិជ្ជកម្ម
-តំបន់កសិកម្ម
-តំបន់សម្រាប់អភិវឌ្ឍន៍
-តំបន់ប្រវត្តិសាស្ត្រ វប្បធម៌ សាសនា

[៣] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ទំព័រ១៩១។

-តំបន់ការពារជាតិ

-តំបន់សំណង់រដ្ឋបាល និងបរិក្ខាសាធារណៈ (ក្រសួង មន្ទីរ សាលារៀន មន្ទីរពេទ្យ...)

-កន្លែងចាក់សម្រាម អាងស្តុកទឹកស្អុយ។[៤]

អត្ថប្រយោជន៍នៃការរៀបចំប្លង់គោលបានផ្តល់ដល់ការអភិវឌ្ឍន៍ដូចជា៖[៥]

១.ធ្វើឲ្យការសាងសង់មានបទដ្ឋានតាមការកំណត់របស់ប្លង់គោល។

២.រាល់ឧទ្យានសួនច្បារ រមណីយដ្ឋាន មហោស្រប ទីធ្លាកំសាន្តត្រូវបានសាងសង់ដោយមានសណ្តាប់ធ្នាប់។

៣.ទីក្រុងមានសោភ័ណ្ឌភាពស្រស់បំព្រង គ្មានសំណង់អាណាធិបតេយ្យ មានអនាម័យគ្មានភក់ជ្រាំចម្លងមេរោគ។

៤.គ្មានភាពច្របូកច្របល់ សួនច្បារក្លាយជាស្ថានីយបូមប្រេង ឆ្នេរទន្លេដែលជាទីលានយកខ្យល់អាកាសសម្រាប់បម្រើឲ្យអ្នកទេសចរណ៍ប្រែក្លាយជាផ្ទះស្លឹក ផ្ទះឈើ ភូមិជរាអាណាធិបតេយ្យក្នុងក្រុង។

៥.ប្លង់គោល ជាប្លង់បង្ហាញអំពីសោភ័ណ្ឌភាពតំបន់សណ្តាប់ធ្នាប់មានបណ្តាញផ្គត់ផ្គង់ទឹកបណ្តាញលូបង្ហូរទឹកភ្លៀងនិងទឹកស្អុយ និងបណ្តាញអគ្គីសនី មានទីកំសាន្ត មានសាលារៀន មានដីសម្រាប់កីឡាដ្ឋាន ដីសម្រាប់រដ្ឋបាល ទីធ្លារសម្រាប់ផ្សារ គ្រឹះស្ថានពាណិជ្ជកម្មនិងវប្បធម៌។ ប្លង់គោលមានបំណងធ្វើឲ្យការអភិវឌ្ឍន៍រីកចំរើនលុបបំបាត់សំណង់អាណាធិបតេយ្យ ព្រោះសំណង់លំនៅដ្ឋានគេបានកំណត់ក្នុងប្លង់គោលហើយតំបន់ទឹកស្អាតក៏គ្មានឧបសគ្គដែរ ពីព្រោះគេបានហាមឃាត់រួចទៅហើយ។

## ១.១.ទិដ្ឋភាពទូទៅ

ទីតាំងភូមិសាស្ត្រនៅសម័យមហានគរ មានឥទ្ធិពលធំធេងណាស់ដល់ការលូតលាស់ របាយ-ធនធានធម្មជាតិ ប្រជាជន សេដ្ឋកិច្ច វប្បធម៌...ដែលទឹកដីនេះបានផ្សាភ្ជាប់យ៉ាងជិតស្និទ្ធិជាមួយភូមិភាគអាស៊ីអាគ្នេយ៍ទាំងដីគោក និងដីកោះលើលក្ខខណ្ឌធម្មជាតិ និងប្រវត្តិសាស្ត្រ។ នៅដើមសតវត្សរ៍ទី១នៃគ្រិស្តសករាជ តំបន់នេះជាដែនដីសុវណ្ណភូមិមានមនុស្សខ្មែរតាំងទីរស់នៅពីយូរលង់ណាស់មកហើយ ដោយបង្កើតបានជាសង្គមមានរបៀបរៀបចំច្បាប់រដ្ឋច្បាស់លាស់ ដឹកនាំដោយស្ត្រី

[៤] មាត្រា៧ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់លេខ០៤/នស/៩៤ ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤។

[៥] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រ១៩២។

សោយរាជ្យឈ្មោះព្រះនាងសោមា តាមភាសារចិនហៅថាព្រះនាងលីវយី នៅនគរគោកធ្លោកដែលមានអង្គបុរីជារាជធានីនៃអាណាចក្រភ្នំ ឬនគរភ្នំ(សព្វថ្ងៃជាខេត្តតាកែវ)។ ព្រះនាងបានរៀបអភិសេកជាមួយព្រាហ្មណ៍ដែលបានមកពីឥណ្ឌាឈ្មោះព្រះបាទកៅណ្ឌិន្យ តាមភាសារចិនហៅថាព្រះបាទហ៊ុនទៀន។ អាណាចក្រភ្នំមានអាយុកាលចាប់ពីសតវត្សរ៍ទី១ដល់សតវត្សរ៍ទី៦ ភាសារចិនហៅថាហ្វូណន។[៦] ម៉្យាងវិញទៀត នៅសម័យអាណាចក្រភ្នំមានឈ្មោះថ្កុំថ្កើងរុងរឿងក៏ដោយសារតែយល់នូវសារៈសំខាន់នៃសេដ្ឋកិច្ច។ កសិកម្មមានការរីកចម្រើនលូតលាស់ខ្លាំង ហើយអ្នកស្រុកចេះជីកព្រែកខ្វាត់ខ្វែងដែលមានសល់ដានរហូតដល់សព្វថ្ងៃនេះនៅត្រង់កម្ពុជាក្រោមខាងលិច។ តាមយោបល់អ្នកជំនាញការ បណ្តាញព្រែកជីកនេះគេបានកសាងឡើងសម្រាប់បង្ហូរទឹកជំនន់ទន្លេមេគង្គចេញផង សម្រាប់លាងសម្អាតឲ្យស្អាតនូវទឹកភក់ល្បាប់ និងបន្សាបអំបិលដែលជ្រាបទៅក្នុងដីផង សម្រាប់ជាគមនាគមន៍រវាងទីក្រុងទាំងឡាយ និងសម្រាប់ឲ្យសំពៅនិងទូកឆ្លងកាត់ទៅបានពីសមុទ្រចិនទៅឈូងសមុទ្រសៀម។[៧] បន្ទាប់ពីសម័យនគរភ្នំ នៅចន្លោះពីសតវត្សរ៍ទី៦ដល់សតវត្សរ៍ទី៨ ខ្មែរភាគខាងជើងបានបង្កើតរដ្ឋមួយឈ្មោះថាអាណាចក្រចេនឡា ខ្មែរធ្លាប់មានជោគជ័យក្នុងនយោបាយទឹកតាំងពីសម័យអាណាចក្រភ្នំមកម្ល៉េះ ចូលមកដល់សម័យចេនឡា នយោបាយទឹកមានសភាពរឹតតែប្រសើរឡើងថែមទៀត ជាហេតុញ៉ាំងឲ្យមានការកសាងទីក្រុងធំៗនៅក្បែរមាត់ស្ទឹង និងមានកសិកម្មរីកចម្រើនលូតលាស់ជាលំដាប់។[៨]

បន្តមកដល់សម័យអង្គរចាប់ផ្តើមពីគ្រិស្តសករាជ៨០២ គឺជាឆ្នាំដែលព្រះបាទជ័យវរ្ម័នទី២ ធ្វើពិធីទេវរាជនៅលើភ្នំគូលែន ហើយចប់នៅគ្រិស្តសករាជ១៤៣១ ជាឆ្នាំដែលព្រះបាទពញាយ៉ាតបានចាកចោលក្រុងអង្គរបានសេចក្តីថា រយៈពេល៦២៩ឆ្នាំគឺជាសម័យកាលមួយដែលប្រទេសខ្មែរបានស្គាល់នូវភាពរុងរឿងក្នុងប្រវត្តិសាស្ត្រមនុស្សលោក។ ព្រះបាទយសោវរ្ម័នទី១ គឺជាស្ថាបនិកដំបូងគេក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលបានកសាងទីក្រុងថ្មី គឺទីក្រុងអង្គរ។ បុព្វបុរសខ្មែរជាមនុស្សមានគំនិតច្នៃប្រឌិតដោយបានរៀបចំបុរី និងបានធ្វើនយោបាយកសិកម្មផ្អែកទៅលើរបៀបចាត់ចែងប្រព័ន្ធទឹកជាមូលដ្ឋាន។ ការរៀបចំប្រទេសដែលបានធ្វើឡើងនៅរាជ្យព្រះបាទឥន្ទ្រវរ្ម័ន អាស្រ័យដោយស្ថានភាពនិងអំណាចរបស់ប្រទេសមានស្ថិរភាព មានកម្លាំងគ្រប់គ្រាន់រួមនឹងជំនឿសាសនាដែលមានលក្ខណៈ

---

[៦] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា ដោយបណ្ឌិត អ៊ូ វ័ឌី ឆ្នាំ២០១២ ត្រង់ទំព័រ៥ និង៦។

[៧] សៀវភៅប្រវត្តិសាស្ត្រខ្មែរភាគទី១ បោះពុម្ពលើកទី១ គ.ស១៩៧៣ ព.ស២៥១៧ ដោយសាស្ត្រាចារ្យត្រឹងងារ ត្រង់ទំព័រ៦២ និង៦៣។

[៨] សៀវភៅប្រវត្តិសាស្ត្រខ្មែរភាគទី១ បោះពុម្ពលើកទី១ គ.ស១៩៧៣ ព.ស២៥១៧ ដោយសាស្ត្រាចារ្យត្រឹងងារ ត្រង់ទំព័រ៧៨។

មុតមាំ។ នយោបាយទឹកនៅជំនាន់ព្រះឥន្ទ្រវរ្ម័ន គឺមានលក្ខណៈផុសផុលខ្លាំងក្លា មានព្រែកជីកខ្វាត់ខ្វែងជាប្រព័ន្ធមួយស្មុគស្មាញ និងមានបារាយណ៍ ព្រមទាំងគូទឹកផ្សេងៗជាគោល។ ហេតុផលទាំងនេះគឺបានធ្វើឲ្យសេដ្ឋកិច្ចប្រទេសមានការរីកចម្រើនឡើង សង្គមមានស្ថិរភាព អំណាចរឹងមាំ និងបានធ្វើឲ្យអាណាចក្រខ្មែរថ្កុំថ្កើងរុងរឿង ដោយសារតែការរៀបចំនគរនៅពេលនោះមានលក្ខណៈពិសេស ដែលប្រទេសនេះបានផ្តោតការយកចិត្តទុកដាក់លើនយោបាយទឹក។ ក្សត្រគ្រងរាជ្យនៅសម័យអង្គរក្នុងរជ្ជកាលនៃអង្គព្រះមហាក្សត្រនីមួយៗ ក៏ដូចប្រជារាស្ត្រទូទាំងប្រទេសដែរ គឺមានបំណងចង់ធ្វើឲ្យទីក្រុងកាន់តែមានសោភ័ណ្ឌភាពលើសដើមជានិច្ច។ តាមរយៈសំណង់ស្ថាបត្យកម្មដែលបានបន្សល់ទុក និងស្លាកស្នាមដែលនៅសេសសល់ដល់សព្វថ្ងៃ។[៩]

ម៉្យាងវិញទៀតលក្ខណៈពិសេសនៃសង្គមខ្មែរគឺការកសាងប្រព័ន្ធបង្ហូរទឹក ដើម្បីស្រោចស្រពស្រែចម្ការតាមរយៈបារាយណ៍ធំៗ ដែលអាចផ្ទុកទឹកបានចំនួនច្រើនអតិបរមា។ ដូច្នេះការរីកចម្រើនខាងវិស័យបច្ចេកទេសដែលគេឲ្យឈ្មោះថានយោបាយទឹក បាននាំមកនូវផលិតកម្មយ៉ាងល្អប្រសើរ ជាហេតុនាំឲ្យមានការរីកដុះដាលនៃប្រជាជនខ្មែរក្នុងចក្រភពមហានគរ ហើយទន្ទឹមនឹងនេះប្រាង្គ-ប្រាសាទជាច្រើន ក៏ត្រូវបានកសាងឡើងជាលំដាប់លំដោយផងដែរ។[១០]

ជាបន្តបន្ទាប់មកដល់សតវត្សរ៍ទី១៥ ក្នុងអំឡុងរជ្ជកាលព្រះបាទស្រីសុរិយោព័រ(ពញាយ៉ាត) គឺនៅពេលដែលព្រះអង្គបានបោះបង់ចោលរាជធានីអង្គរ ហើយមកសាងសង់រាជធានីថ្មីមួយទៀតនៅទួលបាសានក្នុងខេត្តស្រីសឈរ ដែលសព្វថ្ងៃត្រូវបានគេស្គាល់ថាជាស្រុកស្រីសន្ធរខេត្តកំពង់ចាម។ ព្រះអង្គបានគង់នៅទីនោះបានតែមួយឆ្នាំគត់ដោយសារតែមានទឹកជំនន់រាល់រដូវវស្សា ព្រះអង្គបានផ្លាស់ប្តូររាជធានី ហើយបានមកសាងសង់រាជធានីថ្មីមួយទៀតតាមបណ្តោយមាត់ទន្លេចតុមុខ(ទន្លេមុខបួន) នៅក្នុងឆ្នាំ១៤៣៤ ដែលសព្វថ្ងៃជារាជធានីភ្នំពេញ។ ការកសាងព្រះបរមរាជវាំងនៅរាជធានីភ្នំពេញមាន២លើក ទី១ក្នុងរជ្ជកាលព្រះបាទពញាយ៉ាតក្នុងសតវត្សរ៍ទី១៥ និងលើកទី២ក្នុងរជ្ជកាលព្រះបាទនរោត្តមក្នុងសតវត្សរ៍ទី១៩ ទើបបិតបេរ មូលហេតុដែលមានការកសាងព្រះបរមរាជវាំងចំនួន២លើកបែបនេះដោយសារតែការកសាងលើកទី១នៅ(ឆ្នាំ១៤៣៤-១៤៣៧) រាជវាំងត្រូវបានផ្លាស់ប្តូរទៅអង្គរវិញ ក្រោយពីទៅអង្គរ ទៅពោធិ៍សាត់ រួចទៅបរិបូណ៌ បន្ទាប់មកទៅលង្វែកហើយទៅ

[៩] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា ដោយបណ្ឌិត អ៊ូ វីឌី ឆ្នាំ២០១២ ត្រង់ទំព័រ៨,៩,១០។

[១០] សៀវភៅប្រវត្តិសាស្រ្តនៃព្រះរាជាណាចក្រកម្ពុជា ដោយបណ្ឌិត មីសែល ត្រាណេ ឆ្នាំ២០០៦។

ឧត្តុង្គ។ បន្ទាប់ពីឧត្តុង្គ រាជវាំងបានត្រឡប់មកសាងសង់ជាលើកទី២នៅរាជធានីភ្នំពេញ។[១១] រីឯនៅសម័យឆ្នាំ១៨៦៣ដល់ឆ្នាំ១៩៥៣ ដែលជាសម័យអាណានិគមបារាំង ប្លង់រាជធានីភ្នំពេញ និងប្លង់ទីក្រុងតាមខេត្តនានាមានរាងជាក្រឡាចត្រង្គ(មើលរូបភាពទី១-២-៣-៤)នៃឧបសម្ព័ន្ធទី១។ គេសង្កេតឃើញថាមានសំណង់បុរាណគឺត្រូវអភិវឌ្ឍន៍មួយចំនួនដែលនៅសេសសល់សព្វថ្ងៃ និងមានតម្លៃជាប្រវត្តិសាស្ត្រចាំបាច់ត្រូវរក្សា។ សំណង់ទាំងនោះច្រើនជាអាគាររដ្ឋបាលនានា ឬជាលំនៅដ្ឋានរបស់មន្ត្រីជាន់ខ្ពស់ មន្ត្រីជាជនជាតិបារាំងដែលមកធ្វើការនៅស្រុកខ្មែរ និងច្រើនមានទម្រង់ជាអាគារ ឬសំណង់យកតាមលំនាំវប្បធម៌បែបអឺរ៉ុបនៅសម័យក្លាស៊ីក ឬណេអូក្លាស៊ីកដូចជានៅតាមតំបន់រដ្ឋបាលមានសាលា ខេត្ត សាលាក្រុងភ្នំពេញ និងនៅរាជធានីភ្នំពេញគេឃើញមាននៅតំបន់រដ្ឋបាល និងនៅសង្កាត់វត្តភ្នំដែលជាលំនៅដ្ឋានរបស់មន្ត្រីជាន់ខ្ពស់បារាំង។[១២] បន្តពីឆ្នាំ១៩៥៣ដល់ ១៩៧០ កម្ពុជាទទួលបានឯករាជ្យពេញលេញពីបារាំងនៅថ្ងៃ០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។ ក្រោយពេលដែលប្រទេសកម្ពុជាបានទទួលឯករាជ្យ កម្ពុជាមានការរីកចម្រើនឡើងជាពិសេសនៅទសវត្សរ៍ឆ្នាំទី៦០។ ទន្ទឹមនឹងនេះដែរដំណើរនគរូបនីយកម្ម គេឃើញមានស្ថាបត្យកម្មបានកើតឡើង និងរីកដុះដាលនៅតាមរាជធានី ទីក្រុង ទីរួមខេត្តនានា។ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ក៏បានបន្តពង្រីក និងមានការចាក់ដីលុបបំពេញបឹងនឹងតំបន់នានាមានចំការមន បឹងកេងកង...ដើម្បីអភិវឌ្ឍន៍ទីក្រុង ដែលពេលនោះរាជធានី ឬក្រុងភ្នំពេញមានខ្សែក្រវាត់ក្រុងនៅតូច។ នៅសម័យនោះសំណង់ស្ថាបត្យកម្មដែលលេចធ្លោ គឺពហុកីឡាជាតិបានសាងសង់ឡើងសម្រាប់ប្រារព្ធក្នុងពិធីប្រកួតកីឡាហ្គានីហ្វូលើកទី១ នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៦៦ ដែលបានធ្វើឲ្យតំបន់នេះមានភាពអ៊ូអរឡើងព្រោះនៅជិតផ្សារអូឡាំពិច ផ្សារនេះបានសាង់សង់ឡើងវិញនៅលើទីតាំងចាស់ និងបានដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ១៩៩៤។[១៣] បន្តទៅមើលសម័យប៉ុលពតវិញ ក្នុងការដែលខ្មែរក្រហមបានចូលមកកាន់អំណាចថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង គ្រប់ហេដ្ឋារចនាសម្ព័ន្ធត្រូវបានបំផ្លិតបំផ្លាញធ្ងន់ធ្ងរបំផុតជារួមក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ទីក្រុងភ្នំពេញបានក្លាយជាទីក្រុងខ្មោច។ ប៉ុន្តែក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនបានវិលត្រឡប់មករស់នៅស្រុកកំណើតវិញ ក្នុងស្ថានភាពទប់ស្កាត់ការវិលត្រឡប់នៃរបបពូជសាសន៍ផង ការស្តារ និងការកសាង

[១១] គេហទំព័ររបស់សាលារាជធានីភ្នំពេញ www.phnompenh.gov.kh។

[១២] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា ដោយបណ្ឌិត អ៊ូ វ័ឌី ឆ្នាំ២០១២ ត្រង់ទំព័រ៨៨ និង៨៩។

[១៣] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា ដោយបណ្ឌិត អ៊ូ វ័ឌី ឆ្នាំ២០១២ ត្រង់ទំព័រ៩៥,៩៦ និង៩៧។

ប្រទេសផង រដ្ឋអំណាចនិងប្រជាជនបានរួមគ្នាជំនះរាល់ការលំបាកគ្រប់បែបយ៉ាងជាបន្តបន្ទាប់ និងបានកែប្រែសោភ័ណ្ឌភាពទីក្រុងរាជធានីភ្នំពេញឲ្យកាន់តែស្រស់ស្អាត។ រាជធានីភ្នំពេញសព្វថ្ងៃ វាជាផ្លូវដ៏វែងឆ្ងាយឆ្ពោះទៅកាន់រាជធានីភ្នំពេញដែលមានសុខសន្តិភាព និងរីកចម្រើន។[១៤]

### ១.១.១ មូលហេតុដែលនាំឲ្យមានការរៀបចំ

ជាទូទៅរាល់ការអភិវឌ្ឍន៍ទាំងឡាយ ឬធ្វើអ្វីមួយទៅបានគឺទាល់តែមានគម្រោងដើម្បីរៀបចំជាមុន ឬការគ្រោងទុកជាមុន។ ទន្ទឹងនឹងនេះមុនឈានទៅដល់ការរៀបចំ ការអភិវឌ្ឍន៍នូវអ្វីមួយគឺបណ្តាលមកពីគេឃើញភាពខ្វះចន្លោះ ឃើញបញ្ហាផ្សេងៗ។ ដោយឡែកនៅក្នុងក្រុង ស្រុក ខណ្ឌក៏មានការរៀបចំស្ថាបនា ការគ្រោងទុកចំពោះការអភិវឌ្ឍន៍ដែរ នោះក៏ព្រោះតែការពិនិត្យមើលឃើញពីបញ្ហាដែលនាំឲ្យមានការរៀបចំ។ ម្យ៉ាងវិញទៀតដូចឃ្លាមួយគេបាននិយាយថា "**មានហេតុ ទើបមានផល**" ពិតជាមិនខុសទេបើគ្មានហេតុបង្កទាំងឡាយ ឬបញ្ហាបង្កណាមួយទេវាក៏មិនមានផលទាំងអស់នោះដែរ។

ជាពិសេសគឺផលដែលឃើញសព្វថ្ងៃក្នុងរាជធានីភ្នំពេញ ដែលមានទាំងផ្លូវ ទាំងប្រព័ន្ធលូ ចរាចរ បង្គោលភ្លើងបំភ្លឺផ្លូវ និងបណ្តាហេដ្ឋារចនាសម្ព័ន្ធដ៏ទៃទៀត។ ដូច្នេះហើយផលដែលមើលឃើញទាំងនោះ គឺសុទ្ធសឹងតែជាបញ្ហាទាំងឡាយគួរគេប្បីធ្វើការរៀបចំជារៀងរាល់ឆ្នាំ ដើម្បីឲ្យក្រុងនេះមានសោភ័ណ្ឌភាពល្អ។ ការរៀបចំក្រុងមួយ គឺត្រូវមានការគិតគូរយ៉ាងហ្មត់ចត់ និងឲ្យគ្រប់ជ្រុងជ្រោយ ហើយបុព្វហេតុដែលនាំឲ្យមានការរៀបចំនោះមានដូចជា៖

#### ១.១.១.១.កំណើនប្រជាជន

ជាទូទៅមានសមាសភាពនៃកំណើនប្រជាជន៣សំខាន់ៗ៖

កំណើនប្រជាជននៅក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មីដែលពីមុនមកពីតំបន់នេះជាទីជនបទប៉ុណ្ណោះ។ កំណើនប្រជាជននៅក្នុងក្រុងជាលក្ខណៈធម្មជាតិបានធ្វើឲ្យមានការកើនឡើងយ៉ាងលឿនរហ័សនៃចំនួនប្រជាជន ចំណែកប្រភេទសណ្ឋានដីនៃក្រុងថ្មីដែលពីមុនមកជាទីជនបទគឺគ្រាន់តែជាធាតុចូលបន្ទាប់បន្សំតែប៉ុណ្ណោះ។[១៥]

---

[១៤] គេហទំព័ររបស់សាលារាជធានីភ្នំពេញ www.phnompenh.gov.kh ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៧។

[១៥] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ិន សកក្កដា ទំព័រ៦។

បញ្ហានៃការកើនឡើងប្រជាជន ក៏ជាកត្តាសំខាន់ផងដែរនៃការជំរុញឲ្យមានការរៀបចំ។ កត្តានៃការកើនឡើងប្រជាជនក្នុងក្រុង កំណើនជាលក្ខណៈធម្មជាតិដែលមនុស្សយើងបានបង្កកំណើតរីឯកំណើនដោយសារការចំណាកស្រុកពីជនបទ គឺការកើនឡើងនៃបណ្តាប្រជាជនមកពីតាមបណ្តាខេត្ត-ក្រុងផ្សេងៗចូលក្នុងក្រុង។

ដោយឡែករាជធានីភ្នំពេញគឺជាទីក្រុងមួយនៃប្រទេសកម្ពុជា មានការលេចចេញនូវកំណើនប្រជាជនខ្លាំងដែរ ដោយសារប្រទេសកម្ពុជាមានស្ថិរភាពនយោបាយ ក៏ដូចជាសុវត្ថិភាពសង្គមទីក្រុងភ្នំពេញចេះតែរីកធំធាត់ទៅ និងមានការអភិវឌ្ឍន៍គ្រប់វិស័យធ្វើឲ្យទីក្រុងរីកលូតលាស់ទៅគ្រប់ទិសទីយ៉ាងឆាប់រហ័ស។ ជាបន្តបន្ទាប់រហូតដល់ឆ្នាំ២០០៥ មានផ្ទៃដីទីក្រុងកើនដល់ទៅ **៣៧៥**គីឡូម៉ែត្រការ៉េ និងមានប្រជាជនរស់នៅដល់ទៅ**១.៣២៥.៦៨១**នាក់។[១៦] ភ្នំពេញបានបន្តពង្រីកខ្លួនធំឡើងៗអាស្រ័យដោយនគរូបនីយកម្មមានសន្ទុះលឿនគួរឲ្យចាប់អារម្មណ៍។ នៅទីក្រុងភ្នំពេញពីមួយថ្ងៃទៅមួយថ្ងៃកាន់តែមានការទាក់ទាញ មានមុខរបរកាន់តែស្មុគស្មាញឡើង និងមានចំណាកជនបទនៃប្រជាជនគ្រប់ប្រភេទចូលមកទីក្រុង ដើម្បីរកការងារធ្វើជាកម្មករ ក្នុងរោងចក្រកាត់ដេរ និងធ្វើការផ្នែកសេវាកម្មផ្សេងៗទៀត ឬដើម្បីបន្តការសិក្សា។

ដំណើរនគរូបនីយកម្ម គឺបានកើតឡើងដោយឯកឯង ទន្ទឹមនឹងទីក្រុងនានាមិនទាន់បានធ្វើផែនការប្រើប្រាស់ដីធ្លី។ ក្រោយកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសនាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ រដ្ឋាភិបាលកម្ពុជាបានបង្កលក្ខណៈឲ្យប្រជាជនខ្មែរដែលកំពុងរស់នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ធ្វើមាតុភូមិនិវត្តន៍ចូលមករស់នៅក្នុងទឹកដីកម្ពុជា ដែលក្រោយមកពួកគាត់បានវិលមករស់នៅក្នុងទីក្រុង និងទីប្រជុំជនវិញ។ ចលនានេះបានដើរទន្ទឹមគ្នានឹងលំហូរប្រជាជនចេញពីទីជនបទចូលមករស់នៅក្នុងទីក្រុងនានា ជាពិសេសក្រុងភ្នំពេញ និងបានបង្កើតឲ្យមានការតាំងទីលំនៅលើដីរដ្ឋ មានដូចជាលើសួនច្បារសាធារណៈ លំហសាធារណៈ ដីឯកជនរបស់រដ្ឋ ដីរបស់បុគ្គល ដីវត្តអារាម លើប្រឡាយទឹក... និងនៅទីតាំងដែលអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាព ដូចជាលើប្រព័ន្ធលូបង្ហូរទឹកកាកសំណល់ និងលើទីតាំងដែលងាយរងគ្រោះថ្នាក់ ដូចជាលើដីចំណីផ្លូវថ្នល់ ផ្លូវរថភ្លើង លើទំនប់ទឹក ការពារទឹកជំនន់ លើច្រាំងទន្លេ ស្ទឹង ព្រែក លើដំបូលទៅវ៉ាស...។[១៧]

---

[១៦] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា ដោយបណ្ឌិត អ៊ូ វ៉ីឌី ឆ្នាំ២០១២ ត្រង់ទំព័រ១២៦។

[១៧] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា ដោយបណ្ឌិត អ៊ូ វ៉ីឌី ឆ្នាំ២០១២ ត្រង់ទំព័រ១២៧។

បើពិនិត្យមើលលើដង់ស៊ីតេប្រជាជនទីក្រុងភ្នំពេញ នៅឆ្នាំ១៩៩៨ មាន**៣.៨៤៨**នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។ នៅឆ្នាំ២០០៨ ដង់ស៊ីតេប្រជាជននៅលើទីតាំងដដែលនេះបានកើនឡើងមានដល់ទៅ**៤.៩៧១**នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ដែលអាចបង្ហាញឲ្យដឹងថាក្នុងរយៈពេល១០ឆ្នាំនៃចន្លោះជំរឿនប្រជារាស្ត្រពីឆ្នាំ១៩៩៨ មកទល់នឹងឆ្នាំ២០០៨ ដង់ស៊ីតេប្រជាជនក្រុងភ្នំពេញ បានកើនឡើងដល់ទៅ**១.១២៣**នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ព្រោះក្រុងភ្នំពេញជារាជធានី ជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា ជាទីតាំងក្បាលម៉ាស៊ីនដឹកនាំប្រទេស ជាតំបន់សួលរដ្ឋបាល និងជាតំបន់ស្រូបយកកម្លាំងពលកម្មមកធ្វើការកាន់តែច្រើន និងជាតំបន់ទាក់ទាញស្រូបយកគ្រប់វិស័យ និងមានមុខរបរកាន់តែស្មុគស្មាញដូចជា ទីក្រុងធំៗនៅបណ្តាប្រទេសអភិវឌ្ឍន៍ និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតលើពិភពលោក។ នៅទីក្រុងភ្នំពេញក្នុងមួយឆ្នាំ មានអត្រាកំណើនប្រជាជន**៣,២**ភាគរយដូចនេះក្នុងមួយឆ្នាំទីក្រុងភ្នំពេញមានចំនួនប្រជាជនប្រមាណជា**៤០.០០០**នាក់ ដែលត្រូវកើនឡើងឬប្រមាណជា**១០.០០០**គ្រួសារក្នុងមួយឆ្នាំ។[១៨] ចំណែកឯនៅក្នុងឆ្នាំ២០១២វិញ ប្រជាជនបានកើនឡើងដល់ចំនួន **១.៥០១.៧២៥**នាក់។[១៩]

ម្យ៉ាងវិញទៀតចំនួននៃការកើនឡើងប្រជាជនក្នុងពិភពលោក បានកើនឡើងដល់ចំនួន**៦,១**ពាន់លាននាក់ ក្នុងពាក់កណ្តាលឆ្នាំ២០០០ទៅហើយ ដោយឡែកបច្ចុប្បន្នកំពុងកើនឡើងជាមធ្យមចំនួន**៧,៧**លាននាក់ក្នុងមួយឆ្នាំ។ នៅក្នុងឆ្នាំ២០២៥ខាងមុខចំនួនប្រជាជនពិភពលោកនឹងកើនឡើងនៅចន្លោះពីចំនួន**៧,៩** ទៅ**១០,៩**ពាន់លាននាក់។ បើទោះបីជាមានប្រទេសមួយចំនួនបានលេចចេញនូវអត្តិភាពនៃអត្រាមរណៈភាពខ្ពស់ដោយសារជម្ងឺអេដស៍ក៏ដោយ ក៏កំណើនប្រជាជននៅតែខ្ពស់ដដែល។ យ៉ាងណាមិញចំនួនប្រជាជននៅក្នុងប្រទេសអភិវឌ្ឍន៍នៅពេលបច្ចុប្បន្ននេះគឺមិនត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងរយៈពេល៥០ឆ្នាំខាងមុខឡើយ ដោយសារតែកម្រិតនៃការមានកូនត្រូវបានគេដាក់ឲ្យស្ថិតក្រោមកម្រិតកំណត់។ ផ្ទុយទៅវិញចំនួនប្រជាជនក្នុងប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានព្យាករណ៍ថានឹងកើនឡើងពី**៤,៩**ពាន់លាននាក់ នៅក្នុងឆ្នាំ២០០០ នឹងកើនឡើងដល់**៨,២**ពាន់លាននាក់ ក្នុងឆ្នាំ២០៥០។[២០]

---

[១៨] សៀវភៅប្រវត្តិនគរូបនីយកម្មនៅកម្ពុជា ដោយបណ្ឌិត អ៊ូ វ៉ីឌី ឆ្នាំ២០១២ ត្រង់ទំព័រ១២៨។

[១៩] ទិន្នន័យនេះត្រូវបានដកស្រង់ចេញពីគេហទំព័រសាលារាជធានីភ្នំពេញ (www.phnompenh.gov.kh.com)។

[២០] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ទំព័រ៦,៧។

### ១.១.១.២.ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រមានការលំបាកនៅក្នុងការកំណត់ តែជាទូទៅភាពក្រីក្រសំដៅដល់តម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួមប្រទេសភាគច្រើនបានកំណត់ពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាបដែលពួកគេមិនអាចចាយវាយគ្រប់គ្រាន់ក្នុងជីវភាពប្រចាំថ្ងៃឡើយ។ តម្រូវការរូបកាយ ចំណីអាហារ លំនៅដ្ឋាន ការងារ ធនធានទឹក អគ្គីសនី អនាម័យ សុខុមាលភាពសង្គមមានការខ្វះខាត។

ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើចំណូលទាបរបស់បុគ្គលមួយរូបៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជា៖ ចំនួននៃករណីឧក្រិដ្ឋកម្ម អំពើហិង្សា ឬអាយុសង្ឃឹមរស់ជាមធ្យមមិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈប្រាក់ចំណូលនេះឡើយ ជាធម្មតាអ្នកដែលទទួលបានប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មត់ថាជាជនក្រីក្រ។[២១]

មិនតែប៉ុណ្ណោះបើដាក់បន្ទាត់មួយក្រិតឲ្យស្មើគ្នានោះរវាងភាពក្រីក្រនៅជនបទ និងភាពក្រីក្រនៅទីក្រុងឃើញថាពុំមានលក្ខណៈសមភាពទេ មូលហេតុដោយសារថាជាធម្មតាចំណាយនៅទីក្រុងខ្ពស់ជាងជនបទដាច់ឆ្ងាយណាស់។ ស្របពេលជាមួយគ្នា អ្នករស់នៅក្នុងទីជនបទអាចមានឱកាសស្វែងរកការចិញ្ចឹមជីវិត តាមរយៈការទទួលអំណោយ ភោគផលពីធម្មជាតិច្រើនជាងអ្នកនៅទីក្រុង។ តាមរយៈនេះគេអាចនិយាយថាអ្នកក្រីក្រនៅទីក្រុងក្រជាង និងមានស្ថានភាពលំបាកជាងអ្នកក្រនៅទីជនបទ។[២២]

ម្យ៉ាងវិញទៀតក្នុងប្រទេសកម្ពុជាមានប្រជាពលរដ្ឋមួយចំនួន ដែលពួកគាត់មានសមត្ថភាពមានជីវភាពប្រសើរ ដោយមានការជួយជ្រោមជ្រែងពីស្ថាប័នផ្សេងៗ និងមានការងារធ្វើមានប្រាក់ខែសមរម្យសម្រាប់ចិញ្ចឹមជីវិត។ ប៉ុន្តែភាពក្រីក្រនៃប្រជាជន ទោះបីជាកំណើនសេដ្ឋកិច្ចមានការកើនឡើងក៏ដោយ នៅតែមានប្រជាពលរដ្ឋមួយចំនួនមានជីវភាពខ្វះខាតនៅឡើយ នេះបណ្តាលមកពីពួកគាត់ខ្វះចំណេះដឹងជំនាញ និងទុនដើម្បីយកមកធ្វើជាមុខរបរចិញ្ចឹមជីវិត។

### ១.១.១.៣.កម្រិតជីវភាពនៃការរស់នៅ

ភាពខុសគ្នានៃស្ថានភាពជីវភាពរស់នៅ គឺជាកត្តាចម្បងដែលត្រូវបានគិតគូរនៅពេលមានការពិភាក្សាការជម្រុញឲ្យមានការរៀបចំក្រុង។ កម្រិតជីវភាព និងប្រាក់បៀវត្សន៍ខ្ពស់នៅទីក្រុង ជាកត្តា

[២១] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិតអ៊ុន សកក្កដា ទំព័រ៧។

[២២] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិតអ៊ុន សកក្កដា ត្រង់ទំព័រទំព័រ៨។

ទាក់ទាញមនុស្សឲ្យមករស់នៅទីក្រុង។ ដរាបណាភាពខុសគ្នារវាងទីក្រុង និងជនបទមានគម្លាតខ្ពស់ ប្រជាពលរដ្ឋនៅជនបទនៅតែចង់មករស់នៅទីក្រុង។ ជាទូទៅកត្តាសេដ្ឋកិច្ច និងអត្រានិកម្មភាពខ្ពស់ជាកត្តាជម្រុញឲ្យចំណាកស្រុកដោយសារតែពេលខ្លះការងារនៅជនបទនៅមានកម្រិត ដូច្នេះទោះជាទទួលបានប្រាក់ខែទាបក៏ត្រូវតែបង្ខំចិត្តចំណាកស្រុកមកកាន់ទីក្រុងដែរ។ លើសពីនេះនៅក្នុងទីក្រុងមានប្រមូលផ្តុំដោយកត្តាសង្គម នយោបាយល្អប្រសើរ ខណៈពេលសេវាសុខាភិបាល និងសេវាអប់រំមានសម្បូរបែប រិតតែធ្វើឲ្យអ្នករស់នៅមានអារម្មណ៍ថាមានសុវត្ថិភាពជាងកន្លែងណាៗទាំងអស់។[២៣]

ករណីបើឧស្សាហកម្ម និងការងារទាំងឡាយមិនបានចូលទៅក្នុងតំបន់ជនបទ ទោះបីជាមានប្រាក់កម្រៃទាបក៏ដោយក៏ពួកគេប្រហែលជាឲ្យកូនទៅស្វែងរកការងារធ្វើនៅទីក្រុងដែរ។ រីឯបញ្ហាអប់រំក៏ជាឧបសគ្គមួយបន្ថែមទៀតកាលបើជនបទគ្មានហើយទីក្រុងមាន។ មិនតែប៉ុណ្ណោះភាពលំអៀងតាមតំបន់ទីក្រុង ឬតំបន់ជនបទមិនដូចគ្នាតាមរយៈការវិនិយោគទុន និងគោលនយោបាយសេដ្ឋកិច្ចជាហេតុធ្វើឲ្យមានចំណាកស្រុកច្រើន។

សរបញ្ជាក់ផងដែរថា កម្រិតជីវភាពនៃការរស់នៅតំបន់ជនបទ និងតំបន់ទីក្រុងវាមានភាពមិនស្មើគ្នា ពីព្រោះតែវិស័យជាច្រើនទាំងបណ្តាហេដ្ឋារចនាសម្ព័ន្ធ ទាំងវិស័យអប់រំ វិស័យសុខាភិបាល និងវិស័យជាច្រើនទៀតដែលទីក្រុងមាន ប៉ុន្តែនៅជនបទពុំមាន។

**១.១.១.៤.ការដាក់សម្ពាធបរិស្ថាន**

សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅជនបទ ពាក់ព័ន្ធវិស័យបរិស្ថានគឺកង្វះដីបង្កបង្កើនផលដើម្បីធ្វើកសិកម្ម។ ករណីនេះកើតមានច្រើនក្នុងពេលដែលដីរបស់ពួកគេទទួលបានពីដូនតា ឪពុក ឬម្តាយរបស់ខ្លួន ត្រូវបានពួកគេចែកឲ្យកូនៗអស់។ ចំណែកផ្ទៃដីដែលនៅសល់មានទំហំតូច មិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬបង្កបង្កើនផលដំណាំផ្សេងៗឡើយ ហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះ និងគ្មានជីវជាតិទៀត។ ប្រសិនបើក្រឡេកទៅមើលជ្រុងមួយទៀតចំពោះប្រជា-ពលរដ្ឋក្រីក្រនៅពេលដែលពួកគាត់មានដីគ្រប់គ្រាន់ហើយ តែគាត់បែរជាកង្វះប្រព័ន្ធធារាសាស្ត្រស្រោចស្រប និងជីកសិកម្មសម្រាប់បង្កបង្កើនផលបានគ្រប់គ្រាន់ទៅវិញ ករណីនេះច្រើនកើតនៅប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់មេគង្គក្រោម។[២៤]

---

[២៣] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិតអ៊ុន សកក្កដា ត្រង់ទំព័រ៨។

[២៤] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិតអ៊ុន សកក្កដា ត្រង់ទំព័រ៩។

បញ្ហាសម្ពាធបរិស្ថាននៅប្រទេសឥណ្ឌូនេស៊ីវិញ ប្រជាជនថ្វាមានការកើនឡើងជាច្រើន។ ហើយជនជាតិថ្វាដែលគ្មានទីកន្លែងរស់នៅគឺមានចំនួនរាប់លាននាក់ ដូចនេះពួកគេបានធ្វើអន្តោ-ប្រវេសន៍ ហើយចំនួនដ៏ច្រើននៃការធ្វើអន្តោប្រវេសន៍នេះគឺគ្មានការងារធ្វើ និងអ្នកដែលរស់នៅក្នុងទីក្រុងគ្មានទីជម្រកជាហេតុដាក់សម្ពាធដល់បរិស្ថានយ៉ាងធ្ងន់ធ្ងរ។ មួយវិញទៀតវាជាការដាក់សម្ពាធបរិស្ថានដែរ គឺដោយសារពួកគេទៅរស់នៅលើដីជាកន្លែងដែលមិនអាចបង្កបង្កើនផលបានជារៀងរាល់ឆ្នាំ ហើយទិន្នផលនិងប្រាក់ចំណូលតែងតែធ្លាក់ចុះជាបន្តបន្ទាប់។ ឆ្លើយតបចំពោះបញ្ហានេះក្រុមអន្តោប្រវេសន៍ខ្លះបានប្តូរការងារមកធ្វើជាអ្នកកាប់ឈើខ្នាតតូច អ្នកខ្លះទៀតក៏ទៅធ្វើជាកម្មកររបស់គេ។[២៥]

ជនអន្តោប្រវេសន៍ជាច្រើន គឺមានការខ្វះខាតទាំងដើមទុន និងជំនាញផ្សេងៗ ដូច្នេះគេអាចរកកន្លែងរស់នៅបានតែក្នុងតំបន់អាណាធិបតេយ្យ និងរកការងារបានតែផ្នែកមិនផ្លូវការតែប៉ុណ្ណោះ អ្នកខ្លះលក់ដូរតាមចិញ្ចើមថ្នល់ ខ្លះលក់តាមផ្លូវ ឬរើសអេតចាយផ្សេងៗ។ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺការចាប់យកទ្រព្យសម្បត្តិសាធារណៈ លំហដែលទំនេរ ទ្រព្យសម្បត្តិឯកជនដែលមិនបានប្រើប្រាស់រចនាសម្ព័ន្ធទីក្រុង និងបរិស្ថានទីក្រុងទូទៅក្លាយជាការបើកទូលាយក្នុងការចាប់យកធនធានទាំងឡាយមកប្រើប្រាស់។ តំបន់អាណាធិបតេយ្យដ៏កកកុញរបស់ទីក្រុង សំណង់មិនល្អគ្មានអនាម័យ កាកសំណល់រឹងដែលមិនបានប្រមូល ទន្លេកខ្វក់ ការស្ទះចរាចរ ទីក្រុងបាតុកម្ម មានការកាប់បំផ្លាញព្រៃឈើ ការរិចរិលដី ការចាប់ត្រីច្រើនហួសហេតុ សត្វស៊ីស្មៅទាល់តែរលាយហិនហោច ការរិចរិលទឹក និងបញ្ហាសម្ពាធបរិស្ថានដ៏ទៃទៀតដែលនៅសេសសល់។[២៦]

ការដាក់សម្ពាធលើបរិស្ថានភាគច្រើនមាននៅជនបទ គឺទាក់ទងនឹងការកើនឡើងនៃការខ្វះដីធ្លី និងការធ្លាក់ចុះនៃដីមានជីវជាតិ ហើយច្រើនតែកើតចំពោះប្រជាពលរដ្ឋជនបទដែលពួកគេគ្មានដីសម្រាប់បង្កបង្កើនផល ឬការដែលមានដីហើយ តែបែរជាខ្វះនូវប្រព័ន្ធធារាសាស្ត្រស្រោចស្រប ដូចជាជីជាដើម។

### ១.១.១.៥.គមនាគមន៍

គមនាគមន៍ក៏ជាបញ្ហាដែលសំខាន់មួយក្នុងការជម្រុញឲ្យមានការអភិវឌ្ឍន៍ដែរ ជាពិសេសគឺបញ្ហាផ្លូវ។ ផ្លូវជាបញ្ហាចោទមួយដែលអាចធ្វើឲ្យទីក្រុងមានសោភ័ណ្ឌភាព កាលណាផ្លូវធ្វើដំណើរពី

[២៥] គេហទំព័រ Geography.weebly.com ចូលមើល ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៧ ស្ថិតក្នុងចំណុច៣.១ ប្រអប់ទី១។

[២៦] គេហទំព័រ Geography.weebly.com ចូលមើល ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៧ នៅត្រង់ចំណុច៣.៤។

កន្លែងមួយទៅកន្លែងមួយទៀតមានការខូច ឬទឹកជន់លិចបណ្តាលឲ្យខូចផ្សេងៗ ឬផ្លូវលំ ផ្លូវដីស ដែលមានកុហុកច្រើន វាជាបញ្ហាដែលគួរតែមើលឃើញ។

ការលូតលាស់ផ្នែកកសិកម្ម ឧស្សាហាកម្ម ពាណិជ្ជកម្ម និងទេសចរណ៍គឺទាក់ទងយ៉ាងជិតស្និតទៅនឹងការរីកចម្រើនខាងផ្លូវគមនាគមន៍ មានន័យថាទាំងផ្លូវទឹក ផ្លូវថ្នល់ ផ្លូវដែក សុទ្ធតែជាសសៃឈាមនៃសេដ្ឋកិច្ចជាតិ។ នៅក្នុងប្រទេសកម្ពុជាមានបណ្តាញផ្លូវគោក ផ្លូវទឹក ផ្លូវអាកាសសម្រាប់ធ្វើដំណើរ និងដឹកជញ្ជូនទំនិញផ្សេងៗទាំងក្នុងប្រទេសនិងក្រៅប្រទេស។[២៧] ដូចនេះវិស័យគមនាគមន៍ វាជាមធ្យោបាយយ៉ាងសំខាន់មិនអាចខ្វះបានសម្រាប់ទំនាក់ទំនងអន្តរជាតិ វាបានជួយសម្រួលដល់ការនាំចេញនាំចូល ដែលជាដំណើរប្រព្រឹត្តទៅនៃការអភិវឌ្ឍន៍លើគ្រប់វិស័យ ហើយវាជាកត្តាមួយសំខាន់ដែលជម្រុញឲ្យមានការរៀបចំ ក៏ដូចជាការអភិវឌ្ឍន៍ដើម្បីឲ្យទីក្រុង ឬប្រទេសមានសោភ័ណ្ឌភាព។

**១.១.១.៦.សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

នេះជាបញ្ហាសំខាន់ដែលកើតមានឡើងពីការប្រព្រឹត្តបទល្មើស និងបញ្ហាគ្រោះថ្នាក់ចរាចរ ដោយពួកគាត់គ្មានការយោគយល់គ្នា ពួកគាត់មានការធ្វេសប្រហែសខ្លាំង និងមូលហេតុជាច្រើនទៀតដូចជា៖

-ការយល់ដឹងពីច្បាប់នៅមានកំរិត

-ចរាចរ និងប្រើប្រាស់គ្រឿងញៀន

-សេពគ្រឿងស្រវឹង

-មិនគោរពច្បាប់ចរាចរ

-មានចោរកម្ម

-លក់ដូរតាមដងផ្លូវគ្មានសណ្តាប់ធ្នាប់

-ការចតរថយន្តគ្មានសណ្តាប់ធ្នាប់

-កំណើនយានយន្ត

-ក្មេងទំនើង

-មានអ្នកលេងល្បែងស៊ីសង។

[២៧] សៀវភៅភូមិវិទ្យាសេដ្ឋកិច្ច និងមនុស្សនៃប្រទេសកម្ពុជា គណៈកម្មការរៀបរៀង គឺលោក-លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៣-២០១៤។

បញ្ហាទាំងអស់នេះ សុទ្ធតែជាមូលហេតុជម្រុញពីក្រោយក្នុងការរៀបចំសណ្តាប់ធ្នាប់ឲ្យមានសោភ័ណ្ឌភាព និងប្រកបដោយសុវត្ថិភាពផងដែរ។

### ១.១.២ រចនាសម្ព័ន្ធខណ្ឌសែនសុខ

**រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល**




+ការិយាល័យប្រជាពលរដ្ឋ

-ទទួលពាក្យបណ្តឹង

-សម្របសម្រួល

-បញ្ជូនបន្ត

+ការិយាល័យផែនការ និងអភិវឌ្ឍន៍

-ការងារផែនការ

-អនុវត្តគម្រោង និងកម្មវិធីអភិវឌ្ឍន៍

-សម្របសម្រួល ការគាំទ្រកិច្ចសហប្រតិបត្តិការការអភិវឌ្ឍន៍

-ត្រួតពិនិត្យ វាយតម្លៃ

**+ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**

-ការងាររដ្ឋបាល សរុប និងបុគ្គលិក

-ការងារស្ថិតិប្រជាពលរដ្ឋ និងអគ្រានុកូលដ្ឋាន

-ព័ត៌មាន

-ការងារហិរញ្ញវត្ថុ និងគ្រប់គ្រងទ្រព្យសម្បត្តិ

-ការងារលេខាធិការក្រុមប្រឹក្សា

**+ការិយាល័យអន្តរវិស័យ**

-ការងារដីធ្លី និងសំណង់

-ការងារសណ្តាប់ធ្នាប់សាធារណៈច្បាប់ និងសិទ្ធមនុស្ស

-ការងារសេដ្ឋកិច្ច សង្គមកិច្ច

-ការងារដោះស្រាយវិវាទនៅមូលដ្ឋាន

**+ការិយាល័យច្រកចេញចូលតែមួយ**

-ការងារនីត្យានុកូលកម្ម

-វិស័យវប្បធម៌ និងវិចិត្រសិល្បៈ

-វិស័យអប់រំ យុវជន និងកីឡា

-វិស័យទេសចរណ៍

-វិស័យកសិកម្ម

-ការងារអគ្រានុកូលដ្ឋាន

-វិស័យសំណង់

-វិស័យឧស្សាហកម្ម រ៉ែ និងថាមពល

-វិស័យពាណិជ្ជកម្ម

-វិស័យសាធារណការ និងដឹកជញ្ជូន

-វិស័យសុខាភិបាល

-វិស័យសុរិយោដី

**+អង្គភាពលទ្ធកម្ម**

-ការងារដេញថ្លៃ សម្រាប់ប្រភេទលទ្ធកម្មនីមួយៗ

-ការងារផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ

-សេចក្តីព្រាងកិច្ចសន្យាដោយអនុលោមតាមបទដ្ឋាន និងគំរូកិច្ចសន្យា

-តាមដានការទូទាត់តម្លៃកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ អ្នកទទួលការ ឬទីប្រឹក្សា

-រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ។[២៨]

**រចនាសម្ព័ន្ធខណ្ឌសែនសុខ**




សាលាខណ្ឌសែនសុខគឺត្រូវបានដឹកនាំដោយអភិបាលខណ្ឌ០១រូប និងអមដោយអភិបាលរងខណ្ឌ០៤រូប។ នៅក្នុងសាលាខណ្ឌនេះ អភិបាលនៃគណៈអភិបាលខណ្ឌត្រូវទទួលបន្ទុកដូចជា៖

-ដឹកនាំការងាររួម

-ដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅ

-ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

-កិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន

ចំណែកឯអភិបាលរងខណ្ឌ០៤រូបទៀតទទួលបន្ទុកការងារមួយចំនួនមានដូចខាងក្រោម៖

អភិបាលរងខណ្ឌ០១រូបទទួលបន្ទុកការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

[២៨] តារាងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលខណ្ឌសែនសុខ ខែមេសា ឆ្នាំ២០១៧។

-កិច្ចការពត៌មាន អប់រំ យុវជន និងកីឡា

-កិច្ចការវេទិកាសាធារណៈ

-កិច្ចការសិទ្ធិមនុស្ស

-អង្គការក្រៅរដ្ឋាភិបាល

-គណបក្សនយោបាយ សមាគមន៍

-កិច្ចការស្ថិតិ និងអត្រានុកូលដ្ឋាន

-កិច្ចការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ

-កិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-កិច្ចការពាណិជ្ជកម្ម ឧស្សាហកម្ម រ៉ែ និងថាមពល

-កិច្ចការធនាគារ រតនាគារ

-ការងារពន្ធដារសាខាកាំកុងត្រូល និងរដ្ឋាករ

-កិច្ចការលទ្ធកម្ម

-ការងារគ្រប់គ្រងផ្ទះជួល

-ការងារគ្រប់គ្រងផ្សារ

-ការងារសិប្បកម្ម

អភិបាលរងខណ្ឌ០១រូបទទួលបន្ទុកការិយាល័យផែនការ និងអភិវឌ្ឍន៍

-កិច្ចការផែនការ

-កិច្ចការវិនិយោគ

-កិច្ចការអភិវឌ្ឍន៍ជនបទ

-កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ

-កិច្ចការនារី និងកុមារ

-ការងារទេសចរណ៍

-ការងារសត្តឃាត

-ការងារសហគមន៍អ្នកក្រីក្រ

អភិបាលរងខណ្ឌ០១រូបទទួលបន្ទុកការិយាល័យអន្តរវិស័យៈ

-ការងារធម្មការ សាសនា

-កិច្ចការសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា

-ទឹកស្អាត

-កិច្ចការសាធារណការ និងដឹកជញ្ជូន

-កិច្ចការធនធានទឹក ឧតុនិយម និងធារាសាស្ត្រ

អភិបាលរងខណ្ឌ០១រូបទទួលបន្ទុកការិយាល័យអន្តរវិស័យះ

-កិច្ចការបរិស្ថាន និងគ្រប់គ្រងសំណល់រឹងរាវ

-កិច្ចការនគរូបនីយកម្ម សំណង់ និងសុរិយោដី

-កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល

-អង្គភាពអគ្គីសនី

-កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍

-កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ

-ការងារកាកបាទក្រហម។[២៩]

## ១.២.បច្ចុប្បន្នភាព និងទិសដៅអនាគតនៃការរៀបចំខណ្ឌសែនសុខ

ខណ្ឌសែនសុខ គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១២ក្នុងរាជធានីភ្នំពេញ ដែលមានសង្កាត់ចំនួន៤ គឺសង្កាត់ឃ្មួញ សង្កាត់ទឹកថ្លា សង្កាត់ក្រាំងធ្នង់ និងសង្កាត់ភ្នំពេញថ្មី។ ខណ្ឌនេះជាខណ្ឌមួយមានសក្តានុពលសំខាន់ក្នុងការអភិវឌ្ឍន៍ និងមានប្រជាពលរដ្ឋ៥%(ប្រាំភាគរយ) ប្រកបមុខរបរកសិកម្ម ក្រៅពីនេះគឺ៩៥%(កៅសិបប្រាំភាគរយ)ប្រកបរបរអាជីវកម្ម។ ទាំងអស់នេះជាការបង្ហាញឲ្យឃើញពីការប្រកបមុខរបររបស់ប្រជាពលរដ្ឋក្នុងខណ្ឌសែនសុខទាំងមូល គឺភាគច្រើនប្រកបរបរអាជីវកម្ម។ មិនតែប៉ុណ្ណោះវិស័យឯកជន គឺជាក្បាលម៉ាស៊ីនដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ច ដូច្នេះទាមទារឲ្យមានការវិនិយោគផ្ទាល់ពីវិស័យឯកជនក្នុងមូលដ្ឋានខណ្ឌទាំងមូល ដូចជាបង្កើតរោងចក្រសហគ្រាសដែលអាចបង្កើតការងារដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ម្យ៉ាងវិញទៀតដើម្បីឲ្យវិស័យឯកជនចូលមកវិនិយោគក្នុងមូលដ្ឋានខណ្ឌ ត្រូវដាក់ចេញនូវគោលការណ៍ផ្សេងៗដូចជាះ

-លើកទឹកចិត្ត និងជំរុញការចូលរួមរបស់វិស័យឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធតាមការពិនិត្យឡើងវិញ តាមច្បាប់ស្តីពីសម្បទានព្រមទាំងលិខិតបទដ្ឋានគតិយុត្តិ

[២៩] តារាងរចនាសម្ព័ន្ធគ្រប់គ្រងខណ្ឌសែនសុខខែមេសា ឆ្នាំ២០១៧។

-បន្តការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងៗ។[៣០]

**១.២.១.បច្ចុប្បន្នភាពនៃការរៀបចំ**

ស្ថិតក្នុងខណ្ឌនេះដែរ គឺមានការអភិវឌ្ឍន៍លើវិស័យជាច្រើន ប៉ុន្តែក្នុងខណៈនេះគឺលើកតែមួយចំនួនប៉ុណ្ណោះមកធ្វើការបកស្រាយក្នុងនោះរួមមាន ការអភិវឌ្ឍន៍លើវិស័យហេដ្ឋារចនាសម្ព័ន្ធសំណង់លំនៅដ្ឋាន ការងាររៀបចំសណ្ដាប់ធ្នាប់ និងការងារសាធារណការ។

**១.២.១.១.ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ**

បណ្តាហេដ្ឋារចនាសម្ព័ន្ធរួមមានការកសាងផ្លូវ លូបង្ហូរទឹក បង្គោលភ្លើង និងស្ពាន...។ ទាំងបណ្តាផ្លូវ លូបង្ហូរទឹក ស្ពាន បង្គោលភ្លើង គឺសុទ្ធតែមានសារៈសំខាន់ទាំងអស់ដែលផ្តល់ឲ្យខណ្ឌនេះមានសោភ័ណ្ឌភាព និងកាត់បន្ថយការកកស្ទះលូ ក៏ដូចជាការកកស្ទះផ្លូវផ្សេងៗ។

**ក.ការកសាងផ្លូវ**

ការងារស្តាបនាផ្លូវក្នុងខណ្ឌសែនសុខ ដែលបានបញ្ចប់នាឆ្នាំ២០១៥-២០១៦ មានដូចតទៅ៖

-ខណ្ឌសែនសុខមានការជួសជុសផ្លូវបេតុងភូមិទឹកថ្លាប្រវែង ៥៣៦ម៉ែត្រ×៧.៥ម៉ែត្រ ដែលចាប់ផ្តើមនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល១ឆ្នាំ

-ជួសជុលផ្លូវចាក់បេតុង នៅសង្កាត់ឃ្មួញ ភូមិសែនសុខទី៧ប្រវែង ១១០០ម៉ែត្រ×៦ម៉ែត្រ ចាប់ផ្តើមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ មានរយៈពេល១ឆ្នាំ

-ជួសជុលផ្លូវចាក់បេតុង នៅសង្កាត់ភ្នំពេញថ្មី ភូមិគោកឃ្លាងប្រវែង ៨៣៦ម៉ែត្រ×៦ម៉ែត្រ ចាប់ផ្តើមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល១ឆ្នាំ

-ជួសជុលផ្លូវចាក់បេតុង ភូមិព្រៃខ្លាប្រវែង ៩៥០ម៉ែត្រ×៦ម៉ែត្រ ចាប់ផ្តើមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រយៈពេល១ឆ្នាំនៅសង្កាត់ក្រាំងធ្នង់

-ជួសជុលផ្លូវបេតុង ភូមិស្លែងរលើងចាប់ពីផ្លូវលេខ៥៥៥ ដល់ផ្លូវណាតប្រ៊ីដប្រវែង ៨១២ម៉ែត្រ×៦ម៉ែត្រ ចាប់ផ្តើមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មានរយៈពេល១ឆ្នាំ

-ជួសជុលផ្លូវចាក់បេតុង ភូមិភ្នំពេញថ្មីប្រវែង ៥៩០ម៉ែត្រ×៦ម៉ែត្រ ចាប់ផ្តើមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ រយៈពេល១ឆ្នាំ នៅសង្កាត់ភ្នំពេញថ្មី

-ជួសជុលផ្លូវលេខ ១៩៥៨B ក្រាលកៅស៊ូ AC ប្រវែង ៥៧០ម៉ែត្រ×៨ម៉ែត្រ ចាប់ផ្តើមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ រយៈពេល១ឆ្នាំ សង្កាត់ភ្នំពេញថ្មី

[៣០] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៦-២០១៨ របស់ខណ្ឌសែនសុខ ត្រង់ទំព័រ២។

-ជួសជុលផ្លូវចាក់បេតុង ប្រវែង៤០០ម៉ែត្រ×៦ម៉ែត្រ នៅភូមិក្រាំងធ្នង់ សង្កាត់ក្រាំងធ្នង់ចាប់ផ្តើមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ រយៈពេល១ឆ្នាំ

-ជួសជុលផ្លូវក្រាលគ្រួសក្រហម នៅសង្កាត់ក្រាំងធ្នង់ចាប់ផ្តើមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ រយៈពេល១ឆ្នាំ។

-ជួសជុលផ្លូវក្រាលគ្រួសក្រហម នៅសង្កាត់ឃ្មួញចាប់ផ្តើមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ រយៈពេល១ឆ្នាំ។[៣១]

-ការស្ថាបនាផ្លូវលេខ១៩៨២ ចាប់ពីផ្លូវលេខ៥៩៨ ដល់ផ្លូវលេខ១០១១ ដែលមានបណ្តោយប្រវែង ១.០៥០ម៉ែត្រ×៦ម៉ែត្រ×០.១៨ម៉ែត្រ សម្រេចបាន១០០%(មួយរយភាគរយ) ស្ថាបនាដោយក្រុមហ៊ុនស៊ីណូខនស្រ្តាក់សិន អិនវែសមិន

-ស្ថាបនាផ្លូវសំបុកមាន់បេតុងអាមេ អ៊ុតបេតុងកៅស៊ូមូលនិធិខណ្ឌសែនសុខ២០១៦ ស្ថាបនាដោយក្រុមហ៊ុនBBE

-ស្ថាបនាផ្លូវលេខ១៩៥៧ ចាប់ពីផ្លូវលេខ១៩៦២ ដល់ចំណុចP.K៤០០ បណ្តោយ៤០០ម៉ែត្រ×៧ម៉ែត្រ×០.១៥ម៉ែត្រ សម្រេចបាន១០០% (មួយរយភាគរយ)

-ស្ថាបនាផ្លូវលេខ១៩៥៨B ចាប់ពីផ្លូវលេខ៥៩៨ ដល់ផ្លូវលេខ១០០៣ អ៊ុតបេតុងកៅស៊ូ ដែលមានបណ្តោយប្រវែង ៥៧០ម៉ែត្រ×៨ម៉ែត្រ×០.០០៥ម៉ែត្រ សម្រេចបាន១០០% (មួយរយភាគរយ)

-ស្ថាបនាផ្លូវបេតុង ផ្លូវលំចាប់ពីវិហារចិនដល់ផ្លូវណាតប្រ៊ីដផ្លូវចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ

-ស្ថាបនាផ្លូវបេតុងចាប់ពីផ្លូវ២០០០ ដល់ផ្លូវ១៩៨៦ ភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ បណ្តោយ ៤៩៤ម៉ែត្រ×៦ម៉ែត្រ×០.១៥មែត្រ សម្រេចបាន៤០%(សែសិបភាគរយ)។[៣២]

-ការស្ថាបនាផ្លូវបេតុងចំនួន ៨៨១២៦ម៉ែត្រការ៉េ នៅសង្កាត់ក្រាំងធ្នង់

-ការស្ថាបនាផ្លូវបេតុងចំនួន ២៨៩២៦ម៉ែត្រការ៉េ នៅសង្កាត់ភ្នំពេញថ្មី

-ការស្ថាបនាផ្លូវបេតុងចំនួន ១៨៥១៨ម៉ែត្រការ៉េ នៅសង្កាត់ទឹកថ្លា

-ការស្ថាបនាផ្លូវបេតុងចំនួន ៦១០៦០ម៉ែត្រការ៉េ នៅសង្កាត់ឃ្មួញ។[៣៣]

---

[៣១] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៦-២០១៨ របស់ខណ្ឌសែនសុខ។

[៣២] របាយការណ៍ប្រចាំឆ្នាំ២០១៦ ស្តីពីការអនុវត្តន៍ការងារ របស់រដ្ឋបាលខណ្ឌសែនសុខ។

[៣៣] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៦-២០១៨ របស់ខណ្ឌសែនសុខ។

### ខ.ប្រព័ន្ធលូបង្ហូរទឹកក្នុងខណ្ឌសែនសុខ

នៅក្នុងខណ្ឌសែនសុខបានរៀបចំនៅប្រព័ន្ធលូបង្ហូរទឹក ដើម្បីកាត់បន្ថយការកកស្ទះលូដែលធ្វើឲ្យជន់លិចផ្លូវ។ ហើយការស្តាបនាលូប្រឡាយទាំងនេះមានដូចជាៈ

-ស្ថិតក្នុងភូមិបុរី១០០ខ្នង មានការសាងសង់ប្រព័ន្ធលូថ្មីដែលមានប្រវែង១២៦៥ម៉ែត្រ×០.៦ម៉ែត្រ ចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ មានរយៈពេល ១ឆ្នាំ

-ដាក់លូថ្មីនៅសង្កាត់ទឹកថ្លា ក្នុងភូមិស្លែងរលើងចាប់ពីផ្លូវ៥៥៥ ដល់ណតប្រ៊ីដប្រវែង ៨១២ម៉ែត្រ×០.៨ម៉ែត្រសម្រេចបាននៅឆ្នាំ២០១៦

-ដាក់លូថ្មីសង្កាត់ទឹកថ្លា ក្នុងភូមិចុងថ្នល់ខាងលិចមានប្រវែង១០០ម៉ែត្រ×០.៦ម៉ែត្រ សម្រេចបាននៅឆ្នាំ២០១៦

-ដាក់ប្រព័ន្ធលូថ្មីផ្លូវហាណូយសង្កាត់ភ្នំពេញថ្មីប្រវែង ១២០ម៉ែត្រ×១ម៉ែត្រសម្រេចបាននៅឆ្នាំ ២០១៦

-ស្តាប្រឡាយក្នុងសង្កាត់ឃ្មួញប្រវែង ១.១០០ម៉ែត្រ និងបញ្ចប់ឆ្នាំ២០១៦

-ស្តាប្រឡាយក្នុងសង្កាត់ក្រាំងធ្នង់ប្រវែង៥០០ម៉ែត្រ និងបញ្ចប់នៅក្នុងខែធ្នូ ឆ្នាំ២០១៦។[៣៤]

-រៀបចំប្រព័ន្ធលូប្រវែង២.១០០ម៉ែត្រ មុខកាត់០.៨ម៉ែត្រ សម្រេចបាន១០០%(មួយរយភាគរយ) នៅតាមបណ្តោយផ្លូវលេខ៥៩៨ ដល់ផ្លូវ១០១១

-ដាក់លូផ្លូវ១០១៩ ពីឱសថស្ថានចេស្តា ដល់សាលាបង្រៀនបើកបរ២៣តុលា បណ្តោយលូ ១២០ម៉ែត្រ មុខកាត់១ម៉ែត្រ

-ដាក់លូមុខកាត់នៅភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លាខណ្ឌសែនសុខប្រវែងបណ្តោយលូ ១០០ម៉ែត្រ មុខកាត់០.៦ម៉ែត្រ

-ដាក់លូនៅភូមិវិមានទ្រង់ សង្កាត់ក្រាំងធ្នង់ខណ្ឌសែនសុខ ស្តាបនាដោយក្រុមហ៊ុនបុរីមហា-សែនសុខ ថវិកាក្រុមហ៊ុនបុរីមហាសែនសុខប្រវែងបណ្តោយ៤២៥ម៉ែត្រ មុខកាត់១ម៉ែត្រ សម្រេចបាន១០០%(មួយរយភាគរយ)

-ដាក់លូលើផ្លូវចាប់ពីវិហារចិន ដល់ផ្លូវណតប្រ៊ីដ ភូមិចុងថ្នល់ខាងលិចសង្កាត់ទឹកថ្លាប្រវែង

[៣៤] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៦-២០១៨ របស់ខណ្ឌសែនសុខ។

បណ្ដោយលូ៨១២ម៉ែត្រ មុខកាត់០.៨ម៉ែត្រ។[៣៥]

-ដាក់ប្រព័ន្ធលូថ្មីនៅសង្កាត់ទឹកថ្លាប្រវែងមុខកាត់ ១១៨០ម៉ែត្រ×១ម៉ែត្រ និងមុខកាត់១៩៤ម៉ែត្រ×0,៣ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅសង្កាត់ភ្នំពេញថ្មីប្រវែងមុខកាត់ ១៥០០ម៉ែត្រ×១,៥ម៉ែត្រ និងមុខកាត់ ១៨០ម៉ែត្រ×0,៦ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅភូមិបុរី១០០ខ្នងប្រវែង ៦៥០ម៉ែត្រ×0,៦ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅភូមិគោកឃ្លាងប្រវែង ៨៤០ម៉ែត្រ×១ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅភូមិច្រេសប្រវែង ១០១៦ម៉ែត្រ×១ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅភូមិដីថ្មីប្រវែង ៧៤៧ម៉ែត្រ×១ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅភូមិត្រពាំងស្វាយប្រវែង ១១០០ម៉ែត្រ×១ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅភូមិភ្នំពេញថ្មីប្រវែង ៨៤៧ម៉ែត្រ×១ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅភូមិរោងចក្រប្រវែង ១៣៥៦ម៉ែត្រ×១ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅភូមិពោងពាយប្រវែង ៧០០ម៉ែត្រ×១ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅភូមិបន្លាស្អិតប្រវែង ២៤០០ម៉ែត្រ×0,៦ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅភូមិសែនសុខទី៤ប្រវែង ១២០០ម៉ែត្រ×0,៦ម៉ែត្រ

-ដាក់ប្រព័ន្ធលូថ្មីនៅភូមិសែនសុខទី៥ប្រវែង ១២០០ម៉ែត្រ×0,៦ម៉ែត្រ

-សង្កាត់ក្រាំងធ្នង់ដាក់ប្រព័ន្ធលូរំដោះទឹកអមសងខាងផ្លូវមានប្រវែង ១៩៦២ម៉ែត្រ×១ម៉ែត្រ

-ស្តារប្រព័ន្ធលូនៅសង្កាត់ទឹកថ្លា ភូមិស្លែងរលើងចាប់ពីផ្លូវសហព័ន្ធរុស្ស៊ីដល់ផ្លូវ២០០១មានប្រវែង ៦៨០ម៉ែត្រ×0,៦ម៉ែត្រ

-ស្តារប្រព័ន្ធលូនៅសង្កាត់ភ្នំពេញថ្មីមានប្រវែង ៥៤០០ម៉ែត្រ×១ម៉ែត្រ

-ស្តារប្រឡាយអូតាគុជមានប្រវែង ៣៨០០ម៉ែត្រ និងទទឹង១០ម៉ែត្រ នៅសង្កាត់ភ្នំពេញថ្មី។[៣៦]

**គ.ការដាក់បង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈ**

ក្នុងខណ្ឌសែនសុខមានការរៀបចំបង្គោលភ្លើងបំភ្លឺផ្លូវមួយចំនួន ដើម្បីឲ្យមានសោភ័ណ្ឌភាពប្រកបដោយសុវត្ថិភាពដែលមាននៅសង្កាត់ដូចជា៖

[៣៥] របាយការណ៍ប្រចាំឆ្នាំ ២០១៦ ស្ដីពីការអនុវត្តន៍ការងារ របស់រដ្ឋបាលខណ្ឌសែនសុខ។

[៣៦] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៦-២០១៨ របស់ខណ្ឌសែនសុខ។

-សង្កាត់ទឹកថ្លារៀបចំបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈចំនួន ១០៧៨ដើម

-សង្កាត់ភ្នំពេញថ្មីរៀបចំបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈចំនួន ៤៧២ដើម

-សង្កាត់ឃ្មួញរៀបចំបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈចំនួន ៥០០ដើម

-សង្កាត់ក្រាំងធ្នង់រៀបចំបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈចំនួន ៥០០ដើម។

**ឃ.ស្ពាន**

នៅក្នុងខណ្ឌសែនសុខមានការស្ថាបនាស្ពានបេតុង ដែលគម្រោងនេះបានបញ្ចប់ទៅហើយ និងបានដាក់ឲ្យប្រើប្រាស់សម្រាប់ឆ្លងកាត់ប្រឡាយអូតាគុជចំនួន ០២ ដែលកន្លែងនីមួយៗមានទំហំ ៧ម៉ែត្រ×១០ម៉ែត្រ នៅភូមិដីថ្មី។[៣៧] លើសពីនេះទៅទៀតក៏មានការស្ថាបនាស្ពានអាកាសនៅលើផ្លូវសហព័ន្ធរុស្ស៊ីផងដែរ ប៉ុន្តែគម្រោងនេះស្ថាបនាមិនទាន់រួចរាល់ឡើយ។

**១.២.១.២.ការអភិវឌ្ឍន៍សំណង់លំនៅដ្ឋាន**

សំណង់លំនៅដ្ឋានជាចំណុចដែលអាជ្ញាធររដ្ឋត្រូវពិនិត្យ ដើម្បីការពារសុវត្ថិភាព សណ្តាប់-ធ្នាប់សាធារណៈប្រកបដោយគុណភាពសំណង់ និងអាចដឹងពីផលប៉ះពាល់ក្នុងការជួសជុល ឬការកែសម្រួលបណ្តាសំណង់ ព្រមជាមួយនិងការចេញនូវលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើអគារលំនៅដ្ឋាន អគារសាធារណៈ ដែលធ្វើការសាងសង់ខុសពីក្បួនច្បាប់បច្ចេកទេសនៃការសាងសង់។[៣៨] លំនៅដ្ឋាន និងការតាំងទីលំនៅថ្មីជាបញ្ហាពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ទីក្រុង ដែលត្រូវមានការចូលរួមពីវិស័យនានាទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិក្នុងការកសាងផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី ការងារសំណង់ ការងារស្ថាបត្យកម្ម វិស្វកម្ម ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ការស្វែងរកហិរញ្ញប្បទាន និងប្រភពធនធានការវាយតម្លៃអំពីផលប៉ះពាល់បរិស្ថាន និងសង្គម។ល។ ដូច្នេះត្រូវមានការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធ និងការរៀបចំនូវលិខិតបទដ្ឋានគតិយុត្តផ្សេងៗឆ្លើយតបទៅនឹងគោលនយោបាយលំនៅដ្ឋាន មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធតាមលំដាប់ថ្នាក់របស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន និងសហគមន៍ផ្ទាល់។ គោលនយោបាយលំនៅដ្ឋានត្រូវសង្កត់ធ្ងន់លើយុទ្ធសាស្ត្រគាំទ្រដូចជាការចូលរួមសម្រេចរបស់សហគមន៍មូលដ្ឋាន និងការផ្តល់ហិរញ្ញប្បទានសម្រាប់ជួសជុល ឬសាងសង់លំនៅដ្ឋាន ការសាងសង់លំនៅដ្ឋានថ្មីដើម្បីដោះស្រាយតម្រូវការចំពោះមុខ ការកំណត់

[៣៧] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៦-២០១៨ របស់ខណ្ឌសែនសុខ។

[៣៨] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិតអ៊ុន សកក្កដា ទំព័រ៦៨។

មូលដ្ឋានសម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដីនៅទីក្រុង ទីប្រជុំជន ទីជនបទ ការរៀបចំនូវបណ្តាហេដ្ឋារចនាសម្ព័ន្ធ សេវាសាធារណៈ និងការកំណត់តម្លៃសេវានៃការអនុញ្ញាតសាងសង់។ល។[៣៩]

មិនតែប៉ុណ្ណោះរាល់បុគ្គល ឬស្ថាប័នឯកជនក៏ដូចជាអាជ្ញាធរត្រូវហាមឃាត់មិនឲ្យសាងសង់លើទីធ្លារដែលមានលក្ខណៈជាសាធារណៈដូចតទៅ៖

-ទីបម្រុងទុកទឹក និងទំនប់ទឹក

-ទីបម្រុងជីករ៉ែ និងតំបន់ព្រៃឈើ

-រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រ

-សួនច្បារឧទ្យានសាធារណៈ និងតំបន់អភិវឌ្ឍន៍

-ដីបម្រុងទុកសម្រាប់ផ្លូវ ដីបម្រុងសម្រាប់ចំណីផ្លូវ និងដីបម្រុងទុកសម្រាប់ផ្លូវរថភ្លើង និងអាកាសយានដ្ឋាន

-ទន្លេ សមុទ្រ ព្រែក ស្ទឹងព្រមទាំងឆ្នេរច្រាំង

-ជាទូទៅនៅលើដីទាំងឡាយណា ដែលបញ្ញត្តិច្បាប់កំណត់មិនឲ្យសង់។[៤០]

រាល់រូបវន្តបុគ្គល និងនីតិបុគ្គលសាធារណៈ ឬឯកជនមានសិទ្ធិសាងសង់អគារលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ហើយសិទ្ធិសាងសង់នេះគឺត្រូវបានទទួលការការពារដោយអនុក្រឹត្យ។ លិខិតអនុញ្ញាតសាងសង់ ដែលត្រូវបានចេញឲ្យមុនការសាងសង់ជាគ្រឹះនៃភាពស្របច្បាប់របស់សំណង់។ ដើម្បីឲ្យប្រជាពលរដ្ឋជាពិសេសប្រជាជនក្រីក្រមានលំនៅដ្ឋានសម្រាប់រស់នៅ រាល់សំណង់តូចតាចធ្វើអំពីឈើ ឬស្លឹក រុក្ខជាតិនានាពុំទាមទារឲ្យសុំលិខិតអនុញ្ញាតសាងសង់ឡើយដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់។[៤១]

សំណង់ដែលពុំចំណុះក្រោមលិខិតអនុញ្ញាតសាងសង់ដូចជា៖

-សំណង់លំនៅដ្ឋានប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និងតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភ័ណ្ឌជាតិ តំបន់រក្សាទុកការពារដោយពុំគិតពីទំហំ ឬសម្ភារៈសំណង់ប្រើប្រាស់ឡើយ។

---

[៣៩] គោលនយោបាយជាតិស្តីពីលំនៅដ្ឋាន ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ ត្រង់ចំណុចទី៥ ផែនការសកម្មភាព។

[៤០] មាត្រា១២ កថាខណ្ឌ១ នៃច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់លេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ។

[៤១] មាត្រា១ កថាខណ្ឌទី១ វក្យខណ្ឌ១,២,៤ នៃអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់លេខ៨៦អនក្រ/បក ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧។

-ការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់លើក-លែងតែការជួសជុលនោះ អាចបណ្តាលឲ្យប៉ះពាល់ដល់អ្នកជិតខាង។

-បណ្តាសំណង់មានដូចខាងក្រោមនេះ ដោយគ្រាន់តែជូនដំណឹងអំពីគម្រោងសាងសង់ទៅអាជ្ញាធរមូលដ្ឋានដូចតទៅ៖

+ទីសក្ការៈបូជា

+សាលាសំណាក់សាធារណៈ

+បណ្តាការប្រសិល្បះរបស់រដ្ឋសម្រាប់សេវាសាធារណៈដែលរដ្ឋជាម្ចាស់កិច្ចការ។[៤២]

ដូច្នេះសំណង់លំនៅដ្ឋានវាក៏ជាបញ្ហាស្មុគស្មាញ ក្នុងការរៀបចំដើម្បីឲ្យមានសោភ័ណ្ឌភាព ព្រោះនោះមានសំណង់មួយចំនួនដែលរំលោភលើផ្លូវសាធារណៈ និងមានសំណង់មួយចំនួនទៀតដែលពុំទាន់មានលិខិតអនុញ្ញាតសាងសង់នៅឡើយ។

បញ្ហាដែលបានរំលោភលើផ្លូវសាធារណៈ និងការសាងសង់ផ្សេងៗដែលពុំទាន់មានលិខិតអនុញ្ញាតសាងសង់ គឺកើតមានផងដែរនៅក្នុងរាជធានីភ្នំពេញ។ ដោយឡែកខណ្ឌសែនសុខជាខណ្ឌមួយនៅក្នុងរាជធានីភ្នំពេញក៏កើតមាននូវបញ្ហាទាំងនេះដែលធ្វើឲ្យអាជ្ញាធរខិតខំធ្វើការរុះរើ និងចុះដកហូតសម្ភារៈផ្សេងៗ។ ម្យ៉ាងវិញទៀតក្នុងខណ្ឌនេះសំបូរទៅដោយបុរីជាច្រើនដូចជាបុរីភ្នំពេញថ្មី បុរីវ៉ារីណា បុរីពិភពថ្មី... ដែលជួយឲ្យខណ្ឌនេះមានសោភ័ណ្ឌភាព។ តែទោះជាយ៉ាងណាក៏នៅមានសំណង់ផ្សេងៗដ៏ទៃមួយចំនួនទៀត ដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈផងដែរ។

### ក.ការងារសំណង់ខណ្ឌសែនសុខ និងដីធ្លី

-ចុះរុះរើរបងថ្មដែលសាងសង់រំលោភចូលផ្លូវសាធារណៈបាន០២ទីតាំង នៅផ្លូវលេខ១០១៩ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ។

-ចុះរុះរើសំណង់នៅផ្លូវសាធារណៈ០៨ទីតាំង

-ចុះសហការជាមួយBAU ដើម្បីពិនិត្យទីតាំងដីច្រមុះជ្រូកដែលប្រជាពលរដ្ឋស្នើសុំធ្វើប័ណ្ណកម្មសិទ្ធិ នៅភូមិបន្លាស្អិត សង្កាត់ឃ្មួញបានចំនួន ២៥គ្រួសារ

-ដាំស្លាកហាមចោលសំរាម១ស្លាកនៅផ្លូវលេខ១៩៨៦

-ចុះដកហូតសម្ភារៈសំណង់គ្មានលិខិតអនុញ្ញាតសាងសង់១៤កន្លែង នៅសង្កាត់ទឹកថ្លា១០ទីតាំង សង្កាត់ក្រាំងធ្នង់០៣ទីតាំង និងសង្កាត់ឃ្មួញ០១ទីតាំង

[៤២] មាត្រា៣ នៃអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់លេខ៨៦អនក្រ/បក ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧។

-ចុះផ្អាកការដ្ឋានសំណង់ពុំមានលិខិតអនុញ្ញាតសាងសង់

-ចុះរើសំណង់លើផ្លូវសាធារណៈនៅក្នុងភូមិសាស្ត្រខណ្ឌសែនសុខ

-គ្រប់គ្រងដីធ្លី និងលំនៅដ្ឋានដែលមិនរៀបរយនៅសង្កាត់ទាំងបួន(ចំនួន ១២លើក)។[៤៣]

**ខ.ការអភិវឌ្ឍន៍បុរីក្នុងខណ្ឌសែនសុខ**

ជាកាពិតណាស់ ការបង្កើតបុរីគឺពិតជាបង្កនូវលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង ព្រោះបុរីត្រូវបានសាងសង់ដោយមានលក្ខណៈស្តង់ដានៃការសាងសង់ត្រឹមត្រូវ។ មិនតែប៉ុណ្ណោះការអភិវឌ្ឍន៍បុរីអាចជួយសម្រួលដល់ការតាំងទីលំនៅផងដែរ កាលណាបុរីអភិវឌ្ឍន៍រួចម្ចាស់បុរីអាចផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋតាមរយៈការបង់រំលោះបន្តិចម្តងៗ ក្នុងការទទួលបានសំណង់ ឬផ្ទះផ្សេងៗ។ ម្យ៉ាងវិញទៀតការអភិវឌ្ឍន៍បុរីច្រើន អាចកាត់បន្ថយនូវបញ្ហាសំណង់អាណាធិបតេយ្យ និងការកាន់កាប់ដីរដ្ឋខុសច្បាប់ថែមទៀតផង។ តួយ៉ាងការអភិវឌ្ឍន៍បុរីក្នុងខណ្ឌសែនសុខ គឺមានច្រើនដែលបុរីទាំងនេះមានដូចជា បុរីភ្នំពេញថ្មី បុរីពិភពថ្មី បុរីវ៉ារីណា និងបុរីជាច្រើនទៀត...។

ខណ្ឌនេះមានការអភិវឌ្ឍន៍លើបុរីច្រើន ដូចនេះក៏អាចជួយសម្រួលដល់អាជ្ញាធររដ្ឋក្នុងការគ្រប់គ្រងនិងកាត់បន្ថយនូវសំណង់អាណាធិបតេយ្យដែលធ្វើឲ្យគ្មានសណ្តាប់ធ្នាប់ គ្មានរបៀបរៀបរយបង្កឲ្យបាត់បង់នូវសោភ័ណ្ឌភាព។

**១.២.១.៣.ការងាររៀបចំសណ្តាប់ធ្នាប់ និងការងារសាធារណការ**

ការរៀបចំសណ្តាប់ធ្នាប់ និងការងារសាធារណការដែលអាជ្ញាធររដ្ឋបានចុះរៀបចំសណ្តាប់-ធ្នាប់នៅតាមបណ្តាផ្លូវ តាមបណ្តាលូបង្ហូរទឹកមួយចំនួនក្នុងខណ្ឌសែនសុខដែលបានកកស្ទះផ្សេងៗក្នុងគោលដៅអភិវឌ្ឍន៍បណ្តាហេដ្ឋារចនាសម្ព័ន្ធប្រកបដោយសោភ័ណ្ឌភាព។

**ក.ការងាររៀបចំសណ្តាប់ធ្នាប់**

-ចុះរៀបចំសណ្តាប់ធ្នាប់នៅផ្លូវលេខ៣៧១ ផ្លូវឧកញ៉ាម៉ុងរិទ្ធី ផ្លូវលេខ២៧១ ផ្លូវលេខ១០១៩ ផ្លូវលេខ១៩៨៦ ផ្លូវផ្សារឈូកមាស ផ្លូវសម្តេចជាស៊ីម ផ្លូវលេខ១៩២៨(ផ្សារដើមអំពិល) ផ្លូវលេខ១០០៧(ផ្សារក្រមួន) និងផ្លូវសហព័ន្ធរុស្ស៊ី ឃាត់រថយន្តតាក់ស៊ីដែលវង្វេងចំណតបានចំនួន៥៩គ្រឿង និងរថយន្តដឹកដីបានចំនួន៣០គ្រឿងមកធ្វើកិច្ចសន្យាអប់រំ

-ចុះណែនាំដល់ម្ចាស់កុងទីន័រ និងរោងស្នាក់នៅរបស់កម្មករឲ្យរុះរើចេញពីផ្លូវសាធារណៈបានចំនួន០៣ទីតាំង

[៤៣] របាយការណ៍ប្រចាំឆ្នាំ២០១៦ ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលខណ្ឌសែនសុខ។

-ចុះណែនាំរថយន្តធន់ធំចតលើចិញ្ចើមផ្លូវសម្តេចជាស៊ីម ដែលធ្វើឲ្យមានការកកស្ទះចរាចរបានចំនួន១២ឡាន

-ចុះណែនាំការដ្ឋានសំណង់ដែលបង្ហូរទឹកមកលើផ្លូវសាធារណៈបានចំនួន០១ទីតាំង

-ចុះរៀបចំសណ្តាប់ធ្នាប់ ដោយបានណែនាំឲ្យម្ចាស់សិប្បកម្មបញ្ឈប់ការដាក់តាំងសម្ភារៈផ្សេងៗនិងរើគំនរឈើចេញពីចិញ្ចើមផ្លូវសាធារណៈស្ថិតនៅផ្លូវលេខ៥៩៨ ភូមិទំនប់សង្កាត់ភ្នំពេញថ្មី

-ចុះពិនិត្យទីតាំងទិញលក់អេតចាយ ដែលដាក់លក់ទំនិញលើផ្លូវសាធារណៈបានចំនួន០១ទីតាំង

-ចុះឃាត់រថយន្តកុងទីន័រ ដែលធ្វើឲ្យខូចខាតលើផ្លូវបេហាណ្វាយបានចំនួន០២គ្រឿង និងចាប់រថយន្តដឹកឥដ្ឋជាន់ល្វបែកបានចំនួន០១គ្រឿង ស្ថិតនៅផ្លូវលេខ១៩៥២ សង្កាត់ភ្នំពេញថ្មី

-ចុះកាត់ស្លាកឃីហោគ្មានរបៀបរៀបរយបានចំនួនសរុប៥២ស្លាក ដែលនៅផ្លូវលេខ១៩២៨បានចំនួន១៤ស្លាក ផ្លូវលេខ៥៩៨បានចំនួន០៣ស្លាក និងផ្លូវលេខ១៩៨៦បានចំនួន៣៥ស្លាក

-ចូលរួមជាមួយក្រុមហ៊ុនស៊ីនទ្រីសម្អាតអនាម័យតាមផ្លូវលេខ១០១៩ និងផ្លូវសហព័ន្ធរុស្សី

-ចុះរៀបចំសណ្តាប់ធ្នាប់ផ្លូវលេខ២០០៤ សង្កាត់ទឹកថ្លា ចាប់បានម៉ាស៊ីនធុងខ្យល់បាញ់ថ្នាំចំនួន០១គ្រឿង កូនរឺម៉ក់រុញបានចំនួន០១គ្រឿង និងថ្នាំលាបប៩០បានចំនួន០២ធុង ដាក់លើចិញ្ចើមផ្លូវសាធារណៈមកធ្វើកិច្ចសន្យាអប់រំ

-ចុះរៀបចំសណ្តាប់ធ្នាប់ឃាត់រថយន្តឃីឌុប និងរថយន្តដឹកដីបានចំនួន០៦គ្រឿងដែលចតលើផ្លូវសាធារណៈស្ថិតនៅសង្កាត់ភ្នំពេញថ្មីយកមកធ្វើកិច្ចសន្យាអប់រំ

-ចុះណែនាំ ដកហូតរនាំងដែកដែលដាក់លើផ្លូវសាធារណៈបានចំនួន០៤រនាំង និងដកហូតសម្ភារៈមួយចំនួនស្ថិតនៅភូមិបន្លាស្អិត សង្កាត់ឃ្មួញ

-ចុះឃាត់រថយន្តដឹកធូន់បានចំនួន០៣គ្រឿង ស្ថិតនៅផ្លូវលេខ៩២ ភូមិបន្លាស្អិតសង្កាត់ឃ្មួញ (ម្ចាស់រថយន្តសន្យាសហការជួសជុលផ្លូវ)

-ចុះរៀបចំសណ្តាប់ធ្នាប់នៅផ្លូវលេខ២០០៤ ដកហូតបានធុងបាសចំនួន០១គូ និងម៉ាស៊ីនភ្លើងចំនួន០១គ្រឿង របស់ក្រុមតន្ត្រីជនពិការយកមករក្សាទុកនៅរដ្ឋបាលខណ្ឌដើម្បីធ្វើការអប់រំ

-ចុះរៀបចំសណ្តាប់ធ្នាប់នៅផ្លូវសហព័ន្ធរុស្សីដកហូតអារក្លៀងចំនួន០១ស្បោងធំ ធុងទឹកកកចំនួន០១យួរ យកមករក្សាទុកនៅរដ្ឋបាលខណ្ឌដើម្បីធ្វើកិច្ចសន្យាអប់រំ

-ចុះរៀបចំសណ្តាប់ធ្នាប់នៅផ្សារដើមអំពិលលើផ្លូវឧកញ៉ាម៉ុងរិទ្ធី ដកហូតបានផ្លាកយីហោចំនួន០៣ផ្ទាំង ទូកញ្ចក់ចំនួន០៦ទូ ស្បែកជើងចំនួន១០គូ និងគ្រែសាច់ជ្រូកចំនួន០៩គ្រែ យកមករក្សាទុកនៅរដ្ឋបាលខណ្ឌដើម្បីធ្វើកិច្ចសន្យាអប់រំ

-ចុះរៀបចំសណ្តាប់ធ្នាប់នៅផ្លូវសម្តេចជាស៊ីម ឃាត់បានរថយន្តកុងទីន័រចំនួន០២គ្រឿងយកមករក្សាទុកនៅរដ្ឋបាលខណ្ឌ

-ចូលរួមសហការជាមួយកម្លាំងកងរាជអាវុធហត្ថខណ្ឌ ឃាត់អ្នកលេងល្បែងជល់មាន់បានចំនួន០៥នាក់ និងម៉ូតូចំនួន០៣គ្រឿងស្ថិតនៅភូមិសែនសុខទី៧ សង្កាត់ឃ្មួញ និងឃាត់អ្នកកត់កន្ទុយលេខបានចំនួន០៣ ស្ថិតនៅផ្សារឈូកមាស ភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់។[៥៥]

## ខ.ការងារសាធារណការ

-ចុះដោះស្រាយបញ្ហាតភ្ជាប់លូនៅផ្លូវ២០០២ ភូមិត្រពាំងឈូក និងភូមិស្លែងរលើង (ភាគីទាំងពីរឯកភាពគ្នា)

-ចុះឃាត់រថយន្តដឹកដីនៅសង្កាត់ក្រាំងធ្នង់ ដើម្បីឲ្យម្ចាស់ឡានដឹកដី ម្ចាស់រណ្តៅដីជួសជុលផ្លូវបេតុងដែលខូចខាតមានទំហំ១០០០ម៉ែត្រការ៉េឡើងវិញ

-រៀបការីឡាមុខរដ្ឋបាលសង្កាត់ឃ្មួញបានប្រវែង២៥០ម៉ែត្រការ៉េ

-ចាក់ខ្សាច់មុខសាលាបឋមសិក្សាឃ្មួញបានចំនួន០៦ឡានធំ

-ស្តារប្រឡាយនៅភូមិបុរី១០០ខ្នង បានប្រវែង២០ម៉ែត្រស្របតាមបណ្តោយផ្លូវរទេះភ្លើង

-ចុះឈូសឆាយផ្លូវនៅភូមិសេបេសេ សង្កាត់ទឹកថ្លាបានប្រវែង១០០ម៉ែត្រ

-ចុះវាស់វែងរកអ័ក្សផ្លូវ ដើម្បីស្ថាបនាផ្លូវបេតុងបានចំនួន១១ទីតាំង ស្ថិតនៅសង្កាត់ភ្នំពេញថ្មី សង្កាត់ឃ្មួញ និងសង្កាត់ក្រាំងធ្នង់

-ចុះឃាត់ឡានដឹកដីគ្មានលិខិតអនុញ្ញាតបានចំនួន១៨គ្រឿង ណែនាំឲ្យមកសុំលិខិតអនុញ្ញាតឲ្យបានត្រឹមត្រូវ

-ចូលរួមសហការជាមួយមន្ទីរសាធារណការរាជធានីភ្នំពេញ និងក្រុមហ៊ុនស៊ីនទ្រីចុះស្តារប្រព័ន្ធលូផ្លូវ១៩៨៦ បានប្រវែង១២០ម៉ែត្រសង្កាត់ភ្នំពេញថ្មី

-ចុះសហការជាមួយក្រុមហ៊ុនBBE សិក្សាដើម្បីស្ថាបនាបន្តផ្លូវលេខ១០០៣ ចាប់ពីផ្លូវលេខ១៩៨៦ ដល់សណ្ឋាគាម៉ូនណាបានប្រវែង២០៧ម៉ែត្រ

---

[៥៥] របាយការណ៍ប្រចាំឆ្នាំ២០១៦ ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលខណ្ឌសែនសុខ។

-ចុះសហការជាមួយក្រុមហ៊ុនបុរីភ្នំពេញថ្មី ពង្រីកចិញ្ចើមចាប់ពីផ្លូវលេខ១៩៨៦ ដល់ផ្លូវលេខ ១៩៦៦

-ស្តារអណ្តូងលូផ្លូវលេខ២០០២ បានចំនួន២៦អណ្តូង សង្កាត់ទឹកថ្លា

-ចូលរួមសហការជាមួយរដ្ឋបាលរាជធានីភ្នំពេញ និងសង្កាត់ទឹកថ្លាបានចុះរុះរើខ្សែភ្លើងនៅផ្លូវសហព័ន្ធរុស្ស៊ី

-ចុះពិនិត្យម៉ាស៊ីនបូមទឹក ស្ថិតនៅស្ថានីយ៍បូមទឹកបុរី១០០ខ្នង សង្កាត់ទឹកថ្លា

-ចុះពិនិត្យទីតាំងស្នើសុំធ្វើស្ពាននៅប្រឡាយទួលសំពៅភូមិសំរោងទាវ សង្កាត់ក្រាំងធ្នង់

-ចុះពិនិត្យទីតាំងបាក់ដីបិទមុខលូនៅប្រឡាយទួលសំពៅ ស្ថិតនៅព្រំប្រទល់ភូមិសែនសុខ សង្កាត់ឃ្មួញ និងភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់

-ចុះពិនិត្យការដ្ឋានដាក់លូបង្ហូរទឹកស្ថិតនៅភូមិវិមានទ្រង់ សង្កាត់ក្រាំងធ្នង់

-ចុះពិនិត្យទីតាំងស្នើសុំដាក់លូបានចំនួន០៩ទីតាំង ស្ថិតនៅភូមិគោកឃ្លាង ភូមិច្រេស និងភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី

-ចុះពិនិត្យទីតាំងជីក និងស្តារប្រឡាយទួលសំពៅសម្រេចបានប្រវែង២២០ម៉ែត្រ ស្ថិតនៅភូមិដំណាក់ សង្កាត់ភ្នំពេញថ្មី

-ចុះពិនិត្យទីតាំងជីកបើកមុខទឹក ដែលកកស្ទះនៅប្រឡាយមេទួលសំពៅបានចំនួន២ទីតាំង ស្ថិតនៅនៅភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់

-ចុះពិនិត្យទីតាំងស្នើសុំកាត់ផ្លូវបេតុងបានចំនួន១៣ទីតាំង ស្ថិតនៅសង្កាត់ភ្នំពេញថ្មីចំនួន៩ទីតាំង សង្កាត់ទឹកថ្លាចំនួន៣ទីតាំង សង្កាត់ឃ្មួញចំនួន១ទីតាំង

-ចុះពិនិត្យទីតាំងស្នើសុំដាក់បង្គោលភ្លើងថ្មីចំនួន០៥ដើម ភូមិត្រពាំងស្វាយ សង្កាត់ភ្នំពេញថ្មី

-ចូលរួមសហការជាមួយមន្ទីរសាធារណការសម្អាតផ្លូវ និងស្តារលូតាមបណ្តោយផ្លូវសហព័ន្ធ-រុស្ស៊ី ផ្លូវលេខ១០១៩ ផ្លូវលេខ១៩៨៦ ស្ថិតនៅសង្កាត់ទឹកថ្លា និងសង្កាត់ភ្នំពេញថ្មី

-ចូលរួមសហការជាមួយការិយាល័យភូមិបាលខណ្ឌ ចុះដាក់ម៉ាស៊ីនវាស់វែងរកអ័ក្សផ្លូវដើម្បីតទឹកស្អាតជូនប្រជាពលរដ្ឋស្ថិតនៅភូមិបន្លាស្អិត សង្កាត់ឃ្មួញ

-ចុះពិនិត្យការស្នើសុំធ្វើផ្លូវបេតុងចំនួន០១ខ្សែ ដែលមានប្រវែង៣២០ម៉ែត្រនៅភូមិត្រពាំងរាំង សង្កាត់ឃ្មួញ

-ចុះពិនិត្យទីតាំងអណ្តូងលូបាក់ស្រុតបានចំនួន០១ទីតាំងស្ថិតនៅផ្លូវលេខ២០០២ ភូមិស្លែងរលើងសង្កាត់ទឹកថ្លា

-ចុះពិនិត្យទីតាំងស្នើសុំផ្គត់ផ្គង់ទឹកស្អាតរបស់ប្រជាពលរដ្ឋចំនួន២៨គ្រួសារ នៅភូមិទំនប់ សង្កាត់ភ្នំពេញថ្មី

-ចុះផ្អាកទីតាំងដាក់អណ្តូងលូស្ថិតនៅភូមិត្រពាំងមាន សង្កាត់ក្រាំងធ្នង់បានចំនួន០១ទីតាំង

-ចុះពិនិត្យទីតាំងដាក់លូ និងរៀបបារដីកាត់ប្រឡាយមេទួលសំពៅដែលបាក់ស្រុតស្ថិតនៅសង្កាត់ក្រាំងធ្នង់

-ចុះពិនិត្យការជួសជុលអណ្តូងលូដែលមានទំហំ១,២ម៉ែត្រ×២ម៉ែត្រ ស្ថិតនៅភូមិទឹកថ្លាច្រកចូលបុរីភ្នំពេញថ្មី សង្កាត់ទឹកថ្លា

-ចុះពិនិត្យការស្តារប្រឡាយ ដើម្បីនាំទឹកពីភូមិបុរី១០០ខ្នង មកស្ថានីយ៍បូមទឹកបុរី១០០ខ្នងស្ថិតក្នុងសង្កាត់ទឹកថ្លាបានប្រវែង៣៥០ម៉ែត្រ

-ចុះពិនិត្យបញ្ហាម៉ាស៊ីនបូមនៅស្ថានីយ៍បូមទឹកសង្កាត់ទឹកថ្លា(ខូចប្រើការមិនបាន)

-ចុះឃាត់សកម្មភាពចាក់ដីបិតមុខទឹកស្ថិតនៅភូមិទំនប់ សង្កាត់ភ្នំពេញថ្មី និងឃាត់រថយន្តដឹកដី(យកមកណែនាំធ្វើកិច្ចសន្យា)

-ចុះពិនិត្យស្តារប្រព័ន្ធលូស្ថិតនៅសង្កាត់ទឹកថ្លាសម្រេចបានប្រវែង២៥០ម៉ែត្រ

-ចូលរួមសហការជាមួយមន្ទីរសាធារណការ ក្រុមហ៊ុនស៊ីនទ្រីធ្វើការប្រមូលសម្រាម និងបូមលូតាមបណ្តោយផ្លូវលេខ១៩៨៦ សង្កាត់ភ្នំពេញថ្មី

-ចុះពិនិត្យសិប្បកម្មទឹកបរិសុទ្ធស្ថិតនៅភូមិច្រេស សង្កាត់ភ្នំពេញថ្មី(ម្ចាស់សិប្បកម្មឯកភាពកែសម្រួលបច្ចេកទេស)

-ចុះពិនិត្យអណ្តូងលូតាមបណ្តោយផ្លូវលេខ២០០២ ក្នុងនោះមាន០១អណ្តូងគ្មានគំរប និង០៣អណ្តូងមានការបាក់ស្រុតស្ថិតនៅសង្កាត់ទឹកថ្លា

-ចុះកាយបើកមុខទឹកក្នុងប្រឡាយទួលសំពៅបានចំនួន០២ទីតាំង និងស្តារកំប្លោកបិតមុខទឹកចំនួន០៣ទីតាំងស្ថិតនៅក្នុងសង្កាត់ក្រាំងធ្នង់

-ចុះពិនិត្យប្រព័ន្ធលូបង្ហូរទឹកស្ទះលិចផ្លូវ១៩៨៦ប្រវែង១២០ម៉ែត្រ(មិនទាន់បានធ្វើនៅឡើយ)

-ចុះស្តារកំប្លោកបិតមុខទឹកបានចំនួន០៣ទីតាំងស្ថិតនៅក្នុងសង្កាត់ក្រាំងធ្នង់។[៤៥]

### ១.២.២.ទិសដៅអភិវឌ្ឍន៍នៅថ្ងៃអនាគត

ជាទូទៅរាល់ការអភិវឌ្ឍន៍តែងតែមាននូវទិសដៅទុកជាមុន ដើម្បីត្រៀមក្នុងការអភិវឌ្ឍន៍ ការ

[៤៥] របាយការណ៍ប្រចាំឆ្នាំ២០១៦ ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលខណ្ឌសែនសុខ។

រៀបចំផែនការ ឬគម្រោងទុកជាមុន បែបនេះគឺងាយស្រួលដើម្បីឲ្យដំណើរការទៅបានល្អ ហើយគម្រោងនេះក៏មានសរសេរទុកនៅក្នុងសៀវភៅផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ។ ទិសដៅទៅថ្ងៃខាងមុខគឺមានទាំងគោលដៅ និងគោលបំណង ព្រមទាំងយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍន៍។

### ១.២.២.១.គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នៅថ្ងៃអនាគត

គោលដៅ និងយុទ្ធសាស្ត្រទៅថ្ងៃអនាគតគឺមានគម្រោងរំពឹងទុកថា និងអភិវឌ្ឍន៍ឲ្យបានល្អនៅឆ្នាំខាងមុខចំពោះវិស័យហេដ្ឋារចនាសម្ព័ន្ធ វិស័យអគ្គិសនី វិស័យទឹកស្អាត វិស័យដីធ្លី និងវិស័យសន្តិសុខសណ្តាប់ធ្នាប់។

### ក.ការអភិវឌ្ឍន៍លើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងការដឹកជញ្ជូន

គម្រោងការអភិវឌ្ឍន៍លើវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅឆ្នាំ២០១៩ខាងមុខ មានគោលដៅរំពឹងថានឹងសម្រេចបានលើការស្ថាបនាផ្លូវរួចពី៦០ភាគរយ ឡើងទៅ៧០ភាគរយ ដែលមានដូចជា ផ្លូវបេតុងឆ្អឹងដែក ការស្ថាបនាផ្លូវគ្រួសក្រហម ឬខ្សាច់ភ្នំ និងការស្ថាបនាប្រព័ន្ធលូផ្សេងៗ។ ការអភិវឌ្ឍន៍លើវិស័យនេះក្នុងគោលបំណងអភិវឌ្ឍន៍លើការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ ដាក់ភ្លើងបំភ្លឺផ្លូវសាធារណៈ ស្ពាន លូផ្សេងៗ និងលើកកម្ពស់ការដឹកជញ្ជូនប្រកបដោយសុវត្ថិភាព និងពង្រឹងការផ្តល់សេវាយានយន្តឲ្យមានប្រសិទ្ធភាព។ រីឯយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍លើវិស័យនេះ គឺជាគន្លឹះដ៏សំខាន់សម្រាប់បង្កើនប្រសិទ្ធិភាពសេដ្ឋកិច្ច ជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្នុងជីវភាពរស់នៅ និងប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ដូច្នេះវិស័យហេដ្ឋារចនាសម្ព័ន្ធគឺជាតម្រូវការចាំបាច់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដោយត្រូវពង្រឹងការស្ថាបនានិងជួសជុលផ្លូវ លូ ស្ពាន ឲ្យមានគុណភាពនិងប្រសិទ្ធិភាពខ្ពស់។[៤៦]

### ខ.ការអភិវឌ្ឍន៍លើវិស័យអគ្គិសនី

ការរំពឹងទុកថានៅឆ្នាំ២០១៩ខាងមុខ ប្រជាពលរដ្ឋមានភ្លើងអគ្គិសនីរដ្ឋសម្រាប់ប្រើប្រាស់ ១០០ភាគរយ និងមានភ្លើងបំភ្លឺផ្លូវសាធារណៈបាន៥០ភាគរយ ដោយការតបណ្តាញអគ្គិសនី និងការដាក់បង្គោលភ្លើងបំភ្លឺតាមដងផ្លូវសាធារណៈ។ ការអភិវឌ្ឍន៍លើវិស័យអគ្គិសនីនេះក្នុងគោលបំណងជម្រុញការផ្គត់ផ្គង់អគ្គិសនីរដ្ឋឲ្យបានគ្រប់ទីកន្លែង និងដើម្បីឲ្យប្រជាពលរដ្ឋមានភ្លើងអគ្គិសនីរដ្ឋប្រើប្រាស់។ ម៉្យាងវិញទៀតដើម្បីសម្រេចឲ្យបាននូវគោលបំណងនេះ គឺមានយុទ្ធសាស្ត្រសម្រេច

---

[៤៦] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ របស់ខណ្ឌសែនសុខ (២០១៥-២០១៩)។

លើការអភិវឌ្ឍន៍វិស័យអគ្គីសនីនេះ ដោយលើកកម្ពស់លើការអភិវឌ្ឍន៍លើវិស័យថាមពលដើម្បីឲ្យប្រជាជនមានអគ្គីសនីប្រើប្រាស់គ្រប់ៗគ្នា។[៤៧]

**គ.ការអភិវឌ្ឍន៍លើវិស័យទឹកស្អាត និងអនាម័យ**

គោលដៅអភិវឌ្ឍន៍ទៅថ្ងៃអនាគត នៅក្នុងខណ្ឌសែនសុខឆ្នាំ២០១៩ខាងមុខ ប្រជាពលរដ្ឋប្រមាណ៩០ភាគរយ មានទឹកស្អាតប្រើប្រាស់ដោយមានការរៀបចំបណ្តាញទឹកស្អាត និងជីកអណ្តូងស្នប់ផ្សេងៗ។ ការអភិវឌ្ឍន៍លើវិស័យនេះ ក្នុងគោលបំណងឲ្យប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់ និងមានអនាម័យគ្រប់កន្លែង ដោយអនុវត្តន៍តាមផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ក្នុងការជម្រុញការផ្គត់ផ្គង់ទឹកស្អាតឲ្យដល់ប្រជាពលរដ្ឋ ហើយដើម្បីសម្រេចបាននូវគោលបំណងនេះគឺមានយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍លើវិស័យទឹកស្អាត ដោយជម្រុញការតបណ្តាញទឹកស្អាត សង់ និងជួសជុលអណ្តូងស្នប់ដើម្បីឲ្យប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់គ្រប់ៗគ្នា។[៤៨]

**ឃ.ការអភិវឌ្ឍន៍លើវិស័យដីធ្លី**

គោលដៅក្នុងការអភិវឌ្ឍន៍លើវិស័យដីធ្លីនៅឆ្នាំ២០១៩ខាងមុខ ប្រជាពលរដ្ឋប្រមាណ៥០ភាគរយ ទៅ៨០ភាគរយដែលមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ ដោយការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ និងការផ្សព្វផ្សាយច្បាប់ភូមិបាល។ ចំពោះការអភិវឌ្ឍន៍លើវិស័យដីធ្លីនេះក្នុងគោលបំណងរំពឹងថានឹងសម្រេចឲ្យបាន ដោយបង្កើនការគ្រប់គ្រងដីធ្លី និងរៀបចំនគរូបនីយកម្មឲ្យមានសុវត្ថិភាព ហើយថែមទាំងមានយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍លើវិស័យដីធ្លីនេះ ដោយធ្វើការផ្សព្វផ្សាយច្បាប់ភូមិ បាលឲ្យបានទូលំទូលាយ និងសារៈសំខាន់នៃការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិ រួមទាំងធ្វើការដោះស្រាយ និងសម្របសម្រួលទំនាស់ដីធ្លី។[៤៩]

**ង.ការអភិវឌ្ឍន៍លើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

ចំពោះគោលដៅអភិវឌ្ឍន៍លើវិស័យសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈទៅថ្ងៃអនាគត ដោយរំពឹងថានឹងសម្រេចបានក្នុងឆ្នាំ២០១៩ខាងមុខ ប្រជាពលរដ្ឋរស់នៅប្រកបដោយសុខសុវត្ថិភាព ដោយមានការៈ

+ពង្រឹងសកម្មភាពរក្សាសន្តិសុខសណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន

[៤៧] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ របស់ខណ្ឌសែនសុខ (២០១៥-២០១៩)។

[៤៨] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ របស់ខណ្ឌសែនសុខ (២០១៥-២០១៩)។

[៤៩] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ របស់ខណ្ឌសែនសុខ (២០១៥-២០១៩)។

+ទប់ស្កាត់ការចែកចាយ និងប្រើប្រាស់គ្រឿងញៀន

+បង្ក្រាបអំពើចោរកម្ម និងល្បែងស៊ីសងគ្រប់ប្រភេទ

+ពង្រឹងការប្រើប្រាស់អាវុធខុសច្បាប់

+ប្រមូលក្មេងទំនើងដើម្បីអប់រំ

+ពង្រឹងការងារគ្រប់គ្រងអ្នកស្នាក់នៅបណ្ដោះអាសន្ន

+សង់ ឬជួសជុលប៉ុស្តិ៍ប្រជាការពារ

+ពង្រឹងវិធានការការពារគ្រោះថ្នាក់ចរាចរ

+ការពង្រឹងសមត្ថភាពការពារទប់ទល់គ្រោះអគ្គីសនី។

ការអភិវឌ្ឍន៍លើវិស័យសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈក្នុងគោលបំណងបង្កើនការគ្រប់គ្រងសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈដើម្បីឲ្យប្រជាពលរដ្ឋរស់នៅប្រកបដោយសុវត្ថិភាព។ លើសពីនេះទៅទៀត ដើម្បីសម្រេចបាននូវគោលបំណងខាងលើគឺមានយុទ្ធសាស្ត្រមួយចំនួនដែលជាផែនការអភិវឌ្ឍន៍លើវិស័យសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈដូចជា៖

-ផ្សព្វផ្សាយច្បាប់ស្តីពីការជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន

-ពង្រឹងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន

-អនុវត្តន៍គោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាព

-រៀបចំសណ្ដាប់ធ្នាប់សាធារណៈ

-ជម្រុញការចុះធ្វើរដ្ឋបាលផ្សេងៗ។[៥០]

[៥០] សៀវភៅផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ របស់ខណ្ឌសែនសុខ (២០១៥-២០១៩)។

# ជំពូកទី២
# បរិស្ថាន
# ក្នុងខណ្ឌសែនសុខ

# ជំពូកទី២
# បរិស្ថានក្នុងខណ្ឌសែនសុខ

បរិស្ថាន ជាកត្តាមួយក្នុងការជម្រុញឲ្យមានការរៀបចំបានល្អផងដែរ បញ្ហាអំពីបរិស្ថានគឺប្រទេសនៅទូទាំងសាកលលោកទៅហើយដែលបានគិតគូរទៅលើបញ្ហាបរិស្ថានជាធំ ដូច្នេះក្នុងខណ្ឌសែនសុខ គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១២នៃរាជធានីភ្នំពេញរបស់ប្រទេសកម្ពុជាដែលខណ្ឌនេះក៏បានយកចិត្តទុកដាក់ទៅលើបញ្ហាបរិស្ថានផងដែរ។

ការប្រមូលសម្រាមជារៀងរាល់ថ្ងៃ គឺធានាការពារបាននូវគុណភាពទឹក ដី ខ្យល់ និងការគ្រប់គ្រងសំណល់រឹងរាវត្រឹមត្រូវធ្វើឲ្យបរិស្ថានរស់នៅបានល្អ។ ក៏ប៉ុន្តែសម្រាមនៅតែចោទជាបញ្ហាដោយមានការកកស្ទះកន្លែងមួយចំនួននៅសេសសល់តាមសំណង់មិនរៀបរយ ការទុកដាក់សម្រាមចោលរាយប៉ាយ រថយន្តចូលមិនរួច ផ្លូវតូចចង្អៀត មិនយល់ដឹងពីវិធីវែកញែកសម្រាម នៅមានទម្លាប់ចោលសម្រាមផ្តេសផ្តាសតាមប្រឡាយ ប្រជាពលរដ្ឋបញ្ចេញសម្រាមខុសជើងរថយន្តផ្សេងៗ។[៥១] មិនតែប៉ុណ្ណោះបញ្ហាទឹកល្អក់ ក៏ដូចជាបញ្ហាកាកសំណល់ផ្សេងៗដែលបានធ្វើឲ្យមានការប៉ះពាល់ទៅដល់បរិស្ថានយ៉ាងធ្ងន់ធ្ងរនោះក៏បណ្តាលមកពីគ្មានប្រព័ន្ធលូដោះទឹក បំពង់លូតូច បំពង់លូចាស់ ឬបំពង់លូបង្ហូរទឹកបាក់បែក លប់បឹង លប់ព្រែក រថយន្តដឹកសម្រាមមិនទាន់ពេលវេលា គ្មានទីតាំងដាក់សម្រាមផ្សេងៗ...។ ទាំងនេះសុទ្ធតែជាមូលហេតុជម្រុញឲ្យមានការរៀបចំដើម្បីទទួលបាននូវសោភ័ណ្ឌភាពល្អក្នុងរាជធានី ក្រុង ស្រុក ខណ្ឌ ឬតំបន់នានាថែមទៀត។

## ២.១.លក្ខណៈទូទៅទាក់ទងនឹងហេតុបង្កឲ្យមានការបំពុលបរិស្ថាន

កាលពី៦០ឆ្នាំកន្លងទៅ បរិស្ថានពុំសូវមានការបំពុលដូចបច្ចុប្បន្ននេះទេ ដោយសារមនុស្សប្រើប្រាស់សម្ភារៈដែលអាចរលាយបានច្រើនជាងសម្ភារៈមិនអាចរលាយ។[៥២] តួយ៉ាងនៅសម័យនេះនៅពេលដែលស្រុកទេសមានការអភិវឌ្ឍន៍ មនុស្សគ្រប់គ្នាតែងតែចង់ប្រើប្រាស់របស់ទាន់សម័យប្លែកៗដូចជា រថយន្ត ម៉ូតូ ទូរស័ព្ទ និងផលិតផលដែលផលិតឡើងដូចជាប្លាស្ទីចជាដើម។ ទាំងនេះហើយជាបញ្ហានៅពេលបច្ចុប្បន្ន ពីព្រោះថាពេលដែលឧបករណ៍ទាំងអស់នោះខូចពួកគេនឹងយកវាទៅចោលដោយសារថាផលិតផលទាំងនោះជាប្រភេទសំណល់ដែលមិនរលាយបាន វាត្រូវស្ថិតនៅក្នុងបរិស្ថានហើយសមាសភាពរបស់វាអាចធ្វើឲ្យមានការបំពុលដល់បរិស្ថាន។ ជាទូទៅមូលហេតុ

[៥១] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៦-២០១៨) របស់ខណ្ឌសែនសុខត្រង់ទំព័រទី៥។

[៥២] សៀវភៅណែនាំអប់រំអំពីបរិស្ថាន បោះពុម្ពលើកទី២ ឆ្នាំ២០០៧ ត្រង់ទំព័រ១២៦។

ដែលបង្កឲ្យមានការបំពុលបរិស្ថានអាចកើតមានច្រើនករណី ដែលធ្វើឲ្យមានការបំពុលដល់ទឹក ដី ខ្យល់ សំណល់រឹងរាវ និងសម្លេង។

**២.១.១.ការបំពុលទឹក ដី ខ្យល់**

ទាំងការបំពុលទឹក ដី ខ្យល់ គឺសុទ្ធសឹងតែកើតមកពីការទុកដាក់សម្រាមមិនបានល្អ កាលណាសម្រាមគរកាន់តែច្រើនឡើងៗដោយគ្មានអ្នកទុកដាក់ត្រឹមត្រូវ នោះវានឹងបណ្តាលឲ្យបំពុលដល់ទឹក ទឹកក្រោមដី លើដី ឬបរិយាកាសទាំងមូល។

**២.១.១.១.ការបំពុលទឹក**

ទឹកមានផលប្រយោជន៍ណាស់សម្រាប់ទ្រទ្រង់ជីវិតរបស់មនុស្ស សត្វ និងរុក្ខជាតិ។ ទឹកគឺជាចំណែកមួយ ដែលជម្រុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចឲ្យជឿនលឿនក្នុងវិស័យឧស្សាហកម្ម កសិកម្ម ទេសចរណ៍ គមនាគមន៍ និងតំបន់ទីក្រុង។ ប៉ុន្តែការលេចចេញនូវឥទ្ធិពលអវិជ្ជមានទៅលើគុណភាពបរិស្ថានបានបង្កឲ្យមានផលវិបាកដល់ជីវិតមនុស្ស សត្វ ដោយសារការប៉ះពាល់សារធាតុគីមីរាប់ម៉ឺនប្រភេទ រួមទាំងកាកសំណល់ដែលផ្ទុកជាតិពុលផ្សេងៗជាច្រើន។ ការបោះកាកសំណល់ លាមក ឬសម្រាមទៅតាមប្រព័ន្ធលូបង្ហូរទឹក ជាហេតុបង្កឲ្យបរិស្ថានទឹកត្រូវបានបំពុល។

ការបំពុលបរិស្ថានទឹក ជាសកម្មភាពទាំងឡាយណាដែលធ្វើឲ្យទឹកប្រើប្រាស់ខុសពីលក្ខណៈដើម។ ការបំពុលបរិស្ថានទឹកអាចជះឥទ្ធិពលអាក្រក់ដល់សោភ័ណ្ឌភាពបរិស្ថានអាស្រ័យទៅតាមកម្រិតនៃការបំពុល ភាគច្រើនមាននៅតាមទីកន្លែងសំខាន់ៗមួយចំនួន ដូចជារមណីយដ្ឋាន ទីក្រុង ទីប្រជុំជន ទឹកម្សាន្ត ទីសាធារណៈជាដើម។[៥៣]

ម្យ៉ាងទៀតបើតាមគេហទំព័រមួយទៀតគេបានឲ្យនិយមន័យនៃការបំពុលទឹក គឺជាសកម្មភាពមួយដែលធ្វើឲ្យប្រភពទឹកដូចជាសមុទ្រ ទន្លេ បឹងបួរ ស្ទឹង ព្រែក កខ្វក់គ្មានអនាម័យ ហើយភាគច្រើនទឹកកខ្វក់នេះកើតឡើងដោយមនុស្សតែម្តង នៅពេលគ្មានការតាមដានត្រួតពិនិត្យឲ្យបានត្រឹមត្រូវ។[៥៤]

**ក.មូលហេតុបង្កនៃការបំពុលទឹក**

ការបំពុលបរិស្ថានទឹក អាចកើតឡើងតាមរយៈមូលហេតុផ្សេងៗជាច្រើនដូចជា៖

-កត្តាមនុស្ស ទាក់ទងទៅនឹងមុខរបរអាជីវកម្មដែលប្រជាពលរដ្ឋប្រកបរាល់ថ្ងៃដូចជា វិស័យកសិកម្ម ការប្រើប្រាស់ជីគីមីបានបន្សល់ទុកនៅកាកសំណល់ ដោយសារការគ្រប់គ្រងមិនបាន

[៥៣] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

[៥៤] គេហទំព័រ www.cambo-report.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

ត្រឹមត្រូវតាមបច្ចេកទេស នាំឲ្យសំណល់អាចហូរធ្លាក់ចូលប្រឡាយទឹកដែលអាចបណ្តាលឲ្យបំពុលទឹក។ ចំណែកទឹកស្រះនៅតាមជនបទដែលថ្លា និងគ្មានក្លិនស្អុយ គឺបានប្រើសម្រាប់បរិភោគ និងងូត ប៉ុន្តែដោយសារតែមានការបង្ហូរកាកសំណល់ ឬក៏ភាពកខ្វក់ចេញពីរោងចក្រ ក៏ដូចជាកសិដ្ឋានផ្សេងៗ នោះនឹងអាចធ្វើឲ្យស្រះទឹកក្លាយជាកខ្វក់ទៅជាមានក្លិនស្អុយ។[៥៥]

-វិស័យទេសចរណ៍ ការធ្វើដំណើរកម្សាន្តទោះទៅតាមទូក កប៉ាល់ ឬកាណូត អ្នកដំណើរខ្លះក៏មានការបន្ទោរបង់តាមបង្គន់អនាម័យក្នុងយានជំនិះដែរ ប៉ុន្តែប្រសិនបើមិនបានរៀបចំឲ្យត្រឹមត្រូវទេលាមក និងកាកសំណល់ផ្សេងៗទៀតត្រូវធ្លាក់ទៅក្នុងទឹក។[៥៦] វាជាផ្នែកមួយដែលទាក់ទងទៅនឹងការបំពុលទឹកកាលណាបន្ទោរបង់គ្មានអនាម័យ គ្មានការទុកដាក់ត្រឹមត្រូវទេនោះ វាបណ្តាលឲ្យមានការបំពុលដល់បរិស្ថានទឹកជាក់ជាពុំខាន។

-ការទុកដាក់សម្រាម នៅក្នុងទីក្រុង ឬទីសាធារណៈ ការបោះចោលសម្រាម ឬកាកសំណល់ផ្សេងៗពាសវាលពាសកាល និងជូនកាលបោះចោលក្នុងទឹកថែមទៀតជាហេតុធ្វើឲ្យមានការបំពុលទឹក។[57] ជាឧទាហរណ៍ៈ តាមទន្លេ បឹងបួរ ស្ទឹង ព្រែកនានា បើសិនជាមានការបោះកាកសំណល់ផ្សេងៗចូលទៅក្នុងទឹកនោះ វានឹងកើតជាការបំពុលទឹកនាំឲ្យប៉ះពាល់ដល់សុខភាពមនុស្ស។

-អាកាសធាតុ សារធាតុនីជ្រូសែនមានទឹកភ្លៀង ហើយនៅពេលដែលទឹកភ្លៀងធ្លាក់ចូលក្នុងទឹកស្ទឹង ស្រះ ឬទន្លេ ក៏បានបំប្លែងទៅជាអាស៊ីតនីត្រាតដែលបង្កឲ្យគ្រោះថ្នាក់ និងបំផ្លាញដល់ជីវិតរុក្ខជាតិ ព្រមទាំងជីវចម្រុះដែលរស់នៅក្នុងទឹក ថែមទាំងបង្កឲ្យមនុស្សមានជម្ងឺផ្សេងៗបានតាមរយៈការបរិភោគទឹក។[៥៨]

## ខ.ផលប៉ះពាល់នៃការបំពុលទឹក

សកម្មភាពមួយចំនួនអាចធ្វើឲ្យមានការបំពុលបរិស្ថានទឹក ហើយបានជះឥទ្ធិពលដល់មនុស្ស សត្វ និងរុក្ខជាតិ។ ដូច្នេះវាបានឆ្លើយតបទៅវិញចំពោះការកង្វះនូវបច្ចេកវិទ្យាដែលសមស្របសម្រាប់សម្អាតកាកសំណល់រឹង ដែលបានកែច្នៃផលិតផលរួចក៏បានបង្ហូរចេញពីរោងចក្រទៅក្នុងប្រភពទឹក

[៥៥] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

[៥៦] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

[៥៧] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

[៥៨] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

តាមរយៈរោងចក្របោកគក់ រោងចក្រផលិតស្រាបៀរជាដើម។ ហើយសារធាតុពុល និងសារធាតុគីមីត្រូវបានបញ្ចេញជាមួយគ្នាទៅក្នុងទឹកនោះផងដែរ។

-ការបង្ហូរកាកសំណល់រាវចេញពីរោងចក្រឧស្សាហកម្ម កាកសំណល់ទាំងនោះមានផលប៉ះពាល់ច្រើនដល់ការរស់នៅរបស់មនុស្ស សត្វ រុក្ខជាតិ និងការបាត់បង់សេដ្ឋកិច្ចជាតិ។ ជាពិសេសសុខភាពរបស់មនុស្សតាមរយៈការបរិភោគទឹកមិនស្អាត និងកង្វះអនាម័យដែលនាំមកជាមួយនូវកាកសំណល់រាវ ហើយបានបង្កជាជម្ងឺផ្សេងៗជាញឹកញាប់។[៥៩] ដូច្នេះសំណល់ដែលបញ្ចេញចោលពីរោងចក្រនានាទៅក្នុងបឹង ស្ទឹង ទន្លេផ្សេងៗអាចបណ្តាលឲ្យមានការបំពុលទឹកដែលបង្កឲ្យមនុស្សឈឺផងដែរ។

-ការបង្ហូរកាកសំណល់ចេញពីលំនៅដ្ឋាន(ការបង្ហូរកាកសំណល់ចេញពីផ្ទះសម្បែង) តាមទីប្រជុំជននានា ឬពីផ្សារហូរទៅក្នុងថ្លុកផ្សេងៗដែលបង្កើតឲ្យមានទឹកស្អុយជាប្រចាំ និងកាកសំណល់ដែលនៅតាមដងផ្លូវរាយប៉ាយជាសាធារណៈមិនសមស្រប ទើបនៅពេលដែលមានភ្លៀងធ្លាក់បាននាំមកនូវកាកសំណល់ទាំងនោះហូរចូលទៅក្នុងទន្លេ។[៦០]

### គ.ការបំពុលទឹកក្នុងប្រទេសកម្ពុជា

ទឹកកខ្វក់មានផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពមនុស្ស។ មានមនុស្ស**១.២៣**ពាន់លាននាក់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មិនមានទឹកស្អាតសម្រាប់ប្រើប្រាស់ និងមនុស្ស**១.៤៧**ពាន់លាននាក់ទៀតមិនមានបង្គន់អនាម័យគ្រប់គ្រាន់សម្រាប់ប្រើប្រាស់។ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ទឹកកខ្វក់បានសម្លាប់មនុស្សយ៉ាងហោចណាស់**២៥**លាននាក់ជារៀងរាល់ឆ្នាំ ដែល៦០%នៃអ្នករងគ្រោះគឺជាកុមារ។ កង្វះទឹកស្អាតបរិភោគ គឺជាបញ្ហាចម្បងនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅជនបទមានទឹកនៅលើផ្ទៃដីដែរ ប៉ុន្តែទឹកទាំងនោះជាញឹកញាប់ត្រូវបានគេធ្វើឲ្យកខ្វក់ប្រើប្រាស់មិនកើត ហើយបណ្តាលឲ្យប្រជាជនមួយចំនួនធំត្រូវទទួលរងនូវគ្រោះថ្នាក់នៃជម្ងឺផ្សេងៗ ព្រោះតែផឹកទឹកមិនស្អាត។ គ្រោះថ្នាក់របស់ទឹកគឺត្រូវបានបង្កឡើងដោយសារធាតុគីមី អាសេនិច ឬនីត្រាត។ មិនមែនសារធាតុគីមីទាំងអស់នៅក្នុងទឹកសុទ្ធតែបង្កជាជម្ងឺនោះទេ ប៉ុន្តែសារធាតុខ្លះធ្វើឲ្យទឹកមាន

---

[៥៩] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

[៦០] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

រសជាតិមិនល្អ ជាហេតុធ្វើឲ្យមនុស្សឈប់ប្រើប្រាស់វា ឬបានប្តូរទៅប្រើប្រភពទឹកផ្សេងដែលមានសារធាតុគីមីតិចជាង។[៦១]

ជាការពិតខ្លាំងណាស់ផលប៉ះពាល់ដោយសារធាតុគីមី ជាធម្មតាមានកម្រិតខ្ពស់ ពីព្រោះសារធាតុទាំងនោះវាស្ថិតនៅយូរអង្វែង ហើយវាក៏ពិបាកកំចាត់ចេញជាហេតុធ្វើឲ្យកុមារ ចាស់ជរា និងមនុស្សទាំងឡាយណាដែលមានប្រព័ន្ធការពាររាងកាយខ្សោយ គឺប្រឈមមុខនឹងផលប៉ះពាល់ខ្លាំងជាងគេ។ នៅប្រទេសកម្ពុជា ប្រភពទឹកជាច្រើនត្រូវរងការបំពុលរួមមានទឹកទន្លេ ទឹកក្រោមដី និងទឹកភ្លៀង។

+ការបំពុលទឹកទន្លេ ឬស្ទឹង

នៅប្រទេសកម្ពុជាទឹកស្ទឹង និងទន្លេ គឺជាប្រភពទឹកកំពុងរងការបំពុលនៅពេលមនុស្សមិនបានយល់ដឹងពីផលប្រយោជន៍ទឹកស្អាតសម្រាប់ទ្រទ្រង់ជីវិត តាមរយៈសកម្មភាពខុសឆ្គងមួយចំនួនដូចជា៖

-ការបោះចោលកាកសំណល់ និងបន្ទោរបង់ពាសវាលពាសកាល

-ការសង់បង្គន់អនាម័យជិត ឬលើប្រភពទឹក

-ការសង់ផ្ទះ ឬភោជនីយដ្ឋាននានានៅលើទឹកដោយមិនមានប្រព័ន្ធគ្រប់គ្រងកាក-សំណល់ ឬលាមកត្រឹមត្រូវ

-ការលាងសម្អាតយានយន្ត ឬសត្វធាតុ និងការបោកគក់សំលៀកបំពាក់ជិតប្រភពទឹកប្រើប្រាស់

-កាបង្ហូរទឹកកខ្វក់តាមប្រព័ន្ធលូចូលទៅក្នុងបឹងបួរ ឬស្ទឹង និងទន្លេ

-ការដុត និងកប់កាកសំណល់នៅជិតស្ទឹង និងទន្លេ។[៦២]

សកម្មភាពទាំងនេះហើយដែលធ្វើឲ្យទឹកឆាប់រងទទួលនូវការបំពុល និងឈានដល់កង្វះទឹកស្អាតសម្រាប់បរិភោគ។

+ការបំពុលទឹកក្រោមដី

ទឹកក្រោមដីខ្លះមានការបំពុលកើតឡើងតាមធម្មជាតិរបស់វា។ ការហូរចូលទឹកប្រៃកើតឡើងនៅពេលទឹកសាបត្រូវបានគេបូមចេញពីស្រទាប់សិលា ពេលនោះទឹកប្រៃបានហូរពីសមុទ្រមកបំពេញ

---

៦១ សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៣) ត្រង់ទំព័រ៤៣ និង៤៤។

៦២ សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៣) ត្រង់ទំព័រ៤៤។

ទឹកសាបនៅក្នុងដីដែលបាត់បង់។ បញ្ហាបំពុលដ៏ធ្ងន់ធ្ងរបានកើតឡើងដោយសារតែសកម្មភាពរបស់មនុស្សដូចជាប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ការលាងសម្អាតរថយន្ត ទោចក្រយានយន្ត និងបោកគក់សំលៀកបំពាក់ ចំណែកឯការលេចធ្លាយនៃប្រព័ន្ធទឹកស្អុយ និងបង្គន់ក៏អាចបង្កឲ្យមានការបំពុលដល់ប្រភពទឹកក្រោមដីបាន។ គ្រោះថ្នាក់ដ៏ធំបំផុតចំពោះសុខភាព គឺចេញពីវត្តមាននៃសារធាតុអាសេនិចសរីរាង្គនៅតាមតំបន់មួយចំនួនដែលស្ថិតនៅបណ្តោយដងទន្លេសំខាន់ៗ។ បន្ទាប់ពីបរិភោគទឹកក្រោមដី(ទឹកអណ្តូង) ដែលមានជាតិអាសេនិចមួយរយៈមក អ្នកបរិភោគអាចនឹងកើតមានជម្ងឺម្យ៉ាងហៅថាអាលនីកូស៊ីសដែលអាចបណ្តាលឲ្យស្លាប់បាន។[៦៣]

+ការបំពុលទឹកភ្លៀង

មនុស្សភាគច្រើនតែងតែគិតថាទឹកភ្លៀងមានសុវត្ថិភាពសម្រាប់ផឹក។ តាមពិតវាមិនប្រាកដថាមានសុវត្ថិភាពគ្រប់ពេលនោះទេ ព្រោះនៅតាមតំបន់ដែលមានរោងចក្រឧស្សាហកម្ម មធ្យោបាយធ្វើដំណើរបែបទំនើប (រថយន្តទោចក្រយានយន្ត) និងគ្រឿងចក្រអាចបង្កឲ្យកើតមានភ្លៀងអាស៊ីតដែលជាប្រភពទឹកដ៏គ្រោះថ្នាក់ដល់សុខភាពមនុស្ស។[៦៤]

ជាការពិតខ្លាំងណាស់ថ្វីត្បិតតែទឹកភ្លៀងជាប្រភពទឹកស្អាតក៏ដោយ ប្រសិនបើប្រជាជនមិនបានប្រាកដថាទឹកដែលស្តុកទុកនោះស្អាតទេនោះវាប្រាកដជាប៉ះពាល់ដល់ខ្លួនជាក់ជាមិនខាន។

### ២.១.១.២.ការបំពុលដី

ជារៀងរាល់ឆ្នាំមនុស្សម្នាក់ៗ គឺបានបង្កើតនូវកាកសំណល់កាន់តែច្រើនឡើងៗ ប្រសិនបើកំណើនកាកសំណល់ពេលបច្ចុប្បន្ននៅតែបន្ត និងកាន់តែមានកាកសំណល់ច្រើនទ្វេរដង ប្រសិនបើប្រជាពលរដ្ឋមិនបានទុកដាក់ត្រឹមត្រូវវានឹងបង្កឲ្យមានការបំពុលបរិស្ថាន។ ការបំពុលដី គឺជាការធ្វើឲ្យដីមានភាពកខ្វក់ ហើយសម្រាមដែលចេញមកពីគ្រួសារនីមួយៗជាផ្នែកមួយដ៏សំខាន់នៃការបំពុលកាកសំណល់ទាំងអស់នេះ ត្រូវបានគេកប់ក្នុងរណ្តៅជាទីកន្លែងដែលគេស្គាល់ថាជាកន្លែងចោលសម្រាម។ ដូច្នេះកំណើនប្រជាជនកើនឡើង គំនរសម្រាមក៏កើនឡើងដែរគេប្រើដីកាន់តែច្រើនដើម្បីគរសម្រាមបន្តិចម្តងៗ កាកសំណល់ចាប់ផ្តើមរលួយប៉ុន្តែសម្រាម និងកាកសំណល់មួយចំនួនទៀតត្រូវប្រើរយៈពេលរាប់រយ ឬរាប់ពាន់ឆ្នាំទើបរលួយអស់។ ខណៈពេលដែលកាកសំណល់ទាំងអស់នេះរលួយវាបានបញ្ចេញជាកាបូនឌីអុកស៊ីត ឧស្ម័នមេតាននិងឧស្ម័នផ្ទះកញ្ចក់ដែលចូលរួមចំណែកធ្វើឲ្យ

[៦៣] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៣) ត្រង់ទំព័រ៤៥។

[៦៤] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៣) ត្រង់ទំព័រ៤៥។

កើនឡើងនូវកំដៅផែនដី មានវត្ថុធាតុជាច្រើនដែលផ្ទុកនូវសារជាតិពុលដូចជាអាគុយ ឬថ្មពិលអាស៊ីត ដែលបានបំពុលដី និងទឹកក្រោមដី។

+មូលហេតុនៃការបំពុលដីជាទូទៅឃើញមានកត្តាចំនួនបីគឺះ

-កត្តាកសិកម្ម

មូលហេតុនៃការបំពុលដីចំពោះវិស័យកសិកម្ម គឺភាគច្រើនទាក់ទងទៅនឹងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលមានសារជាតិគីមី។ នៅពេលដែលមានការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតហួសកម្រិតសម្រាប់ដាំដំណាំ ឬការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតច្រើនហួសហេតុ សារជាតិពុលទាំងនោះនឹងស្ថិតនៅក្នុងដីបង្កឲ្យមានការបំពុល និងធ្វើឲ្យដីនោះពោរពេញទៅដោយជាតិពុល។[៦៥]

-កត្តាមនុស្ស

នៅពេលដែលមនុស្សបោះសម្រាមចោលទៅលើដីហៅថា(ពង្រាយសម្រាម) ការពង្រាយសម្រាមនៅលើដីបណ្តាលឲ្យដីក្លាយជាកខ្វក់។ នៅពេលដែលសត្វទៅរកចំណីនៅក្នុងគំនរសម្រាមទាំងនោះវាក៏ទៅជាឈឺ ហើយបើមនុស្សចាប់សត្វទាំងនោះមកបរិភោគ ឬប៉ះពាល់សត្វនោះវានឹងបណ្តាលឲ្យទៅជាឈឺផងដែរ។ នៅពេលកប់កាកសំណល់ដែលមិនអាចរលាយទៅក្នុងដីច្រើនគឺបណ្តាលឲ្យមានការបំពុល ប្រភេទសំណល់ដែលមិនអាចរលាយបាន វាត្រូវចំណាយពេលយូរណាស់ទើបរលាយ ដូច្នេះមនុស្សមិនអាចប្រើប្រាស់ដីដែលកប់សម្រាមនោះសម្រាប់ដាំដំណាំ ឬយកទៅធ្វើជាលំនៅដ្ឋានបានទេ។[៦៦]

-កត្តាឧស្សាហកម្ម

កត្តានេះដែរភាគច្រើនគឺពាក់ព័ន្ធទៅនឹងរោងចក្រ ដែលបង្ហូរទឹកស្អុយទៅលើដី ឬទឹកដែលបង្កឲ្យមានការបំពុល ជាពិសេសឧស្សាហកម្មធន់ធ្ងន់ជាច្រើនដូចជា រោងចក្រផលិតសារជាតិគីមីលោហៈធាតុ និងក្រដាសជាដើម ផលិតផលទាំងអស់នេះ គឺសុទ្ធតែប៉ះពាល់ទៅដល់បរិស្ថាន។[៦៧]

សរុបមកវិញការបំពុលដី គឺជាបញ្ហាដែលបណ្តាលមកពីវិស័យកសិកម្ម ឧស្សាហកម្ម និងបណ្តាលមកពីប្រជាពលរដ្ឋគ្រប់រូប។

---

[៦៥] ដកស្រង់ចេញពី www.youtube.com (land pollution) ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧។

[៦៦] ដកស្រង់ចេញពី www.youtube.com (land pollution) ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧។

[៦៧] ដកស្រង់ចេញពី www.youtube.com (land pollution) ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧។

### ២.១.១.៣.ការបំពុលខ្យល់

ការបំពុលខ្យល់ ជាការបង្កើតឡើងដោយសារធាតុគីមី ឬជីវៈសរីរាង្គដែលបំផ្លាញ ឬបណ្តាលឲ្យមានផលប៉ះពាល់ដល់មនុស្ស ឬភាវៈមានជីវិតទាំងឡាយ និងបំផ្លាញដល់បរិស្ថានក្នុងបរិយាកាស។ បរិយាកាស គឺជាប្រព័ន្ធធម្មជាតិយ៉ាងរឹងមាំដែលទ្រទ្រង់រាល់ជីវិតមនុស្សសត្វនានានៅលើផែនដី។ ការបំផ្លាញស្រទាប់អូហ្សូន គឺជាការបំផ្លាញរនាំងការពារផែនដីពីកាំរស្មីអ៊ុលត្រាវីយ៉ូលេដែលបង្កផលវិបាកដល់ជីវិតលើផែនដី។ សរុបវិញមកការបំពុលខ្យល់ត្រូវបានចាត់ទុកថាជាការគំរាមកំហែងដល់មនុស្ស និងឋានប្រព័ន្ធនានានៅលើផែនដី។[៦៨] ជាការពិតការបំពុលខ្យល់គឺអាចធ្វើឲ្យអន្តរាយដល់មនុស្សនិងបរិស្ថាន ដែលការបំពុលនេះអាចជាកំទេចធូលីដី ឬឧស្ម័នមួយចំនួនដូចជា ឧស្ម័នកាបូនម៉ូណូអុកស៊ីតភាយចេញពីយានយន្ត ឬពពួកស៊ុលហ្វួរឌីអុកស៊ីតភាយពីរោងចក្រ។

#### ក.មូលហេតុនៃការបំពុលខ្យល់

ក្នុងប្រទេសកម្ពុជាការបំពុលខ្យល់ គឺជាបញ្ហាដែលកើតមានឡើងតាមមូលដ្ឋាន។ មានការសន្មត់ថាការបំភាយឧស្ម័នពីសកម្មភាពសង្គម សេដ្ឋកិច្ច ការសាងសង់ផ្លូវថ្នល់ ការដឹកជញ្ជូនតាមផ្លូវគោក ការប្រើប្រាស់ប្រេងឥន្ធនៈសម្រាប់ផលិតថាមពលឧស្សាហកម្ម និងការប្រើប្រាស់ឥន្ធនៈជីវម៉ាស គឺជាកត្តាធំៗដែលរួមចំណែកនាំឲ្យមានការបំពុលខ្យល់។[៦៩]

បញ្ហាគ្រប់គ្រងសម្រាមមិនបានល្អ គឺជាមូលហេតុចម្បងមួយក្នុងចំណោមបញ្ហាសំខាន់ៗដទៃទៀតដែលបង្កឲ្យមានការបំពុលខ្យល់ក្នុងកម្ពុជា តួយ៉ាងមានវិធីទុកដាក់សម្រាមសាមញ្ញពីរយ៉ាងគឺការដុតកាកសំណល់ និងការកប់កាកសំណល់ទៅក្នុងដីដែលប្រជាជនកម្ពុជានិយមអនុវត្ត។

+ការដុតកាកសំណល់

នៅក្នុងទីក្រុង និងទីប្រជុំជនភាគច្រើនការប្រមូលសម្រាមត្រូវបានដំណើរការដោយក្រុមហ៊ុនឯកជន។ បើសិនប្រជាជនចង់ឲ្យឡានដឹកសម្រាមយកទៅចាក់ចោលនៅកន្លែងផ្សេងៗ គេត្រូវតែបង់ប្រាក់ឲ្យក្រុមហ៊ុននោះ។ ជាទូទៅក្រុមហ៊ុនឯកជនប្រមូលតែសម្រាមតាមភោជនីយដ្ឋាន ហាងទំនិញ ទីផ្សារនានា។ ចំណែកឯអ្នកដែលមិនបានបង់ប្រាក់ថ្លៃប្រមូលសម្រាម ជាទូទៅគេដុតសម្រាមរបស់ពួកគេនៅទីវាលទំនេរជិតផ្ទះ។ ការដុតសម្រាម ក៏អាចបង្កទៅជាបញ្ហាធំផងដែរ នៅពេលដែលមនុស្សដុតសម្រាមប្លាស្ទិច ឬកញ្ចប់ប្រអប់បាយដែលធ្វើពីប្លាស្ទិចផ្សែងភាយឡើងទៅក្នុងអាកាស

[៦៨] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន (នាយកដ្ឋានបណ្តុះបណ្តាល និងរិក្រឹតការ ឆ្នាំ២០១៣) ត្រង់ទំព័រ៣៨។

[៦៩] គេហទំព័រក្រសួងមហាផ្ទៃ Ministry of interior (ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម Environmental and Social Management Framework ហៅកាត់ថា ESMF) ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧។

និងធ្វើឲ្យបរិយាកាសកខ្វក់ដោយសារធាតុគីមីផ្សេងៗ និងបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ផ្លូវដង្ហើម។ ម្យ៉ាងវិញទៀតនៅពេលដែលសម្រាមឆេះមិនអស់ វាបង្កឲ្យមានភ្លើងឆេះរីមៗមានផ្សែងច្រើនឡើងទៅបរិយាកាស ហើយផ្សែងពណ៌ខ្មៅដែលបញ្ចេញទៅក្នុងអាកាស គឺវាផ្សំឡើងពីភាគល្អិតតូចៗជាច្រើនលានដែលផ្សែងនោះជួនកាលអាចនៅក្នុងខ្យល់បានជាច្រើនម៉ោង។[៧០] សរបញ្ជាក់ផងដែរនៅពេលដែលផ្សែង និងឧស្ម័នគ្រោះថ្នាក់ផ្សេងៗបានភាយឡើងទៅក្នុងខ្យល់គឺវាអាចបណ្តាលឲ្យមានការបំពុលខ្យល់កើតឡើង នោះគឺបណ្តាលមកពីការដុតកាកសំណល់ផ្សេងៗ។

+ការកប់កាកសំណល់ទៅក្នុងដី

នៅតាមទីក្រុង និងទីប្រជុំជនភាគច្រើនមានរណ្តៅធំៗជាច្រើនកន្លែងសម្រាប់ទុកដាក់កាក-សំណល់ដែលមនុស្សបង្កើតឡើង។ មនុស្សជាច្រើនយល់ថាការកប់កាកសំណល់ទៅក្នុងដីគឺជាវិធីគ្រប់គ្រងសម្រាមដ៏ងាយមួយដោយពួកគេគិតថាគ្រាន់តែចាក់សម្រាមឲ្យពេញរណ្តៅ ហើយកាយដីកប់ជាការស្រេច។ ផ្ទុយមកវិញវាមិនមែនជាវិធីល្អទេ ការកប់សម្រាមទៅក្នុងដីមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន។[៧១] ទោះបីយកទៅកប់ដីក៏ដោយ ក៏វារលាយចូលទៅក្នុងដីតែក្រដាសប៉ុណ្ណោះចំណែកប្លាស្ទិចគឺវាមិនអាចរលាយបានឡើយ។ យ៉ាងណាមិញការគ្រប់គ្រងសម្រាមមិនបានល្អវាអាចបង្កឲ្យមានក្លិនមិនល្អ និងមានដីហុយថែមទៀតផង។

## ខ.ផលប៉ះពាល់នៃការបំពុលខ្យល់

អង្គការសុខភាពពិភពលោកថ្លែងថា មានមនុស្ស**២លាន៤សែន**នាក់បានស្លាប់រៀងរាល់ឆ្នាំតាមរយៈការទទួលរងឥទ្ធិពលដោយផ្ទាល់ពីការបំពុលខ្យល់ ហើយមនុស្សចំនួន**១.៥លាន**នាក់ស្លាប់ដោយសារការបំពុលខ្យល់នៅក្នុងអាគារ។ ទីក្រុងនានាជុំវិញពិភពលោកដែលមានការសាយភាយខ្យល់ពុលកម្រិតខ្ពស់ បង្កឲ្យកុមារមានផ្ទុកជម្ងឺហឺត រលាកសួត ជម្ងឺផ្លូវដង្ហើម និងមានអាត្រាកំណើនទារកទាប។[៧២] ម្យ៉ាងទៀតការសាយភាយនៃសារធាតុគីមីគឺងាយធ្វើឲ្យមនុស្សចាស់ និងកុមាររងគ្រោះកើតជម្ងឺដែលបណ្តាលមកការបំពុលហើយចំណែកឯអ្នកមានជម្ងឺបញ្ហាសួត ឬបេះដូងស្រាប់នោះប្រាកដជាគ្រោះថ្នាក់ធ្ងន់ថែមទៀត នេះដោយសារសកម្មភាពមនុស្សបញ្ចេញនូវខ្យល់ច្រើនប្រភេទដែលបង្កឲ្យមានជម្ងឺ។

---

[៧០] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៣) ត្រង់ទំព័រ៣៩។

[៧១] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៣) ត្រង់ទំព័រ៤០។

[៧២] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៣) ត្រង់ទំព័រ៣៨។

មិនតែប៉ុណ្ណោះ មានជម្ងឺជាច្រើនដែលបង្កឡើងដោយការបំពុលខ្យល់តែមិនមានបង្ហាញរោគសញ្ញាអ្វីសោះ។ ជម្ងឺទាំងនោះមានដូចជា រលាកទងសួតរ៉ាំរ៉ៃ រោគហឺត មហារីក បេះដូងដែលអាចកើតមានឡើងជាយថាហេតុចំពោះអ្នកដែលបានស្រូបយកខ្យល់ពុល។ ខ្យល់ពុលទាំងនោះមានដូចជា អូហ្សូន នីត្រូសែនអុកស៊ីត ស៊ុលហ្វួរឌីអុកស៊ីត ក៏បង្កឲ្យមានអន្តរាយដល់ឋានប្រព័ន្ធធម្មជាតិផងដែរ។[៧៣]

## គ.ការបំពុលខ្យល់នៅក្នុងលំនៅដ្ឋាន

ខ្យល់អាកាសដែលមនុស្សដកដង្ហើមស្រូបចូលក្នុងខ្លួនមិនមែនសុទ្ធតែបរិសុទ្ធនោះទេ។ ផ្សែងឧស្ម័ន និងសារជាតិពុលបានបំផ្លាញខ្យល់ដង្ហើមរបស់មនុស្ស គំរាមកំហែងដល់សុខភាពសារពាង្គ-កាយ។ មិនត្រឹមតែបំពុលក្នុងបរិស្ថានធម្មជាតិទេ ផ្សែងឧស្ម័ន និងសារធាតុពុលផ្សេងទៀតក៏អាចបំពុលលំនៅដ្ឋានបច្ចុប្បន្ននេះផងដែរ។ ផ្នែកខាងក្នុងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋក៏អាចទទួលរងការបំពុលដោយសារធាតុ និងឧស្ម័នបំពុលជាច្រើន ពិសេសនៅលំនៅដ្ឋានតាមទីក្រុងដែលបិទជិតពេកខ្យល់អាកាសពោរពេញទៅដោយសារធាតុពុល បរិយាកាសយ៉ាងគ្រោះថ្នាក់នៅច្រាស់ច្រាលវិលវល់ចេញមិនរួច។

ឧស្ម័នពុលនៅក្នុងលំនៅដ្ឋានដែលប្រទះឃើញជាញឹកញាប់មានដូចជាៈ

-ផ្សែងបារី មានផ្ទុកទៅដោយសារធាតុបំពុល ដែលធ្វើឲ្យប៉ះពាល់ដល់សុខភាពជាខ្លាំង ដូចជាកាបូនម៉ូណូអុកស៊ីត ជាតិគួជ្រុង ជាតិនីកូទីនជាដើម។[៧៤] មនុស្សដែលបានជក់បារី គឺងាយនឹងកើតជម្ងឺមហារីក ដោយការស្រូបយកផ្សែងពុលដែលមាននៅក្នុងបារីនោះ។ ម៉្យាងវិញទៀតការបំពុលដោយផ្សែងរបស់អ្នកជក់បារីនេះទៀតសោតក៏បានធ្វើឲ្យប៉ះពាល់ដល់អ្នកនៅជុំវិញខ្លួនថែមទៀត។

ជាឧទាហរណ៍ៈ បុគ្គលម្នាក់រស់នៅជាមួយបងប្អូនបង្កើត៤នាក់ សរុបទាំងគាត់គឺមាន៥នាក់ បុគ្គលម្នាក់ក្នុងចំណោម៥នាក់ដែលជាបងប្អូនបង្កើត គឺគេបានជក់បារីដោយការបំពុលផ្សែងរបស់ម្នាក់នោះគឺមិនត្រឹមតែប៉ះពាល់ដល់ខ្លួនឯងទេ គឺថែមទាំងបានធ្វើឲ្យបំពុលដល់មនុស្ស៤នាក់ដែលរស់នៅក្រោមដំបូលជាមួយគ្នាទៀតផង។

-ឧស្ម័នរ៉ាដុង ដែលបែកចេញពីជាតិអ៊ុយរ៉ានីញ៉ូម មិនបង្កជាគ្រោះថ្នាក់ទេបើវាមានបរិមាណតិចតួចបំផុតនោះ។ ជាតិអ៊ុយរ៉ានីញ៉ូមគឺឃើញមាននៅក្នុងដី ពោលគឺវាមាននៅក្នុងគ្រឿងសំណង់

---

[៧៣] សៀវភៅអប់រំបំណិនជីវិតស្តីពីបរិស្ថាន (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៣) ត្រង់ទំព័រ៣៨។

[៧៤] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

មួយចំនួនដូចជាឥដ្ឋបេតុងដើម។ ជាតិអ៊ុយរ៉ានីញ៉ូមនេះមានពាសពេញបរិយាកាស តែនៅក្នុងលំនៅដ្ឋានវាអាចប្រមូលផ្តុំបង្កកំណើតអាត្រាកម្រិតខ្ពស់។ ឧស្ម័នរ៉ាដុងបំបែកខ្លួនជាអាតូមវិទ្យុសកម្មដែលទៅភ្ជាប់ខ្លួននឹងកម្ទេចលំអងធូលីពេលដែលមនុស្សដកដង្ហើម បានស្រូបវាចូលទៅក្នុងខ្លួនវាបង្កជាជម្ងឺដំបៅសួត ជួនកាលបង្កជាជម្ងឺមហារីកបើការប្រឈមដដែលយូរអង្វែង។[៧៥] មិនតែប៉ុណ្ណោះការបំពុលទៅក្នុងបរិយាកាស និងក្នុងលំនៅដ្ឋានករណីដូចជាចង្ក្រានហ្គាសដែលបានបញ្ចេញនូវជាតិអាសូតអុកស៊ីត ជាតិកាបូនម៉ូណូអុកស៊ីតភាយចេញពីចង្ក្រាន ឬភាយពីឡដាំស្លរ និងជាតិអាមីញង់ដែលជាសារជាតិពុលផងដែរ។

**២.១.២.ការបំពុលសំណល់រឹង រាវ និងសម្លេង**

សំណល់មិនថាទោះជារឹង ឬរាវទេ គឺបណ្តាលមកពីមនុស្សដែលគ្មានការរៀបចំ ឬវែកញែកចំពោះសំណល់រឹងឬរាវឲ្យបានត្រឹមត្រូវ ជាហេតុធ្វើឲ្យមានការបំពុល ហើយនិងមានការកកស្ទះនៅពេលភ្លៀងធ្លាក់ថែមទៀត។ រីឯសម្លេងក៏ជាបញ្ហាប៉ះពាល់មួយផងដែរ កាលណាសម្លេងលឺខ្លាំងហួសកម្រិត វាបណ្តាលឲ្យប៉ះពាល់ដល់ការសិក្សាក៏ដូចជាការរស់នៅក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សទាំងអស់គ្នា។

**២.១.២.១.ការបំពុលសំណល់រឹង រាវ**

ជារៀងរាល់ថ្ងៃ គឺមានសម្រាមជាច្រើនដែលត្រូវបោះចោល ទោះជាសម្រាមប្រភេទណាក៏ដោយ ការដែលទុកដាក់សម្រាមមិនបានល្អ វាអាចធ្វើឲ្យមានមេរោគនៅក្នុងសម្រាម ជាហេតុធ្វើឲ្យប៉ះពាល់ដល់ជីវិតមនុស្សរស់នៅ។ ការបំពុលដោយសំណល់គឺអាចធ្វើការបែងចែកជាពីរ ទីមួយគឺសំណល់រឹង ទីពីរគឺសំណល់រាវ។

**ក.សំណល់រឹង និងសំណល់រាវ**

+សំណល់រឹង គឺសំដៅដល់វត្ថុរឹង សារធាតុរឹងឬរាវ កម្ទេចកម្ទីរដែលលែងត្រូវការប្រើប្រាស់បោះបង់ចោល ឬត្រូវឲ្យបោះបង់ចោល។[៧៦]

+សំណល់រាវ សំដៅដល់វត្ថុរាវដែលបញ្ចេញពីប្រភពបំពុលហូរចូលទៅក្នុងតំបន់សាធារណៈ ឬហូរចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបីជាបានឬមិនបានធ្វើប្រតិកម្មក្តី។[៧៧] អាចនិយាយ

[៧៥] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

[៧៦] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧។

[៧៧] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧។

បានម៉្យាងទៀតថា សំណល់រាវគឺសំដៅដល់វត្ថុរាវដែលជាផលិតផល និងជាសារធាតុរួមផ្សំជាមួយនឹងសារធាតុរឹងខ្លះ ដែលត្រូវបានបោះចោលជាប្រចាំថ្ងៃទៅតាមប្រព័ន្ធលូទឹកស្អុយផ្សេងៗ។[៧៨] ទាំងសំណល់រឹង និងសំណល់រាវខាងលើនេះ ជាទូទៅគេធ្វើការបែងចែកជាច្រើនប្រភេទដូចជា៖

-សំណល់ទីក្រុង៖ សំដៅដល់សំណល់ដែលបញ្ចេញពីលំនៅដ្ឋានក្នុងនោះរួមមានសំណល់សរីរាង្គ ប្លាស្ទិច សម្រាម និងមានប្រភេទសម្រាមដែលបង្កឲ្យគ្រោះថ្នាក់។ អាចជាសំណល់ដែលសល់ពីភោជនីយដ្ឋាន ទីផ្សារ សណ្ឋាគារ សំណង់ រោងចក្រ មន្ទីរពេទ្យ...។[៧៩]

-សំណល់ឧស្សាហកម្ម៖ គឺជាសម្ភារៈដែលសល់ពីការផលិតមានលក្ខណៈប្រហាក់ប្រហែលនឹងសំណល់ទីក្រុងដែរ ប៉ុន្តែប្រភេទខ្លះផ្ទុកទៅដោយសារធាតុគីមី។[៨០] សំណល់រឹង ឬរាវវាអាចកើតមានឡើងពីរោងចក្របានបោះកាកសំណល់ ដោយការធ្វើប្រព្រឹត្តិកម្មទៅកាន់ប្រព័ន្ធលូបង្ហូរទឹកស្អុយ ឬដោយផ្ទាល់ទៅកាន់ស្រះផ្សេងៗ។

-សំណល់មន្ទីរពេទ្យ៖ គឺជាសំណល់ដែលសល់ពីផ្នែកវេជ្ជសាស្ត្រដូចជាស៊ីរ៉ាំង បង់រុំ និងសំណល់ផ្សេងៗជាច្រើនទៀតដែលសល់ពីការវះកាត់។[៨១]

-សំណល់ប្រកបដោយគ្រោះថ្នាក់៖ សំដៅដល់សារធាតុពុល ផ្ទុះ ឆេះ ឬធ្វើអុកស៊ីដកម្ម ព្រមទាំងសំណល់ដែលសល់ពីថ្នាំពុលកសិកម្ម ឧស្សាហកម្មគីមី ថ្នាំពេទ្យ លោហៈធាតុ...។[៨២]

-សំណល់ពីអាងប្រតិកម្ម៖ មានភក់ ផេះនៃឡដុតសំណល់ជាដើម។[៨៣] សរុបមកវិញសំណល់ខាងលើនេះសុទ្ធតែជាសំណល់ដែលបង្កើតឲ្យមានទាំងសំណល់រឹង និងសំណល់រាវមានន័យថាការគ្រប់គ្រងសម្រាម សំណល់រាវដែលហូរតាមប្រព័ន្ធលូធ្វើឲ្យប៉ះពាល់ដល់មនុស្សនិងបរិស្ថានជាខ្លាំងនេះដោយសារតែកាកសំណល់សម្អុយទាំងរឹង និងរាវដែលធ្វើឲ្យបំពុលដល់បរិយាកាស ទាំងអស់។

---

[៧៨] គេហទំព័រ Https://seylanote.wordpress.com ខែឧសភា ឆ្នាំ២០១៧។

[៧៩] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧។

[៨០] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧។

[៨១] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧។

[៨២] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧។

[៨៣] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧។

### ខ.ផលប៉ះពាល់

+ផលប៉ះពាល់ដល់មនុស្ស៖ មិនថាសំណល់រឹង ឬរាវទេប្រសិនបើមិនមានការគ្រប់គ្រងឲ្យល្អ វាធ្វើឲ្យប៉ះពាល់ដល់គុណភាពជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្ស ការចាក់ចោលសម្រាមមិនបានត្រឹមត្រូវវាអាចបង្កើតជាប្រភពចម្លងដល់ការរីករាលដាលនៃជម្ងឺផ្សេងៗជាច្រើនប្រភេទដូចជា ជម្ងឺគ្រុនពោះវៀន ជម្ងឺគ្រុនចាញ់...។[៩៤] មិនតែប៉ុណ្ណោះសារធាតុគីមីផ្សេងៗទៀតដែលបានមកពីសំណល់ឧស្សាហកម្ម និងសំណល់ដ៏ទៃទៀតគឺវាអាចស្រូបចូលក្នុងខ្លួនរបស់មនុស្សតាមរយៈការដកដង្ហើម ឬការបរិភោគ ឬការប៉ះពាល់វា។ មេរោគដែលបង្កដោយសម្រាម គឺអាចមានគ្រោះថ្នាក់ដល់ជីវិតមនុស្ស វាមិនត្រឹមតែអាចមានជម្ងឺរុំរ៉ៃ ឬមហារីកប៉ុណ្ណោះទេ វាអាចបណ្តាលឲ្យមនុស្សបាត់បង់ជីវិតបានថែមទៀតផង។

+ផលប៉ះពាល់ដល់បរិស្ថាន៖ ប្រសិនបើគ្រប់គ្រងសម្រាមមិនបានល្អទេនោះវានឹងនាំឲ្យប៉ះពាល់ដល់បរិស្ថាន ដល់សុខភាពមនុស្សដោយផ្ទាល់និងដោយប្រយោល។ ដោយផ្ទាល់មានដូចជាការបរិភោគចំណីអាហារ ឬហូបទឹក ឬសារធាតុផ្ទាល់ដែលបង្កឲ្យមានជម្ងឺ រីឯដោយប្រយោលវិញ គឺវាធ្វើឲ្យមានការបាត់បង់ធនធានទឹក ដី ខ្យល់ ដែលជាតម្រូវការដល់ការទ្រទ្រង់ការរស់នៅប្រចាំថ្ងៃរបស់មនុស្ស និងសត្វ។[៩៥]

+ផលប៉ះពាល់ដល់សេដ្ឋកិច្ច៖ បើសិនជាមានការបំពុលដោយសំណល់សម្រាមរឹងក្តី ឬរាវក្តី គឺធ្វើឲ្យមនុស្សមានជម្ងឺ ហើយធ្វើឲ្យប្រាក់ចំណូលថយចុះដោយការកើតឡើងនូវជម្ងឺផ្សេងៗ ណាមួយនាំឲ្យប៉ះពាល់ដល់ផលដំណាំកសិកម្ម និងវិស័យទេសចរណ៍ថែមទៀតផង។

#### ២.១.២.២.ការបំពុលសម្លេង

ជាញឹកញាប់ការបំពុលដោយសូរសម្លេង គឺជាបញ្ហាបរិស្ថានចម្បងនៅទីក្រុងដែលប្រមូលផ្តុំដោយរថយន្តផ្ទាល់ខ្លួន រថយន្តដឹកជញ្ជូន យន្តហោះ ស៊ីផ្លេ ស៊ីរ៉ែន តន្ត្រី រោងចក្រ និងឧបករណ៍បំពងសម្លេងជាច្រើនទៀត។ល។ សូរសម្លេងទាំងនេះអាចធ្វើឲ្យមានការហត់ហេវអស់កម្លាំងខាងផ្លូវចិត្ត ការមួម៉ៅ តប់ប្រមល់ និងការខូចខាតសោតវិញ្ញាណ...។

### ក.មូលហេតុបង្ក

មូលហេតុដែលបង្កឲ្យមានការបំពុលសម្លេង គឺកើតមានឡើងតាមគ្រប់រូបភាពក្នុងនោះមាន៖

---

[៩៤] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧។

[៩៥] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៧។

-សម្លេងយន្តហោះ

-សម្លេងស៊ីផ្លេនាពេលយប់

-រថយន្តដឹកជញ្ជូន រថយន្តដឹកដី

-រទេះភ្លើង ឬរថភ្លើង

-តន្ត្រី

-រោងចក្រ

-សម្ភារៈផ្ទះបាយ

-ក្លឹបខារ៉ាអូខេ

-ការរកស៊ីដោយផ្សារដែក

-ឈូសឈើ...។

កត្តាទាំងឡាយខាងលើនេះ គឺជាបញ្ហាដែលកើតមានសព្វថ្ងៃនេះមិនថាជាប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍នោះទេ។ តួយ៉ាងការបំពុលសម្លេងដូចលើកឡើងខាងលើវាជាបញ្ហាសំខាន់ដែលប្រទេសមួយចំនួនយកចិត្តទុកដាក់។ ម៉្យាងទៀតសូម្បីតែសម្លេងឧបករណ៍ប្រើប្រាស់នៅក្នុងផ្ទះក៏ចាត់ទុកជាបញ្ហាបង្កសម្លេងដែរ។ ដោយឡែកបញ្ហាទាំងនេះចំពោះប្រទេសកម្ពុជាវិញគឺមានតិចតួចបំផុតដែលសម្លេងទាំងអស់នោះមិនត្រូវបានកើតជាបញ្ហាធំដុំនោះទេ ក៏ដោយសារតែបច្ចុប្បន្ននេះប្រជាពលរដ្ឋមានការយល់ដឹងច្រើន ហើយសម្លេងដែលសព្វថ្ងៃគេចាត់ទុកជាបញ្ហានោះដូចជាការរកស៊ីដោយការផ្សារដែក ឈូសឈើ ក្លឹបខារ៉ាអូខេ រោងចក្រ ទាំងនេះគឺជាបញ្ហាដែលកម្ពុជាកំពុងជួប។ ឧទាហរណ៍ ក្រុងភ្នំពេញនៅប្រទេសកម្ពុជា គឺមានក្លឹបខារ៉ាអូខេច្រើន មានរោងចក្រច្រើន ដូច្នេះសម្លេងដែលចេញពីកន្លែងទាំងនោះវាមានរំញ័រ វាអាចបំពុលសម្លេងដល់អ្នកជិតខាងដែលរស់នៅទីនោះផងដែរ។

### ខ.ផលប៉ះពាល់នៃការបំពុលដោយសម្លេង

សម្លេងត្រូវបានក្លាយជាផ្នែកធម្មជាតិមួយនៃជីវិតប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ ផលប៉ះពាល់ការបំពុលដោយសារសម្លេងវាបានជះឥទ្ធិពលអាក្រក់ដល់យើងទាំងអស់គ្នាដូចជា៖

-មានភាពពិបាកក្នុងការរៀនសូត្រ ការបំពុលដោយសម្លេងនេះ គឺពិតជាផ្តល់ផលអាក្រក់ទាំងមនុស្សធំ ទាំងកុមារតូចៗ ដែលបានប្រឈមនឹងសម្លេងរំខានជាប្រចាំ និងមានបញ្ហាពិបាកក្នុងការសិក្សាដោយសារតែការបង្កឲ្យមានការបំពុលសម្លេងឡាន សម្លេងតន្ត្រី ឬយន្តហោះ។ល។

-រំខានដល់ដំណាក់កាលនៃការដេក ការបំពុលដោយសម្លេងក៏អាចប៉ះពាល់ផងដែរទៅដល់ការគេងរបស់មនុស្សទាំងអស់គ្នា។ ប្រសិនបើមនុស្សម្នាក់ៗមិនបានទទួលទានដំណេកឲ្យបានគ្រប់គ្រាន់ និងមានសុខភាពមិនល្អ នោះរាងកាយរបស់គេនឹងត្រូវទទួលរងនូវផលអវិជ្ជមាន។[៨៦]

-ហ៊ឹងត្រចៀក បញ្ហាមួយផ្សេងទៀតដែលបណ្តាលមកពីការបំពុលដោយសម្លេងនោះគឺការលាន់ស្នូរហ៊ឹងត្រចៀកដែលជាសម្លេងលាន់ឮង្វូងនៅក្នុងត្រចៀក។[៨៧] ការធ្វើឲ្យមានការឮស្នូរខ្លាំងៗបែបនេះវាបានជះឥទ្ធិពលដល់សុខភាពទូទៅរបស់មនុស្សបានដោយការលាន់ឮសម្លេងរំខាន។

-មានជម្ងឺលើសសម្ពាធឈាម ការបំពុលដោយសម្លេងអាចធ្វើឲ្យមនុស្សម្នាក់ឈានទៅរកការវិវត្តន៍ មាននូវជម្ងឺលើសសម្ពាធឈាម និងបញ្ហាផ្សេងៗរបស់បេះដូង។ ដូច្នេះការបំពុលនេះក៏អាចធ្វើឲ្យមនុស្សមួយចំនួនស្លាប់ផងដែរ។[៨៨]

-បំផ្លាញដល់ការចងចាំ វាអាចជះឥទ្ធិពលអាក្រក់ដល់ការចងចាំ និងសមត្ថភាពនៃញាណដឹងរបស់មនុស្សម្នាក់ៗ ជាពិសេសចំណុចនេះគឺផ្តល់ផលអាក្រក់ចំពោះកុមារដែលមានសមត្ថភាពនៃការរៀនសូត្រចុះខ្សោយដោយសារតែការបំពុលសម្លេងនេះ។[៨៩]

## ២.២.បរិស្ថានក្នុងខណ្ឌសែនសុខ

រាជធានីភ្នំពេញមានខណ្ឌចំនួន១២ ក្នុងនោះគឺមានខណ្ឌមួយឈ្មោះថាខណ្ឌសែនសុខ ខណ្ឌនេះមានចំនួនប្រជាជននៅចុងឆ្នាំ២០១៦គឺ**១៥៤.៧២៨**នាក់។[៩០] ដូច្នេះរាល់កាកសំណល់របស់បុគ្គលម្នាក់ៗដែលពួកគេទុកដាក់ ឬបោះចោលនោះ គឺមានច្រើនណាស់ដែលជាហេតុធ្វើឲ្យប៉ះពាល់ដល់បរិស្ថានក្នុងខណ្ឌនេះ។

### ២.២.១.បណ្តាញខៀវ និងបណ្តាញបៃតង

ការរៀបចំបណ្តាញខៀវ និងបៃតង គឺជាផែនការយុទ្ធសាស្ត្រមួយ ដើម្បីស្តារការអភិវឌ្ឍន៍ឲ្យមានភាពស្រស់បំព្រង តាមរូបផ្ទៃទឹក និងដើមឈើ។ តាមរយៈនេះ គម្រោងជាច្រើនបានបង្ហាញឡើង

[៨៦] គេហទំព័របាយ័ន ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧។

[៨៧] គេហទំព័របាយ័ន ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧។

[៨៨] គេហទំព័របាយ័ន ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧។

[៨៩] គេហទំព័របាយ័ន ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧។

[៩០] តួរលេខនេះដកស្រង់ចេញពីរបាយការណ៍អនុវត្តន៍ការងារ របស់ខណ្ឌសែនសុខឆ្នាំ២០១៦។

ឆ្លុះបញ្ចាំងពីការរៀបចំបណ្តាញទាំងពីរ ទាំងនៅកណ្តាលក្រុង និងនៅជាយក្រុង។[៩១] បណ្តាញខៀវ និងបណ្តាញបៃតង គឺជាធាតុផ្សំមួយដែលមិនអាចខ្វះបានសម្រាប់ការរៀបចំ ប្លង់គោលដែលទាក់ទងនឹងការរៀបចំទេសភាពទីក្រុង ព្រោះវាមិនត្រឹមតែផ្តល់នូវសោភ័ណ្ឌភាពប៉ុណ្ណោះទេ វាថែមទាំងជួយស្រូបយកនូវសារធាតុពុលផ្សេងៗចេញពីបរិយាកាសបានថែមទៀត។

**២.២.១.១.បណ្តាញខៀវ**

បើក្រឡេកទៅមើលទីតាំងភូមិសាស្ត្ររបស់រាជធានីភ្នំពេញឃើញថា មិនត្រឹមតែមានទន្លេប៉ុណ្ណោះនោះទេ គឺនៅមានបឹង ស្ទឹងជាច្រើនទៀត។ នៅរាជធានីភ្នំពេញមានខណ្ឌជាច្រើនដែលព័ទ្ធជុំវិញទៅដោយបឹងខៀវស្រងាត់ ហើយអាចជួយទប់ស្កាត់មិនឲ្យមានទឹកជំនន់ជន់លិច ដោយសារបឹងគឺជាកន្លែងស្តុកទុកនូវទឹកភ្លៀងទាំងឡាយ ព្រោះតែភាពទន់ខ្សោយនៃប្រព័ន្ធលូរបស់ទីក្រុងទើបមិនអាចហូរទាន់ឡើយ។[៩២] ក្រៅពីនេះវាបានផ្តល់សម្រស់ផ្ទៃទឹកពណ៌ខៀវដែលបន្ថែមពីលើទេសភាពបៃតង ធ្វើឲ្យទីក្រុងមានលក្ខណៈធម្មជាតិ និងទាក់ទាញបំផុត។

**២.២.១.២.បណ្តាញបៃតង**

បណ្តាញបៃតង ក្រៅពីមានតួនាទីហែរហមជាមួយផ្ទៃពណ៌ខៀវ ពួកវាក៏បានចូលរួមក្នុងតំបន់កណ្តាលក្រុងដើម្បីលើកស្ទួយទេសភាពបៃតង ក្នុងនោះមានការពង្រីកការដាំដើមឈើជាជួរតាមបណ្តាវិថី និងទីលានលំហែរដែលការដាំនេះតម្រូវទៅនឹងប្រភេទផ្លូវនីមួយៗ ពោលគឺត្រូវសមាមាត្រទៅនឹងទំហំផ្លូវ។[៩៣] ម៉្យាងវិញទៀត ការដាំដើមឈើក៏ត្រូវជម្រុញផងដែរចំពោះការពង្រីក ដោយដាំដើមឈើឲ្យបានច្រើននៅតាមផ្ទះ តាមវិថី សួនច្បារ សាលារៀន មន្ទីរពេទ្យ ស្ថាប័នរដ្ឋ ឬទីកន្លែងណាមួយនោះទេ គឺត្រូវតែមានបណ្តាញបៃតងដើម្បីឲ្យមានភាពទាក់ទាញព្រោះថា កាលណាមានដើមឈើច្រើនវាជួយស្រូបយលឧស្ម័នកាបូនិច និងបញ្ចេញនូវឧស្ម័នអុកស៊ីសែន ហើយជួយលំអរតាមដងវិថីថែមទៀត។

សរុបមកវិញទាំងបណ្តាញខៀវ និងបណ្តាញបៃតង គឺត្រូវមានភាពបន្តមិនដាច់គ្នា និងស៊ីចង្វាក់គ្នា។ ភាពបន្តមិនដាច់គ្នាសំដៅដល់ភាពភ្ជាប់គ្នានៃធាតុខៀវនិងធាតុបៃតង ដើម្បីបង្កើតជាបណ្តាញខៀវ និងបៃតងដូចជា ការដាំដើមឈើ ការរក្សាទុកនូវទីវាលដំណាំ ការស្តារប្រឡាយ ការ

[៩១] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យ អ៊ុន សកក្កដា ឆ្នាំ២០១២ ត្រង់ទំព័រទី៥០។

[៩២] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យ អ៊ុន សកក្កដា ឆ្នាំ២០១២ ត្រង់ទំព័រទី៥២។

[៩៣] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យ អ៊ុន សកក្កដា ឆ្នាំ២០១២ ត្រង់ទំព័រទី៥៣។

ថែរក្សាបឹង រុក្ខជាតិ ឬដាំដើមឈើនៅតាមមាត់ទឹកឲ្យបានច្រើន...។[៥៩] ភាពបន្តមិនដាច់រវាងបណ្តាញខៀវ និងបណ្តាញបៃតងគឺមានសារៈសំខាន់ណាស់ ពីព្រោះវាជាផ្នែកមួយនៃការអភិវឌ្ឍន៍ទេសភាពទីក្រុង និងផ្តល់បរិយាកាសល្អដល់បរិស្ថានក្នុងការរស់នៅ ថែមទាំងធ្វើឲ្យវិស័យទេសចរណ៍មានការកើនឡើងជាលំដាប់។

### ២.២.២.វិធានការការពារទាក់ទងនឹងបរិស្ថាន

វិធានការដែលអាជ្ញាធរខណ្ឌសែនសុខអនុវត្ត ឃើញថាទទួលបាននូវលទ្ធផលដ៏គួរឲ្យកត់សម្គាល់ ព្រោះដោយសារតែអាជ្ញាធរខណ្ឌនេះ លោកបានចុះពិនិត្យក៏ដូចជាការសហការជាមួយក្រសួងបរិស្ថាន ដែលបានចុះពិនិត្យដោះស្រាយទៅលើការបំពុលផ្សេងៗ។ វិធានការដែលបានចុះអនុវត្តទាំងនោះមានដូចតទៅៈ

-ចុះពិនិត្យប្រភពបំពុលបរិស្ថាននៅតាមសិប្បកម្មអាជីវកម្ម សេវាកម្មបានចំនួន ១៥ទីតាំង

-ចុះណែនាំម្ចាស់ភោជនីយដ្ឋានឲ្យធ្វើការញែក វេចខ្ចប់ ទុកដាក់ និងបញ្ចេញសម្រាមទៅតាមពេលម៉ោងកំណត់បានចំនួន ០៣ទីតាំង

-បានចូលរួមជាមួយរដ្ឋបាលខណ្ឌ សង្កាត់ចុះដោះស្រាយពាក្យបណ្តឹងបទល្មើសបរិស្ថានជូនប្រជាពលរដ្ឋបានចំនន ០៨ទីតាំង

-ចូលរួមជាមួយមន្ទីរបរិស្ថាន រដ្ឋបាលខណ្ឌ សង្កាត់ ចុះត្រួតពិនិត្យទីតាំងដែលមន្ទីរបរិស្ថានដាក់លិខិតបញ្ជាឲ្យកែប្រែផ្ទះលេខ១៥B បុរីភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី

-បានសហការជាមួយមន្ទីរបរិស្ថាន អង្គការ WVC ក្រុមហ៊ុនស៊ីនទ្រី សង្កាត់ឃ្មួញ បើកវគ្គផ្សព្វផ្សាយចំណេះដឹងបរិស្ថាន និងធ្វើអនាម័យរើសសម្រាមតាមដងផ្លូវបានចំនួន ០៣វគ្គ ក្នុងភូមិសែនសុខទាំង៧ មានអ្នកចូលរួមចំនួន ៣៣២នាក់ (ប្រុស ៨៧នាក់)

-បានចូលរួមជាមួយលោកអភិបាលខណ្ឌ រដ្ឋបាលសង្កាត់ភ្នំពេញថ្មីចុះពិនិត្យទីតាំងសង្កាត់ភ្នំពេញថ្មីបានចំនួន ០១លើក

-បានចូលរួមជាមួយលោកអភិបាលខណ្ឌ រដ្ឋបាលសង្កាត់ភ្នំពេញថ្មី និងក្រុមហ៊ុនស៊ីនទ្រីបានធ្វើអនាម័យផ្លូវចំនួន ០៥លើក

-បានចុះពិនិត្យសកម្មភាពប្រមូលសម្រាមរបស់ក្រុមហ៊ុនស៊ីនទ្រីបានចំនួន ៨៣លើក

[៥៩] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យ អ៊ុន សកក្កដា ឆ្នាំ២០១២ ត្រង់ទំព័រទី៥៩។

-បានចូលរួមជាមួយក្រុមការងារមកពីសាលារាជធានីភ្នំពេញ មន្ទីរកសិកម្ម មន្ទីរបរិស្ថាន រដ្ឋបាលខណ្ឌ សង្កាត់ ចុះពិនិត្យទីតាំងសត្តឃាតជ្រូកបានចំនួន ០៤ទីតាំង ស្តុកចែកចាយជ្រូកបាន ចំនួន ០១ទីតាំង ស្តុកចែកចាយមាន់បានចំនួន ០២ទីតាំង

-បានដាំស្លាកប៉ាណូហាមចាក់សម្រាមអនុក្រឹត្យលេខ១១៣ បាន០១ផ្ទាំងនៅផ្លូវសម្តេចជាស៊ីម

-បានចូលរួមជាមួយមន្ទីរបរិស្ថានរាជធានីភ្នំពេញនិងរដ្ឋបាលសង្កាត់បានបើកវគ្គអប់រំចំណេះដឹងបរិស្ថានក្នុងសង្កាត់ចំនួន ០៣គឺសង្កាត់ភ្នំពេញថ្មី សង្កាត់ក្រាំងធ្នង់ និងសង្កាត់ឃ្មួញ ដែលមានអ្នកចូលរួមចំនួន ១៤០នាក់ (ស្រី ១៧នាក់)។[៩៥]

បើទោះជាមានការចុះពិនិត្យការបំពុលទឹក ដី ខ្យល់ សំណល់រឹងរាវផ្សេងៗក៏ពិតមែន ប៉ុន្តែបញ្ហានេះក៏នៅតែមាន នោះគឺបណ្តាលមកពីប្រជាពលរដ្ឋមួយចំនួនគាត់ខ្វះការយល់ដឹង ឬមានការយល់ដឹងហើយតែបែរជានៅតែប្រព្រឹត្តនូវអំពើទាំងនេះថែមទៀត។

### ២.២.៣.បញ្ហាប្រឈមក្នុងការអភិវឌ្ឍន៍បរិស្ថាន

បញ្ហាដែលបានជួបប្រទះក្នុងខណ្ឌនេះ គឺមានដូចជា៖

+បញ្ហាកាកសំណល់

-រថយន្តដឹកមិនទាន់

-ការទុកដាក់សម្រាមចោលគ្មានសណ្តាប់ធ្នាប់

-ផ្លូវតូចរថយន្តមិនអាចចូលដឹកដល់

-ខ្វះការយល់ដឹងពីការទុកដាក់សម្រាម

-គ្មានទីតាំងចោលត្រឹមត្រូវ។[៩៦]

ម៉្យាងវិញទៀត មិនត្រឹមតែបញ្ហាទាំងនេះទេ គឺនៅមានបញ្ហាជាច្រើនទៀតដូចជាការប្រើជីគីមី ការបង្ហូរទឹកស្អុយចូលក្នុងទន្លេរ បឹង ដោយមិនបានជ្រោះជាហេតុធ្វើឲ្យមានការបំពុលទឹក ដី ខ្យល់ សំណល់រឹងរាវផ្សេងៗ ដែលធ្វើឲ្យប៉ះពាល់ដល់មនុស្ស សត្វជាច្រើន។ រីឯសម្លេងគឺមិនសូវជាកើតមាននោះទេ។

ដូចនេះដើម្បីដោះស្រាយទៅនឹងបញ្ហាប្រឈមទាំងអស់នេះឲ្យទាន់សភាពការណ៍ គឺត្រូវរកដំណោះស្រាយឲ្យបានល្អកុំឲ្យមានការបំពុលដល់បរិស្ថាន។

---

[៩៥] របាយការណ៍អនុវត្តន៍ការងារខណ្ឌសែនសុខ ឆ្នាំ២០១៦ ត្រង់ទំព័រទី៣៣។

[៩៦] សៀវភៅអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ (២០១៥-២០១៩) របស់ខណ្ឌសែនសុខ។

## ២.៣.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលបរិស្ថាន

បន្ទាប់ពីបានដឹងពីមូលហេតុបង្ក និងផលប៉ះពាល់មួយចំនួនដូចរៀបរាប់ខាងលើក្នុងខណៈនេះនឹងធ្វើការឆ្លើយតបដោយការដោះស្រាយទៅនឹងការបំពុលទឹក ដី ខ្យល់ សំណល់រឹងរាវ និងសម្លេង ថាតើគួរមានដំណោះស្រាយដូចម្តេចខ្លះដើម្បីការពារ កាត់បន្ថយ ឬការលុបបំបាត់ការបំពុលទាំងនេះ។

### ២.៣.១.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលទឹក ដី ខ្យល់

ការបំពុល គឺបង្កើតឡើងដោយសកម្មភាពរបស់មនុស្ស ដូច្នេះមធ្យោបាយដែលមានប្រសិទ្ធិ-ភាពបំផុតគឺត្រូវឲ្យមនុស្សមានឥរិយាបថល្អចំពោះបរិស្ថាន ដោយមនុស្សជាអ្នកទទួលខុសត្រូវក្នុងការការពារគ្រប់គ្រងសំណល់ និងការបំពុលឲ្យបានល្អ។ មធ្យោបាយល្អបំផុតក្នុងការកាត់បន្ថយការបំពុល គឺត្រូវកាត់បន្ថយបរិមាណសម្រាមដែលបង្កើតឲ្យចុះតិច និងរៀបចំដំណោះស្រាយមួយចំនួនដើម្បីការពារ។

#### ២.៣.១.១.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលទឹក

ការត្រួតពិនិត្យទៅលើការបំពុលទឹក គឺទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹក ដើម្បីការពារដល់សុខភាពមនុស្ស។[៩៧] ការត្រួតពិនិត្យទៅតាមតំបន់ទឹកសាធារណៈ ជាការដោះស្រាយមួយដែលល្អដើម្បីធ្វើឲ្យបរិស្ថានគ្មានការបំពុលទឹកអ្វីដែលពិសេសនោះគឺជួយឲ្យមានសោភ័ណ្ឌភាព និងប្រកបដោយផាសុខភាពល្អក្នុងការរស់នៅប្រចាំថ្ងៃ។ មួយវិញទៀត ក្រសួងបរិស្ថានត្រូវរៀបចំកម្រិតកំណត់ស្តង់ដារបរិមាណសារធាតុពុលទាំងឡាយណា ដែលអាចអនុញ្ញាតឲ្យបញ្ចេញពីប្រភពបំពុលនានា។[៩៨] ជាឧទាហរណ៍៖ ការហាមឃាត់ចំពោះការបង្ហូរទឹកល្វចេញពីលំនៅដ្ឋាន ឬអាគារសាធារណៈចូលទៅក្នុងតំបន់ទឹកសាធារណៈដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសម្អាតដទៃទៀត។

វិធានការដោះស្រាយសំខាន់ៗដែលគួរតែអនុវត្តឲ្យបានមានដូចខាងក្រោម៖

-វិធានការសម្រាប់សាធារណៈ៖ គឺជាកត្តាចាំបាច់បំផុតដើម្បីសម្អាត និងអនាម័យទីក្រុងដោយជម្រុញជាលក្ខណៈអប់រំ តាមវិទ្យុ ទូរទស្សន៍ និងការបង្កើតទិវាបរិស្ថាន។[៩៩]

[៩៧] មាត្រា១ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩។

[៩៨] មាត្រា២ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩។

[៩៩] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

-វិធានការសម្រាប់រោងចក្រសហគ្រាសៈ មាននន័យថាគ្រប់រោងចក្រសហគ្រាស ឬក្រុមហ៊ុន គួរអនុវត្តការគ្រប់គ្រងកាកសំណល់ឲ្យបានល្អ ដោយមិនត្រូវបង្ហូរចូលទៅក្នុងប្រឡាយទឹកតាមរយៈការបង្កើតអាងស្តុកទុកកាកសំណល់រាវរបស់ខ្លួន។[១០០]

-វិធានការរៀបចំតាក់តែងច្បាប់ៈ គ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវរៀបចំផែនការឲ្យបានល្អច្បាស់លាស់សម្រាប់គ្រប់គ្រងសំណល់គ្រប់ប្រភេទ។ បច្ចុប្បន្ននេះ ការចែងពីបទបញ្ញត្តិបានចេញរួចហើយក៏ពិតមែន តែនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ដូច្នេះស្ថាប័នដែលត្រួតពិនិត្យនិងគ្រប់ម្ចាស់ដែលបំពុលទឹកត្រូវចូលរួមគោរព និងពង្រឹកច្បាប់នេះឲ្យបានប្រសើរឡើង។[១០១] ហេតុដូច្នេះ ដើម្បីឲ្យមានសោភ័ណ្ឌភាពទីក្រុង និងបរិស្ថានរស់នៅល្អ មនុស្សទាំងអស់គួរចូលរួមចំណែកដោយបំពេញភារៈកិច្ចក្នុងការកែប្រែបរិស្ថានទឹក។

### ២.៣.១.២.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលដី

អាចធ្វើការការពារដីដោយប្រើសម្ភារៈតិចតួច ប្រើប្រាស់វត្ថុដែលងាយរំលាយក្នុងរយៈពេលខ្លី និងសម្ភារៈដែលអាចប្រើប្រាស់ឡើងវិញបាន។ ៨០%នៃកាកសំណល់ដែលប្រមូលពីធុងសម្រាម ដូចជា កញ្ចប់ប្លាស្ទិច លោហៈធាតុ ក្រដាស់ជាដើម របស់ទាំងអស់នេះគឺសុទ្ធតែអាចកែច្នៃបាន។[១០២] មួយវិញទៀតមូលហេតុនៃការបំពុលដី គឺបណ្តាលមកពីកត្តាមនុស្ស កត្តាឧស្សាហកម្ម កត្តាកសិកម្ម ដូច្នេះគួរធ្វើការអប់រំដល់មនុស្សទាំងអស់ ដើម្បីឲ្យបានយល់ដឹងពីផលប៉ះពាល់ទាំងអស់នេះ រីឯកត្តាឧស្សាហកម្មគឺបណ្តាលមកពីរោងចក្រ ហេតុនេះគួរធ្វើការណែនាំពន្យល់ដល់ខាងរោងចក្រដើម្បីឲ្យពួកគេចូលរួមកាត់បន្ថយដល់ការបំពុលដី ចំណែកឯកត្តាកសិកម្មគឺត្រូវណែនាំឲ្យប្រជាពលរដ្ឋកាត់បន្ថយការប្រើជីគីមី និងថ្នាំសម្លាប់សត្វល្អិតហួសកម្រិតក្នុងការដាំដំណាំរបស់ខ្លួន។

### ២.៣.១.៣.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលខ្យល់

មានបច្ចេកវិទ្យាគ្រប់គ្រងការបំពុលខ្យល់ផ្សេងៗជាច្រើន និងផែនការយុទ្ធសាស្ត្រនានា ដើម្បីកាត់បន្ថយការបំពុលខ្យល់ពីមធ្យោបាយធ្វើដំណើរ និងគ្រឿងម៉ាស៊ីនចល័តមួយចំនួនរួមមានដូចជា បទបញ្ញត្តិតាមរយៈការលើកកម្ពស់ការប្រើប្រាស់ប្រេងឥន្ធនៈឲ្យមានប្រសិទ្ធិភាព ឬការប្រើប្រាស់

---

[១០០] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

[១០១] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១៧។

[១០២] ដកស្រង់ចេញពី www.youtube.com (land pollution) ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧។

រថយន្តដើរដោយអាគុយផង និងសាំងផង ឬក៏ប្តូរទៅប្រើប្រាស់អគ្គីសនីទាំងស្រុង ឬប្តូរទៅប្រើជីវៈឥន្ធនៈ ដូចជាអេតាណុល ជីវៈម៉ាស៊ូតជាដើម។

ដើម្បីកាត់បន្ថយការបំពុលខ្យល់ គឺត្រូវហាមឃាត់ជាដាច់ខាតនូវរាល់ការបញ្ចេញសារធាតុ-បំពុលទៅក្នុងបរិយាកាសណាដែលមិនឆ្លើយតបទៅតាមកម្រិតកំណត់ស្តង់ដារ។[១០៣] ការដែលបានបញ្ចេញនូវសារធាតុបំពុលទាំងនោះគឺវាអាចប៉ះពាល់ដល់ខ្យល់ ហើយនឹងធ្វើឲ្យខ្យល់នោះមានការបំពុលដូចជា ផ្សែងដែលបញ្ចេញពីឡដុត រោងចក្រផលិតលោហាធាតុ រោងចក្របេតុង រោងចក្រស៊ីម៉ង់ត៍ កំបោរ និងសារធាតុបំពុលដែលបញ្ចេញពីប្រភពដទៃទៀត។ ការកម្រិតស្តង់ដារនៃសារធាតុបំពុលដែលអនុញ្ញាតឲ្យបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស គឺមានការកម្រិតកំណត់យ៉ាងត្រឹមត្រូវ និងច្បាស់លាស់ជាទីបំផុត។ ឧទាហរណ៍៖ ឡដុត ឬរោងចក្រផលិតលោហាធាតុកម្រិតអតិបរមានៃការបញ្ចេញគឺ ៤០០mg/$m^3$។

ទោះបីជាយ៉ាងណាក៏ដោយ ក៏នូវមិនទាន់គ្រប់គ្រាន់ដែរមានន័យថា មិនត្រឹមតែធ្វើការកម្រិតស្តង់ដារការបំពុលប៉ុណ្ណោះទេ គឺត្រូវហាមឃាត់ចំពោះការនាំចូល និងការប្រើប្រាស់យានយន្តគ្រប់ប្រភេទដែលយានយន្តទាំងនោះបានបញ្ចេញសារធាតុពុល ហើយការកម្រិតនៃការបញ្ចេញឧស្ម័នពីប្រភពចល័តដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសម្លេង។ ខាងក្រោមនេះជាតារាងកម្រិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពចល័ត៖

| លរ | ប្រភេទយានយន្ត | ប្រភេទប្រេងឥន្ធនៈ | កម្រិតនៃការបញ្ចេញ | | | | |
|---|---|---|---|---|---|---|---|
| | | | CO (%) | | HC (ppm) | | ផ្សែងខ្មៅ% |
| | | | ក | ខ | ក | ខ | |
| ១ | ទោចក្រយានយន្តដែលមានចំហេះ២វគ្គ | ប្រេងសាំង | ៤,៥ | ៤ | ១០.០០០ | ៣០០០ | |
| ២ | ទោចក្រយានយន្តដែលមានចំហេះ៤វគ្គ | ប្រេងសាំង | ៤,៥ | ៤ | ១០.០០០ | ២៤០០ | |
| ៣ | យានយន្តគ្រប់ប្រភេទ | ប្រេងសាំង | ៤,៥ | ៤ | ១២០០ | ៨០០ | |
| ៤ | យានយន្តគ្រប់ប្រភេទ | ប្រេងសាំង | | | | | ៥០ |

[១០៣] មាត្រា៨ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសម្លេង ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ។

រីឯការនាំចូលផលិតនូវសារធាតុដែលមានស្ពាន់ធ័រ សំណរ បង់សែន និងសារធាតុអ៊ីដ្រូការប៊ូក៏ត្រូវបានកម្រិតផងដែរ។[១០៥] ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី៨នៃអនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសម្លេង បានលើកឡើងថាជាតិស្ពាន់ធ័រ សំណរ បង់សែន និងអ៊ីដ្រូការប៊ូប្រហើរដែលអនុញ្ញាតឲ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្មមានដូចតទៅ៖

| ល.រ | សារធាតុចំហេះ | ស្ពាន់ធ័រ(S) | សំណរ(Pb) | បង់សែន | អ៊ីដ្រូកាប៊ូប្រហើរ |
|---|---|---|---|---|---|
| ១ | ប្រេងខ្មៅ | ១,០% | | | |
| ២ | ប្រេងម៉ាស៊ូត | ០,២% | | | |
| ៣ | ប្រេងសាំង | | ០,១៥ក្រាម/L | ៣,៥% | ៥០% |
| ៨ | ធ្យូងថ្ម | ១,៥% | | | |

មិនតែប៉ុណ្ណោះការកម្រិតស្តង់ដារ និងការហាមឃាត់នេះដែរ គឺត្រូវធ្វើឲ្យបានជាដាច់ខាតដើម្បីចូលរួមការពារបរិស្ថាន។ តួយ៉ាងក៏ត្រូវមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋគ្រប់ៗរូប ដើម្បីចូលរួមដោះស្រាយនូវរាល់បញ្ហាកាកសំណល់ ក៏ដូចជាសម្រាមផ្សេងៗដែលបានជះឥទ្ធិពលដល់បរិស្ថានជាខ្លាំង។ មួយវិញទៀតសម្រាមជាបញ្ហាចោទមួយធំផងដែរ ដូច្នេះត្រូវមានការរៀបចំទុកដាក់ឲ្យបានត្រឹមត្រូវ ហើយដំណោះស្រាយចំពោះបញ្ហាដែលបានកើតឡើងសព្វថ្ងៃនេះគឺ៖

-បើសំណល់នោះមិនអាចកែច្នៃវាបានទេ ត្រូវរកកន្លែងទុកដាក់សម្រាមដោយញែកវាឲ្យដាច់ពីគ្នារវាងសំណល់រឹង និងរាវ។

-មុននឹងដុតត្រូវហាលវាឲ្យស្ងួត ព្រោះសម្រាមសើមអាចបង្កឲ្យមានផ្សែងច្រើន។

-ត្រូវជ្រើសរើសកន្លែងដុតសម្រាមនៅកន្លែងដីទួល ជៀសវាងទឹកលិចនៅរដូវភ្លៀង

-ករណីមួយទៀតគឺចំពោះកាកសំណល់ដែលមិនរលួយអាចកប់ប្រសើរជាងដុត ជៀសវាងការបង្កឲ្យមានផ្សែងបំពុលទៅក្នុងបរិយាកាស។

**២.៣.២.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលសំណល់រឹងរាវ និងសម្លេង**

ចំពោះបញ្ហាទាំងនេះ គឺនឹងធ្វើការបែងចែករវាងសំណល់រឹង សំណល់រាវ និងសម្លេង។ មានដំណោះស្រាយជាច្រើន នឹងធ្វើការបកស្រាយទៅតាមចំណុចនីមួយៗ។

[១០៥] មាត្រា១០ នៃអនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសម្លេង ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ។

### ២.៣.២.១.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលសំណល់រឹង រាវ

មនុស្សគ្រប់រូប សុទ្ធតែបានជ្រាបហើយថាការរាយប៉ាយនៃកាកសំណល់គ្រប់ប្រភេទអាចធ្វើឲ្យមានការប៉ះពាល់ជាច្រើនមកលើជីវភាពរស់នៅប្រចាំថ្ងៃរបស់អ្នករាល់គ្នា ដូចជាធ្វើឲ្យបាត់បង់នូវសោភ័ណ្ឌភាពរបស់ទីក្រុង បង្កភាពអាប់អួរដល់បរិយាកាសជុំវិញ ជាពិសេសបញ្ហាដល់សុខភាពថែមទៀតផង។ អាស្រ័យហេតុនេះទើបមាននូវយុទ្ធនាការអប់រំ និងច្បាប់ស្តីពីការគ្រប់គ្រងសំណល់ឲ្យបានត្រឹមត្រូវទៅតាមបច្ចេកទេស និងប្រកបដោយសុវត្ថិភាព។

ជាទូទៅចំពោះសំណល់ត្រូវបានធ្វើការបែងចែកយ៉ាងច្បាស់លាស់ ដាច់ពីគ្នារវាងសំណល់រឹង និងរាវ។

#### ក.សំណល់រឹង

សំណល់រឹងជាបញ្ហាមួយដែលរដ្ឋាភិបាលកំពុងតែប្រឈមមុខនឹងបញ្ហានេះ។ ប៉ុន្តែបច្ចុប្បន្ននេះសំណល់រឹងជាច្រើន ត្រូវបានគេយកមកកែច្នៃជាថ្មីសម្រាប់ប្រើប្រាស់ឡើងវិញ និងប្រើប្រាស់ក្នុងគោលដៅថ្មីផ្សេងទៀត។ ការកាត់បន្ថយសំណល់រឹង គឺគិតចាប់ពីសកម្មភាពរបស់មនុស្សម្នាក់ៗរហូតដល់ទូទាំងប្រទេស មានន័យថាមនុស្សទាំងអស់មិនត្រូវបោះចោល និងដុតសំណល់រឹងតាមដងផ្លូវសាធារណៈ កុំប្រើប្រាស់ផលិតផលដែលជាជាតិប្លាស្ទិច កែច្នៃឡើងវិញ និងជាពិសេសយកសំណល់រឹងទៅធ្វើជាជីកំប៉ុសសម្រាប់កសិកម្ម។

ឧទាហរណ៍១៖ លោហៈ កែវ ក្រដាស ដែលចេញពីសំណល់រឹងគឺអាចធ្វើការកែច្នៃដោយផ្លាស់ប្តូររូបធាតុហើយត្រឡប់ទៅដាក់ចូលក្នុងវិស័យសេដ្ឋកិច្ចវិញ ដោយរូបភាពជាផលិតផលថ្មី។

ឧទាហរណ៍២៖ សំណល់អាហារ រុក្ខជាតិ ក្រដាស យកទៅបំបែកធាតុឲ្យទៅជាផលិតផលសរីរាង្គ ហើយយកទៅប្រើប្រាស់ជាជីសម្រាប់កសិកម្ម ព្រោះវាសំបូរដោយសារធាតុចិញ្ចឹមជួយឲ្យរុក្ខជាតិដុះលូតលាស់បានល្អ។

មិនតែប៉ុណ្ណោះ ដើម្បីបង្ការ និងចៀសវាងឲ្យផុតពីជម្ងឺផ្សេងៗដែលបណ្តាលមកពីសម្រាមសំណល់រឹង គឺត្រូវមានដំណោះស្រាយក្នុងការទុកដាក់កុំឲ្យមេរោគចេញ ហើយទៅចម្លងដល់មនុស្សបាន។ ដំណោះស្រាយមានដូចតទៅ៖

+ប្រជាពលរដ្ឋ

-ត្រូវរៀបចំទីកន្លែងស្តុកសំណល់រឹង ឬសម្រាមបណ្តោះអាសន្នឲ្យបានសមស្រប និងមានរបៀប ដោយមិនបង្កឲ្យមានផលប៉ះពាល់ដល់ចរាចរ សុខភាពសាធារណៈ សោភ័ណ្ឌភាព និងសណ្តាប់ធ្នាប់សង្គម

-មិនត្រូវបោះចោលសម្រាមរឹងនៅតាមទីប្រជុំជន ទីសាធារណៈ ផ្សារ កន្លែងកម្សាន្ត និងតាមប្រព័ន្ធលូនោះទេ

-មុនពេលបោះចោលសម្រាម គប្បីត្រូវបែងចែកឲ្យបានជាមុនដូចជាប្រភេទសម្រាមចេញពីមន្ទីរពេទ្យ និងចេញពីលំនៅដ្ឋាន ព្រោះកាកសំណល់ដែលចេញពីមន្ទីរពេទ្យអាចចម្លងមេរោគ និងជម្ងឺបាន។[១០៥]

+ភារកិច្ចអង្គភាពទទួលបន្ទុកផ្នែកគ្រប់គ្រងសម្រាម

អង្គភាពត្រូវរៀបចំដាក់ស្លាកសញ្ញាហាមឃាត់ការបោះចោលសម្រាមរាយប៉ាយ ហើយត្រូវទុកដាក់សំណល់រឹងឲ្យបានត្រឹមត្រូវគ្រប់ទីកន្លែងដូចជាតំបន់ទីប្រជុំជន ទីកន្លែងសាធារណៈ និងតំបន់រោងចក្រសហគ្រាសជាដើម។

ចំពោះទីលានចាក់សម្រាមវិញ ត្រូវយកចិត្តទុកដាក់ប្រតិបត្តិការគ្រប់គ្រងទីលានឲ្យបានល្អចៀសវាងផលប៉ះពាល់ដែលអាចកើតមានឡើង ដោយធ្វើការយកចិត្តទុកដាក់នូវចំណុចដូចខាងក្រោម៖

-លើកទំនប់ព័ទ្ធជុំវិញទីលានចាក់សម្រាម ដើម្បីការពារទឹកជំនន់ហូរចូល និងហូរចេញទៅវិញនាំសារធាតុបំពុលទៅជាមួយ

-រៀបចំផ្លូវចូលទីលានដែលអាចចូលចាក់បានគ្រប់រដូវកាល និងបាតរណ្ដៅត្រូវរៀបចំប្រព័ន្ធការពារ។[១០៦]

មួយវិញទៀតចំពោះស្ថាប័នទទួលខុសត្រូវគឺក្រសួងបរិស្ថាន ដែលមានតួនាទីដឹកនាំ និងជម្រុញកិច្ចប្រតិបត្តិការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន មានភារកិច្ចដូចខាងក្រោម៖

-រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោល-ការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ

-ផ្ដល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ លើការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន

---

[១០៥] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៧។

[១០៦] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៧។

-ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារៈសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន

-គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីកែច្នៃសម្រាម សំណល់រឹងទីប្រជុំជន

-តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន។[១០៧]

## ខ.សំណល់រាវ

ចំពោះសំណល់រាវត្រូវហាមឃាត់ដាច់ខាតនូវរាល់ការចាក់ចោល ការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណា ដែលមិនបានអនុវត្តតាមកម្រិតស្តង់ដារនៃការបញ្ចេញសំណល់រាវដូចមានចែងក្នុងអនុក្រឹត្យស្តីពីត្រួតពិនិត្យការបំពុលទឹក។ មិនតែប៉ុណ្ណោះហាមនូវរាល់ការចាក់ចោល ឬការបង្ហូរចេញនូវសំណល់រាវពីប្រភពបំពុលណាមួយ ដែលមិនអនុវត្តទៅតាមកម្រិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវដូចមានចែងក្នុងមាត្រា៤និង៥នៃអនុក្រឹត្យនេះ។[១០៨] ក្រសួងបរិស្ថានត្រូវរៀបចំកម្រិតកំណត់ស្តង់ដារ បរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតឲ្យបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចម្រុះ។[១០៩] ម្យ៉ាងវិញទៀតម្ចាស់រោងចក្រត្រូវទទួលខុសត្រូវចំពោះការតម្លើងរោងចក្រប្រព្រឹត្តកម្មកាកសំណល់ និងការបោះចោលកាកសំណល់ដែលបានធ្វើប្រព្រឹត្តកម្មទៅកាន់លូបង្ហូរទឹកស្អុយ ឬដោយផ្ទាល់ទៅកាន់ស្រះទឹកសាធារណៈ ដើម្បីបំពេញតាមស្តង់ដារសំណល់រាវ។[១១០]

---

[១០៧] មាត្រា៥ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ។

[១០៨] មាត្រា៦ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩។ ។

[១០៩] មាត្រា៧ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩។ ។

[១១០] គេហទំព័រ JICA www.jicareport.jica.go.jp។

ប៉ុន្តែទោះជាមានអនុក្រឹត្យក៏ដោយ ក៏នូវមានចំណុចខ្វះខាតខ្លះៗផងដែរដូច្នេះគួរមានវិធានការដោះស្រាយដូចតទៅ៖

-ធ្វើវិសោធនកម្មអនុក្រឹត្យ ដើម្បីបំពេញបន្ថែមចំណុចខ្វះខាត និងរៀបចំពង្រាងច្បាប់ថ្មីដែលពុំទាន់មាន

-រៀបចំគោលនយោបាយជាតិសម្រាប់ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាន

-រៀបចំផែនការមេស្តីពីវិធានការចម្រុះនូវការគ្រប់គ្រងសំណល់រឹងប្រកបដោយនិរន្តភាព

-ពង្រឹងការអនុវត្តច្បាប់

-លើកកម្ពស់ការអនុវត្ត ដល់កម្មវិធីកែច្នៃ និងការប្រើប្រាស់ឡើងវិញនៃសំណល់ និងកម្មវិធីកាត់បន្ថយបរិមាណសំណល់

-ជម្រុញ និងលើកទឹកចិត្តដល់ការអនុវត្ត ដល់កម្មវិធីផលិតកម្មស្អាត

-បង្កើតទីលានចាក់សំណល់ប្រកបដោយបច្ចេកទេស និងមានអនាម័យ

-បង្កើនការអប់រំបរិស្ថានដល់អ្នកជាប់ពាក់ព័ន្ធទាំងអស់

-ពង្រឹងកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ ក៏ដូចជាអាជ្ញាធរមូលដ្ឋានដែរ។[១១១]

### ២.៣.២.២.ដំណោះស្រាយពាក់ព័ន្ធនឹងការបំពុលសម្លេង

វិធានការដោះស្រាយនោះ គឺត្រូវអប់រំដល់ប្រជាពលរដ្ឋឲ្យបានយល់នូវបញ្ហា ផលប៉ះពាល់ហើយនិងធ្វើការផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋដើម្បីកាត់បន្ថយនូវការបំពុលសម្លេង។ ការបញ្ចេញសម្លេងពីប្រភពយានយន្ត ទីតាំងផលិតកម្មផ្សេងៗ ឬតាមផ្ទះដែលបង្កឲ្យមានការបំពុលសម្លេងគឺត្រូវធ្វើការហាមឃាត់ឲ្យបាន។ ហើយគប្បីកម្រិតស្តង់ដារនៃការបញ្ចេញសម្លេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកម្រិតស្តង់ដារសម្លេងអតិបរមាសម្រាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន។[១១២]

ការបញ្ចេញសម្លេងពីប្រភពយានយន្ត វាបានបង្កឲ្យថ្លង់ដល់មនុស្សគ្រប់គ្នា ដូច្នេះកាលណាធ្វើការហាមឃាត់ដោយដាក់កម្រិតចំពោះការបញ្ចេញសម្លេងនោះ វានឹងជួយកាត់បន្ថយការបំពុលដោយសម្លេង។ តាមតំបន់ដូចជាមន្ទីរពេទ្យ សាលារៀន លំនៅដ្ឋានគឺត្រូវកម្រិតឲ្យមានជាដាច់ខាត ព្រោះថាទីនោះជាកន្លែងដែលសំខាន់ និងមិនត្រូវឲ្យប៉ះពាល់ឡើយ ហើយសម្លេងដែលបានអនុញ្ញាតនៅតំបន់សាធារណៈ ក៏ដូចជាលំនៅដ្ឋាន រោងចក្រ មន្ទីរពេទ្យនោះគឺត្រូវអនុវត្តទៅតាមការកំណត់

[១១១] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៧។

[១១២] មាត្រា៧ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសម្លេង ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០។

ស្តង់ដារអតិបរមាដែលអនុញ្ញាតឲ្យបញ្ចេញសម្លេង ដូចមានក្នុងតារាងឧបសម្ព័ន្ធទី៥, ៦ និង៧ នៃអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងសម្លេង។

សរុបជារួមមកវិញទាំងការបំពុលទឹក ដី ខ្យល់ សំណល់រឹងរាវ និងសម្លេងគឺត្រូវអនុវត្តនូវវិធានការធំៗមួយចំនួនទៀតដូចតទៅៈ

**+ការកែច្នៃ**

សំណល់ផ្សេងៗដែលលែងត្រូវការសម្រាប់កិច្ចការមួយ អាចមានប្រយោជន៍សម្រាប់កិច្ចការមួយផ្សេងទៀត។ សំណល់ដែលអាចកែច្នៃបាន ឬប្រើប្រាស់ឡើងវិញបាននោះគឺមាន ដែកថែប ដែកធម្មតា អាលុយមីញ៉ូម ទង់ដែង សំណល់ ដបប្លាស្ទិច ប្រេងម៉ាស៊ីន...។[១១៣]

**+ការប្រើប្រាស់ឡើងវិញ**

មនុស្សម្នាក់ៗអាចប្រើប្រាស់សំណល់ដែលបង្កើតដោយខ្លួនឯងបាន ដូចជាដបប្លាស្ទិចអាចយកវាទៅលាងសម្អាតដើម្បីទុកប្រើប្រាស់នៅថ្ងៃក្រោយ ជាជាងយកវាទៅបោះចោលទាំងវាអាចនៅប្រើប្រាស់បានម្តងទៀត។

**+សំណល់ដែលមិនអាចប្រើប្រាស់ឡើងវិញ**

សំណល់ខ្លះៗដូចជាប្លាស្ទិចដែលគ្របពីលើចំណីអាហារ ម្ជុលសឺរាំងចាក់ថ្នាំដូចជានៅតាមមន្ទីរពេទ្យ គឺតែងតែមានការប្រើប្រាស់វា ប៉ុន្តែរបស់ទាំងអស់នោះមិនអាចយកវាមកប្រើប្រាស់ឡើងវិញបានទេ ព្រោះវាអាចចម្លងនូវមេរោគពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបាន ហេតុដូច្នេះត្រូវតែមានការរៀបចំទុកដាក់ឲ្យបានត្រឹមត្រូវ និងប្រុងប្រយ័ត្នដើម្បីកុំឲ្យមានការបំពុលដល់បរិស្ថាន។[១១៤]

ដើម្បីការពារកុំឲ្យមានការបំពុលគួរគប្បីអនុវត្តតាមវិធីដូចខាងក្រោមៈ

-កាត់បន្ថយបរិមាណសំណល់ជារៀងរាល់ថ្ងៃឲ្យចុះតិច

-ព្យាយាមប្រើប្រាស់របស់ទាំងឡាយណាដែលអាចប្រើបានទៀត

-កែច្នៃឡើងវិញនូវរបស់ទាំងឡាយណាដែលនៅមានប្រយោជន៍

-បោះចោលតែសម្រាមណាដែលមិនអាចកែច្នៃ ឬប្រើប្រាស់ឡើងវិញម្តងទៀតបាន

-មិនត្រូវបោះចោលសម្រាមទៅក្នុងស្ទឹង លើថ្នល់ ឬនៅកន្លែងដែលមិនមែនជាធុងសម្រាម។

+ប្រយុទ្ធនឹងការបំពុល

[១១៣] សៀវភៅណែនាំអប់រំអំពីបរិស្ថាន បោះពុម្ពលើកទី២ ឆ្នាំ២០០៧ ត្រង់ទំព័រទី១៨២។

[១១៤] សៀវភៅណែនាំអប់រំអំពីបរិស្ថាន បោះពុម្ពលើកទី២ ឆ្នាំ២០០៧ ត្រង់ទំព័រទី១៨៣។

ការប្រយុទ្ធនេះមិនមែនជាភារកិច្ចរបស់រដ្ឋាភិបាលតែឯងទេ គឺប្រជាពលរដ្ឋគ្រប់រូបអាចធ្វើតាមកម្រិតរបស់ខ្លួនបាន ដោយមិនត្រូវបោះសម្រាមចោលពាសវាលពាសកាលនៅក្នុងធម្មជាតិឡើយ ត្រូវប្រើប្រាស់ផលិតផលគីមីដូចជា(ប្រេងម៉ាស៊ីន ឬអាស៊ីត)ចូលទៅក្នុងប្រឡាយទឹក បង្គន់ ធុងសម្រាម...ឡើយ។[១១៥]

**+ការរៀបចំផែនការប្រើប្រាស់ដីធ្លីឲ្យបានត្រឹមត្រូវ**

ការរៀបចំផែនការប្រើប្រាស់ដីធ្លីនៅតាមតំបន់នីមួយៗនៃខេត្ត ក្រុងមានសារៈសំខាន់ជាចាំបាច់ដែលត្រូវមាន ដើម្បីសណ្តាប់ធ្នាប់សាធារណៈ សោភ័ណ្ឌភាព និងរក្សាបាននូវការការពារសុខភាពមនុស្ស ការអភិរក្សជីវៈចម្រុះ និយាយជាទូទៅគឺលើកកម្ពស់គុណភាពបរិស្ថាន។ ម៉្យាងទៀតមិនថាខេត្ត-ក្រុងនីមួយៗត្រូវមានផែនការ ឬប្លង់ប្រើប្រាស់ដីធ្លីរបស់ខ្លួនឲ្យបានច្បាស់លាស់ និងត្រឹមត្រូវស្របតាមលក្ខណៈពិសេសនៃស្ថានភាពតំបន់នីមួយៗ ដោយធ្វើការបែងចែកឲ្យដាច់ពីគ្នាជាតំបន់សម្រាប់គោលដៅផ្សេងៗគ្នាដូចជា៖

-តំបន់ដែលត្រូវប្រើប្រាស់ ឬបម្រុងសម្រាប់វិស័យកសិកម្ម

-តំបន់ដែលសម្រាប់សកម្មភាពពាណិជ្ជកម្ម

-តំបន់សម្រាប់កសាង ឬសកម្មភាពរោងចក្រឧស្សាហាកម្ម

-តំបន់សម្រាប់សិប្បកម្ម និងតំបន់សម្រាប់វប្បធម៌ទេសចរណ៍

-តំបន់សម្រាប់ការពារធនធានធម្មជាតិ និងអភិរក្សរមណីយដ្ឋានបុរាណវិទ្យាប្រវត្តិសាស្ត្រ។[១១៦]

**+ការរៀបចំឲ្យមានផែនការបរិស្ថាន និងប្រព័ន្ធនៃការគ្រប់គ្រងបរិស្ថាន**

ផែនការបរិស្ថាន គឺជាផែនការសម្រាប់កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាព។ ផែនការបរិស្ថានត្រូវកំណត់ពីបញ្ហាបរិស្ថានសំខាន់ៗ និងបញ្ហាគ្រប់គ្រងធនធានធម្មជាតិសំខាន់ៗដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ផែនការបរិស្ថានក៏ត្រូវលើកឡើងផងដែរពីវិធានការ ឬយុទ្ធសាស្ត្រសម្រាប់ធានាការគ្រប់គ្រងបរិស្ថាន។ ផែនការបរិស្ថាននេះធ្វើឲ្យរដ្ឋមានសមត្ថភាពក្នុងការបន្ថយសម្ពាធ រវាងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិដែលទាមទារនូវការប្រើប្រាស់ធនធានធម្មជាតិ និងដីធ្លីដែលមាន និងសម្ពាធនៃកិច្ចការពារបរិស្ថាន។ ផែនការបរិស្ថាននេះក៏ជាគោលការណ៍ណែនាំមួយផងដែរដល់ក្រសួង ស្ថាប័ននានា ដល់ផ្នែកឯកជន និង

---

[១១៥] សៀវភៅស្វែងយល់អំពីបរិស្ថាន ដោយអង្គការ (SIPAR) បោះពុម្ពលើកទី៣។

[១១៦] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី១៨៤ និង១៨៥។

អង្គការនានាដែលមានការពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន ដើម្បីយកបញ្ហាឬកង្វល់ពីបរិស្ថាននេះដាក់បញ្ចូលទៅក្នុងគោលនយោបាយអភិវឌ្ឍន៍មូលដ្ឋានរបស់ជាតិ និងក្នុងគម្រោងវិនិយោគទុននានា។[១១៧]

**+ការអប់រំពីការយល់ដឹងបរិស្ថាន និងការចូលរួមពីសាធារណជនក្នុងកិច្ចការពារបរិស្ថាន**

ដើម្បីឲ្យកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាព និងប្រព្រឹត្តទៅបានដោយជោគជ័យ ក៏ដូចជាការអនុវត្តនូវផែនការបរិស្ថានជាតិ និងផែនការបរិស្ថានតំបន់ប្រកបដោយប្រសិទ្ធិភាពក្រសួងបរិស្ថាន បានជម្រុញលើកទឹកចិត្ត និងផ្តល់លទ្ធភាពឲ្យមានការចូលរួមពីសាធារណជនក្នុងកិច្ចការពារបរិស្ថាន។ ការចូលរួមពីសាធារណជននេះត្រូវមានតាំងពីថ្នាក់ជាតិរហូតដល់មូលដ្ឋាន ទោះជាក្នុងដំណាក់កាលនៃការធ្វើផែនការបរិស្ថាន និងរាល់ការធ្វើសេចក្តីសម្រេចលើគម្រោងផ្សេងៗដែលអាចមានផលប៉ះពាល់ដល់បរិស្ថាន ព្រោះថាបើមានការចូលរួមពីសាធារណ-ជន ឬប្រជាជនតាមមូលដ្ឋាន ប្រជាជនទាំងនោះអាចចូលរួមជាមតិយោបល់លើកជាបញ្ហាដំណោះស្រាយផ្សេងៗដែលអាចឲ្យអ្នកធ្វើសេចក្តីសម្រេចលើគម្រោងនានា។[១១៨]

**+ការវាយតម្លៃហេតុប៉ះពាល់ដល់បរិស្ថាន**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាឧបករណ៍របស់ជាតិ ឬជាវិធានការដ៏សំខាន់សម្រាប់ទប់ស្កាត់ និងបន្ថយនូវការបំពុលបរិស្ថានដែលកើតចេញមកពីគម្រោងវិនិយោគនានា ឬពីសកម្មភាពវិនិយោគនានាទាំងរបស់សាធារណៈ(រដ្ឋ) និងរបស់ឯកជនដែលបានស្នើឡើង ឬគម្រោងមានស្រាប់កំពុងដំណើរការ ដូចជាគម្រោងរបស់ក្រុមហ៊ុនឯកជន ក្រុមហ៊ុនចម្រុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ជាក្រសួងស្ថាប័នរដ្ឋ។ រាល់គម្រោងទាំងនេះត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានជាមុន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ ក្រៅពីនេះក៏តម្រូវឲ្យម្ចាស់ត្រូវមានវិធានការចាំបាច់ជាមុនដើម្បីទប់ស្កាត់ និងត្រួតពិនិត្យជាមុននូវរាល់មហន្តរាយ ឬការបំពុលបរិស្ថានណាមួយដែលអាចនឹងកើតឡើងដូចជាអគ្គីភ័យជាដើម។ លទ្ធផលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះគឺជារបាយ-ការណ៍មួយដែលផ្ទុកទៅដោយព័ត៌មានលំអិតនានាដែលបានមកពីការសិក្សា ឬការប៉ះពាល់ដល់បរិស្ថានដែលអាចនឹងកើតមានដូចជា ការប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី ការបំពុលទឹក ខ្យល់អាកាស

[១១៧] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី១៩០ និង១៩១។
[១១៨] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី១៩៤ និង១៩៥។

ផ្សេង...។ ការរំខានដោយសម្លេង ឬរំញ័រ កាកសំណល់រឹង និងសំណល់រាវ សម្រាមនានា សារធាតុវិទ្យុកម្ម សារធាតុគីមី។ល។[១១៩]

**+ការរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធការពារបរិស្ថាន**

ដើម្បីការពារកុំឲ្យមានការបំពុលបរិស្ថាន ដែលអាចកើតចេញពីប្រភពផ្សេងៗដូចជា ចេញពីយានយន្ត ផលិតកម្ម ឧស្សាហកម្ម រោងចក្រ សហគ្រាស សិប្បកម្ម លំនៅដ្ឋាន អាជីវកម្មនានា មន្ទីរ-ពេទ្យ សណ្ឋាគារ កន្លែងកសិដ្ឋាន ការដ្ឋានសាងសង់ ស្ថានីយ៍ស្តុកប្រេងឥន្ធនៈ ទីតាំងស្តុកសំណល់ កន្លែងសត្តឃាត ភោជនីយដ្ឋាន ទីផ្សារ រមណីយដ្ឋាន និងអាគាររដ្ឋបាលសាធារណៈ។ល។ គេចាំបាច់ត្រូវគិតគូរដល់ការអភិវឌ្ឍន៍ និងកសាងនូវហេដ្ឋារចនាសម្ព័ន្ធការពារការបំពុលបរិស្ថាន ដែលអាចនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពរបស់មនុស្ស សត្វ និងធនធានធម្មជាតិនានា។ យន្តការ និងហេដ្ឋារចនាសម្ព័ន្ធដែលគប្បីយកចិត្តទុកដាក់ក្នុងការការពារកុំឲ្យមានការបំពុលបរិស្ថាន នោះរួមមានដូចខាងក្រោម៖

-កម្រិតកំណត់ស្តង់ដារអតិបរមានៃការអនុញ្ញាតឲ្យបញ្ចេញសំណល់រាវសារធាតុបំពុល ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹក ឬលូសាធារណៈ

-ម្ចាស់សំណល់ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួនតាមលក្ខណៈបច្ចេកទេសសមស្រប និងមានសុវត្ថិភាព

-ការដឹកជញ្ជូន ឬសាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ដែលប្រភពពីរោងចក្រសហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន

-ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសម្អាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវមានការឯកភាពពីក្រសួងបរិស្ថានជាមុនសិន

-តម្រូវឲ្យម្ចាស់លំនៅដ្ឋាន និងអង្គភាពរដ្ឋបាលសាធារណៈដែលតាំងនៅក្នុងតំបន់គ្មានលូសាធារណៈរៀបចំប្រព័ន្ធច្រោះសម្អាតសំណល់រាវរបស់ខ្លួន

-ម្ចាស់រោងចក្រឧស្សាហកម្មសហគ្រាស ត្រូវរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងសំណល់គ្រោះថ្នាក់ ដូចជា ការកសាងអាងស្តុកទុកបណ្តោះអាសន្ន និងអាងប្រព្រឹត្តកម្មសម្អាតសំណល់រាវដែលបញ្ចេញ

[១១៩] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី១៨៦ និង១៨៧។

ពីខ្សែសង្វាក់ផលិតកម្មឲ្យបានត្រឹមត្រូវ តាមកម្រិតកំណត់ស្តង់ដារអតិបរមាមុនពេលបង្ហូរសំណល់រាវទាំងនេះទៅក្នុងប្រព័ន្ធលូសាធារណៈ

-ជាពិសេសម្ចាស់ឧស្សាហកម្ម ត្រូវបំពាក់នូវឧបករណ៍ត្រួតពិនិត្យការបំពុលបរិស្ថាន និងកសាងប្រព័ន្ធប្រព្រឹត្តកម្មសំណល់របស់ខ្លួនឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដើម្បីកាត់បន្ថយនូវការបំពុលខ្យល់ ទឹក និងសម្លេង ដែលកើតចេញពីសកម្មភាពឧស្សាហកម្មរបស់ខ្លួន

-ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវទទួលខុសត្រូវក្នុងការតម្លើង ឬបំពាក់ឧបករណ៍ច្រោះសម្អាតសារធាតុបំពុល និងឧបករណ៍សម្រាប់កាត់បន្ថយសម្លេង ដើម្បីឲ្យឆ្លើយតបទៅនឹងកម្រិតកំណត់ស្តង់ដារ និងត្រូវទទួលខុសត្រូវក្នុងការតម្លើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុលដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន

-វិធានការតឹងតែងបានជ្រើសរើសសម្រាប់អនុវត្តចំពោះអ្នកប្រព្រឹត្តល្មើស និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងច្បាប់បរិស្ថានដូចជា ក្រសួងបរិស្ថានត្រូវចេញបញ្ជាជាលាយលក្ខណ៍អក្សរតម្រូវឲ្យម្ចាស់កម្មសិទ្ធិធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ ឬក្នុងរយៈពេលណាមួយជាក់លាក់ ឬផ្អាកសកម្មភាពរបស់ខ្លួនរហូតដល់បទល្មើស នោះត្រូវបានកែប្រែ ឬលុបបំបាត់ការបំពុល (ការសម្អាត) ជាបន្ទាន់ ឬធ្វើការពិន័យអន្តរកាល និងឈានដល់ការធ្វើបណ្តឹងទៅតុលាការដើម្បីឲ្យផ្តន្ទាទោសដាក់ពន្ធនាគារតាមមាត្រា២១,២២,២៣ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ១៩៩៦។[១២០]

រួមសេចក្តីមកការបង្កើតឲ្យមាននូវហេដ្ឋារចនាសម្ព័ន្ធដើម្បីគ្រប់គ្រងបរិស្ថាន និងការអនុវត្តវិធានការដោះស្រាយ ដែលចាំបាច់ក្នុងការទប់ស្កាត់ការបំពុលបរិស្ថានដូចជា យន្តការពង្រឹងការគ្រប់គ្រងសំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់ ប្រកបដោយលក្ខណៈបច្ចេកទេស និងយន្តការទប់ស្កាត់ និងត្រួតពិនិត្យប្រភពបំពុលដែលបញ្ចេញសំណល់រាវចូលតំបន់ទឹកសាធារណៈ ឬលូសាធារណៈដោយមិនបានឆ្លងកាត់ប្រព័ន្ធច្រោះសម្អាតភាពកខ្វក់ ឬសារធាតុបំពុល នោះគឺមានសារៈសំខាន់ណាស់ដើម្បីធានាសុវត្ថិភាព គុណភាព បរិស្ថាន និងសុខភាពសាធារណៈ ជាពិសេសវាធ្វើឲ្យបរិស្ថានមានបរិយាកាសស្អាត និងថែរក្សាបាននូវសោភ័ណ្ឌភាព។

[១២០] សៀវភៅនីតិនគរូបនីយវិទ្យា របស់សាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ត្រង់ទំព័រទី១៩២, ១៩៣ និង១៩៤។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើឃើញថា ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានពិតជាមានសារៈសំខាន់ណាស់ដើម្បីធ្វើឲ្យទីក្រុងមានរបៀបរៀបរយ និងបរិស្ថានល្អ។ ដោយឡែកទោះបីជាមានការកសាង ឬការអភិវឌ្ឍន៍ពិតមែន ក៏វានៅតែមានការខ្វះខាតនៅឡើយ ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌសែនសុខក៏កំពុងជួបប្រទះដូចខណ្ឌដទៃទៀតដែរ មានន័យថាថ្វីត្បិតតែខណ្ឌនេះបានរៀបចំឲ្យមាននូវផ្លូវថ្នល់ លូទឹកស្អាត ទឹកស្អុយ សួនច្បារ បង្គោលភ្លើងបំភ្លឺផ្លូវ...ពិតមែនក៏ខណ្ឌនេះបានជួបប្រទះនូវបញ្ហាសណ្តាប់ធ្នាប់ និងបរិស្ថានផងដែរ។ ម៉្យាងទៀតទោះបីជាខណ្ឌសែនសុខមានការអភិវឌ្ឍន៍យ៉ាងច្រើនស្ទើរគ្រប់វិស័យក៏ពិតមែន ប៉ុន្តែឃើញថាការអភិវឌ្ឍន៍មួយចំនួនរបស់សាលាខណ្ឌនេះវាមិនទាន់ដូចនូវអ្វីដែលបានរំពឹងទុកឡើយ។ ជាក់ស្តែងបញ្ហាសណ្តាប់ និងបរិស្ថានគឺជាបញ្ហាដែលត្រូវយកចិត្តទុកដាក់បន្ថែមទៀតទៅលើការរៀបចំឲ្យមាននូវហេដ្ឋារចនាសម្ព័ន្ធ និងការកែប្រែ បរិស្ថានក្នុងខណ្ឌនេះឲ្យបានល្អលើសពីនេះទៀត។ ជាពិសេសការរៀបចំតាមដងផ្លូវដែលសព្វថ្ងៃនេះមានអាជីវករមួយចំនួនបានយកដងផ្លូវសាធារណៈ មកធ្វើការប្រកបរបរអាជីវកម្មផ្ទាល់ខ្លួនដែលធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់ការរៀបចំសណ្តាប់ធ្នាប់។ លើសពីនេះទៅទៀតឃើញថាការគ្រប់គ្រងសម្រាមមិនបានល្អ ក៏ធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ខណ្ឌនេះដែរ កាលណាមានភ្លៀងធ្លាក់ហើយសម្រាមរាយប៉ាយទុកដាក់មិនបានត្រឹមត្រូវ ជាហេតុធ្វើឲ្យមានការកកស្ទះប្រព័ន្ធលូបង្ហូរទឹក នឹងឈានទៅដល់ការលិចលង់តាមដងវិថីនានា ដែលធ្វើឲ្យពិបាកក្នុងការធ្វើដំណើរម្តងៗ។

មិនតែប៉ុណ្ណោះ ការសិក្សាស្វែងយល់ទៅលើប្រធានបទសារណា "**ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានក្នុងខណ្ឌសែនសុខ**" បានធ្វើឲ្យខ្ញុំទាំងពីរនាក់មានការយល់ដឹងពីផលប៉ះពាល់នៃការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថាន ហើយថែមទាំងយល់ដឹងពីផលប្រយោជន៍នៃការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានផងដែរ។ ផលប្រយោជន៍ដែលបានមកនោះធ្វើឲ្យខណ្ឌ ឬក្រុងនេះមានសោភ័ណ្ឌភាព មានរបៀបរៀបរយ គមនាគមន៍ខ្វាត់ខ្វែងគ្មានការបំពុលដែលធ្វើឲ្យខណ្ឌនេះមានភាពទាក់ទាញ និងមានការរីកចម្រើនស្ទើរគ្រប់វិស័យ។ មួយវិញទៀតគឺធ្វើឲ្យមាននូវសន្តិសុខសុវត្ថិភាព មានភាពស៊ីវិល័យ ឬភាពទាន់សម័យទៅនឹងសង្គមបច្ចុប្បន្ន។

សរុបសេចក្តីមកអាចសន្និដ្ឋានបានថា ការរៀបចំសណ្តាប់ធ្នាប់ និងបរិស្ថានគឺពិតជាមាននូវសារៈសំខាន់ខ្លាំងណាស់ ទោះបីជាក្នុងពេលនេះមិនទាន់ទទួលបានជោគជ័យទាំងស្រុងក៏ពិតមែន ប៉ុន្តែទៅថ្ងៃខាងមុខពិតជាទទួលបាននូវភាពជោគជ័យនេះជាក់ជាមិនខាន ព្រោះថាបើមានការចូលរួម

សហការគ្នារវាងរាជរដ្ឋាភិបាលក៏ដូចជាអាជ្ញាធររដ្ឋ ក្រសួង ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ និងបងប្អូនប្រជាពលរដ្ឋ នោះប្រាកដជាទទួលបាននូវទេសភាពស្រស់បំព្រង និងបរិយាកាសក្នុងការរស់នៅល្អប្រកបដោយផាសុខភាព និងភាពយូរអង្វែង។

# អនុសាសន៍

# អនុសាសន៍

យោងតាមការបកស្រាយខាងលើឃើញថា ខណ្ឌសែនសុខក៏មានបញ្ហាប្រឈមមួយចំនួនផងដែរ បញ្ហាដែលបានកើតឡើងនោះភាគច្រើនជារឿងដដែល ទោះបីជាមានការអភិវឌ្ឍន៍ខ្លះក៏ពិតមែន ប៉ុន្តែវានៅតែចោទជាបញ្ហាដែលប្រជាពលរដ្ឋចង់ឲ្យអាជ្ញាធរធ្វើការកែសម្រួលនូវបញ្ហាទាំងនេះដែលមានដូចជា ផ្លូវ លូ ការលក់ដូរគ្មានសណ្តាប់ធ្នាប់ អសន្តិសុខផ្សេងៗ។ ម៉្យាងវិញទៀត បញ្ហាកាកសំណល់ ឬសម្រាមវាជាបញ្ហាដែលកើតមានដែរ ព្រោះសម្រាមតាមដងផ្លូវ និងការទុកដាក់គ្មានសណ្តាប់ធ្នាប់ ដែលបានធ្វើឲ្យមានការបំពុលដល់បរិស្ថាន និងធ្វើឲ្យមានការកកស្ទះដល់ប្រព័ន្ធលូបង្ហូរទឹកផ្សេងៗ។ ដើម្បីដោះស្រាយនឹងបញ្ហាទាំងនេះ ខ្ញុំទាំងពីរសូមមានមតិយោបល់ដូចតទៅៈ

-សូមអំពាវនាវដល់អាជ្ញាធរគ្រប់ជាន់ថ្នាក់ សូមជួយយកចិត្តទុកដាក់ឲ្យបានខ្ពស់ទៅលើបញ្ហាទាំងអស់នេះដូចជា សន្តិសុខ សណ្តាប់ធ្នាប់ និងបន្ថែមការប្រុងប្រយ័ត្នចំពោះបញ្ហាចោរកម្ម ក្មេងទំនើង... និងត្រួតពិនិត្យពីបញ្ហាបរិស្ថាន ដើម្បីកុំឲ្យមានការបំពុលដល់បរិយាកាស។

-សូមអំពាវនាវដល់សាលារាជធានីភ្នំពេញ សូមឲ្យមានការផ្តល់នូវកញ្ចប់ថវិកាទៅដល់ខណ្ឌសែនសុខឲ្យបានគ្រប់គ្រាន់ ដើម្បីឲ្យខណ្ឌនេះមានការអភិវឌ្ឍន៍ក្នុងខណ្ឌរបស់ខ្លួន។

-សូមអំពាវនាវដល់ក្រសួងបរិស្ថាន សូមឲ្យមានការផ្តល់នូវមន្ត្រីជំនាញដើម្បីសហការជាមួយមន្ត្រីខណ្ឌសែនសុខ ក្នុងការដោះស្រាយនូវបញ្ហាបរិស្ថាន។

-សូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមឲ្យមានការអភិវឌ្ឍន៍លើបណ្តាវិថីឲ្យបានច្រើន ដែលប្រែក្លាយពីផ្លូវដីឲ្យទៅជាផ្លូវបេតុង ឬថ្នល់កៅស៊ូជាដើម ហើយក៏សំណូមពរផងដែរចំពោះប្រព័ន្ធលូសាធារណៈ សូមមេត្តារៀបចំឲ្យបានល្អ(ពីលូតូចឲ្យទៅជាលូធំវិញ) ព្រោះបញ្ហាស្ទះលូ ឬលូហូរមិនទាន់នេះជាបញ្ហាធំមិនថាក្នុងខណ្ឌសែនសុខ ឬក៏រាជធានីភ្នំពេញទាំងមូលឡើយ។ ដូច្នេះសូមរៀបចំឲ្យបានគ្រប់ទីកន្លែងទៅតាមស្តង់ដារដើម្បីជៀសវាងពីបញ្ហាកកស្ទះប្រព័ន្ធលូបង្ហូរទឹក ដែលបង្កឲ្យមានការជន់លិចផ្លូវ និងពិបាកធ្វើដំណើរ។

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ

## ១.លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ លេខ០៨/នស/៩៤, ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤
- អនុក្រឹត្យស្តីពី លិខិតអនុញ្ញាតសាងសង់លេខ៨៦ អនក្រ/បក ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ១៩៩៧
- អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលទឹក ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងសម្លេង ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០០០
- អនុក្រឹត្យស្តីពី ការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន ថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០១៥
- គោលនយោបាយជាតិស្តីពីលំនៅឋាន ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤

## ២.សៀវភៅ

- សៀវភៅ ប្រវត្តិសាស្ត្រខ្មែរ ភាគទី១ បោះពុម្ពលើកទី១ គ.ស១៩៧៣ ព.ស២៥១៧ ដោយសាស្ត្រាចារ្យ ត្រឹងងារ
- សៀវភៅ ណែនាំអប់រំអំពីបរិស្ថាន បោះពុម្ពលើកទី២ ឆ្នាំ២០០៧
- សៀវភៅ ស្វែងយល់អំពីបរិស្ថាន ដោយអង្គការ (SIPAR) បោះពុម្ពលើកទី៣
- សៀវភៅ នីតិនគរូបនីយវិទ្យា រៀបរៀងដោយសាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ឆ្នាំ ២០១២
- សៀវភៅ ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា ដោយបណ្ឌិតអូវ៉ឌី ឆ្នាំ២០១២
- សៀវភៅ អប់រំបំណិនជីវិតស្តីពីបរិស្ថាន(នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ២០១៣)
- សៀវភៅ ភូមិវិទ្យាសេដ្ឋកិច្ច និងមនុស្សនៃប្រទេសកម្ពុជា រៀបរៀងដោយសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៣-២០១៤
- សៀវភៅ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល (២០១៦-២០១៨) របស់ខណ្ឌសែនសុខ

- សៀវភៅផែនការអភិវឌ្ឍន៍សម្រាប់រយៈពេល៥ឆ្នាំ (២០១៥-២០១៩) របស់ខណ្ឌសែនសុខ

**៣.គេហទំព័រ**

- គេហទំព័ររបស់សាលារាជធានីភ្នំពេញ (www.phnompenh.gov.kh)
- គេហទំព័ររបស់ក្រសួងមហាផ្ទៃ Minisry of interio ( ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម Environmental and Social Management Framework ហៅកាត់ថា ESMF)
- គេហទំព័រសុខភាពកម្ពុជា (www.healthcambodia.com)
- គេហទំព័រ www.cambo-report.com
- គេហទំព័រ (www.geography.weebly.com)
- គេហទំព័រ www.youtube.com (Land pollution)
- គេហទំព័រ (https://Seylanote.wordpress.com)
- គេហទំព័របាយ័ន (www.bayon.com)
- គេហទំព័រទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (www.jicareport.jica.go.jp)

**៤.វចនានុក្រម**

- សម្តេចព្រសង្ឃរាជ ជួនណាត (កម្មវិធីវចនានុក្រមខ្មែរ v.៣.១)

**៥.ផ្សេងៗ**

- របាយការណ៍ អនុវត្តន៍ការងាររបស់ខណ្ឌសែនសុខ ឆ្នាំ២០១៦
- តារាងវចនាសម្ព័ន្ធគ្រប់គ្រង របស់សាលាខណ្ឌសែនសុខឆ្នាំ២០១៧

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១. ប្លង់ប្រាសាទ និងទីក្រុង
ឧបសម្ព័ន្ធទី២. ផែនទីក្រុងអង្គរ និងរាជធានីភ្នំពេញ
ឧបសម្ព័ន្ធទី៣. តារាងរចនាសម្ព័ន្ធខណ្ឌសែនសុខ
ឧបសម្ព័ន្ធទី៤. ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
ឧបសម្ព័ន្ធទី៥. អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក
ឧបសម្ព័ន្ធទី៦. អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង
ឧបសម្ព័ន្ធទី៧. អនុក្រឹត្យស្តីពីការគ្រប់គ្រងសម្រាម សំណល់រឹងទីប្រជុំជន

# ឧបសម្ព័ន្ធទី១

**រូបទី ១ ៖ ប្លង់រាជធានីភ្នំពេញទាំងមូល**



រូបទី ២ : ប្លង់កណ្តាលរាជធានី




រូបទី ៣ : ប្លង់ទីក្រុងបាត់ដំបងចាស់ និងគូរឡើងវិញឆ្នាំ២០០៤



## រូបទី ៤ : ប្លង់ទីក្រុងសៀមរាប



រូបទី ៥ : ប្លង់ប្រាសាទអង្គរវត្ត




រូបទី ៦ : ប្លង់ប្រាសាទនាគព័ន្ធ



រូបទី៧: លំនៅឋានដែលជាសំណង់ដ៏ប្រណិតត្រូវអភិរក្ស ថតឆ្នាំ ២០០៤



# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ




www.phnompenh.gov.kh
រក្សាសិទ្ធិ © copyright






ផែនទីប្លង់គោលអភិវឌ្ឍន៍រាជធានីភ្នំពេញ ឆ្នាំ២០៣៥
ប្លង់កំណត់តំបន់
KAB SROV
BOENG PONG PEAY
TOUL KORK
SAMRAONG
AEROPORT
CHAMCHAO
BOENG CHENG EK
TA KMAU
Nouveau port de PP 30km
0 2 4 6 km

# ឧបសម្ព័ន្ធទី៣

**លោក ម៉ឹល កុសល អភិបាល នៃគណៈអភិបាលខណ្ឌ**

ទទួលបន្ទុកដឹកនាំការងារទូទៅ និងដឹកនាំផ្ទាល់លើការងាររដ្ឋបាលទូទៅការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងកិច្ចការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**លោក ហោ ចាន់សារ៉ា**
**អភិបាលរងខណ្ឌ**

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- កិច្ចការព័ត៌មាន អប់រំ យុវជន និងកីឡា
- កិច្ចការវេទិកាសាធារណៈ
- កិច្ចការសិទ្ធិមនុស្ស
- អង្គការក្រៅរដ្ឋាភិបាល
- គណបក្សនយោបាយ សមាគម
- កិច្ចការស្ថិតិ និងអត្រានុកូលដ្ឋាន
- កិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ
- កិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កិច្ចការពាណិជ្ជកម្ម ឧស្សាហកម្ម រ៉ែ និងថាមពល
- កិច្ចការធនាគារ រតនាគារ
- ការងារពន្ធដារសាខាក្រុងគ្រួសនិងជ្រោយ
- កិច្ចការលទ្ធកម្ម
- ការងារគ្រប់គ្រងផ្ទះជួល
- ការងារគ្រប់គ្រងផ្សារ
- ការងារសិប្បកម្ម

**លោកស្រី ភ្នំ ខ្ជាវ**
**អភិបាលរងខណ្ឌ**

- ការិយាល័យផែនការ និងអភិវឌ្ឍ
- កិច្ចការផែនការ
- កិច្ចការវិនិយោគ
- កិច្ចការអភិវឌ្ឍន៍ជនបទ
- កិច្ចការគ្រប់គ្រងគ្រោះមហន្តរាយ
- កិច្ចការនារី និងកុមារ
- ការងារទេសចរណ៍
- ការងារសត្តឃាត
- ការងារសហគមន៍អ្នកក្រីក្រ

**លោក សាំង សុភៈនិមិត្រ**
**អភិបាលរងខណ្ឌ**

- ការិយាល័យអន្តរវិស័យ
- ការងារធម្មការ សាសនា
- កិច្ចការសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិ សម្បទា
- ទីកន្លែង
- កិច្ចការសាធារណៈការ និងដឹកជញ្ជូន
- កិច្ចការធនធានទឹក ឧតុនិយម និងពាក សាស្ត្រ

**លោក សក់ ច័ន្ទកញ្ញារិទ្ធ**
**អភិបាលរងខណ្ឌ**

- ការិយាល័យអន្តរវិស័យ
- កិច្ចការបរិស្ថាន និងគ្រប់គ្រងសំណល់រឹងរាវ
- កិច្ចការរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី
- កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល
- អង្គភាពអគ្គិសនី
- កិច្ចការប្រៃសណីយ៍ និងទូរគមនាគមន៍
- កិច្ចការសម្របសម្រួលទំនាស់ក្រៅប្រព័ន្ធតុលាការ
- ការងារគាំពារទេដ្ឋាហ

## ២. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល



# ឧបសម្ព័ន្ធទី៤

*ការឡើងវិញ*

# ព្រះរាជក្រម

លេខ០៤/នស/៩៤

## យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣
- គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

## ប្រកាសឱ្យប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ដូចមានសេចក្តីតទៅនេះ៖

## ជំពូកទី១ កម្មវត្ថុ

### មាត្រា១

ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់មានកម្មវត្ថុជំរុញឱ្យមានការរៀបចំកែលំអទីក្រុង និងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍសុខដុមនៃប្រទេសក្នុងស្មារតី៖

-គោរពប្រយោជន៍រួម និងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបទបញ្ញាច្បាប់ផង និងត្រួតពិនិត្យការសាងសង់ផង។

-ធានាការអភិវឌ្ឍសំដៅរកលំនឹងរវាងទីក្រុង និងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រ និងលក្ខណៈពិសេសនៃជនបទនីមួយៗ។

-ធានាលើកតម្លៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ និងធានាការអភិវឌ្ឍវិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍ និងរក្សាបាននូវគុណភាពបរិស្ថាន។

មាត្រា២

ច្បាប់រៀបចំទឹកដី នគរូបនីយកម្ម និងសំណង់នេះត្រូវសំអាងទៅលើកម្មសិទ្ធិដែលអនុលោមទៅតាមច្បាប់ភូមិបាលបច្ចុប្បន្ន ក្នុងករណីដែលច្បាប់ភូមិបាលត្រូវកែប្រែ ផ្លាស់ប្តូរ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់នឹងត្រូវកែច្នៃឱ្យស្របទៅតាមច្បាប់ភូមិបាលនេះដែរ។

មាត្រា៣

ដើម្បីសម្រេចនូវបំណងដែលបានចែងខាងលើនេះ ត្រូវបង្កើតឱ្យមានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលមានសមាជិក និងសំណើការតែងតាំង និងរៀបចំដោយអនុក្រឹត្យ។

ចំពោះរាជធានីភ្នំពេញ គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់សម្រាប់ក្រុងភ្នំពេញមួយត្រូវបង្កើត។ គណៈកម្មាធិការនេះដឹកនាំដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ហើយដែលមានប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ ឬអភិបាល អភិបាលរង ព្រមទាំងអង្គភាពបច្ចេកទេសដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផងដែរ។ សមាសភាពឲ្យាស់លាស់ ព្រមទាំងដំណើរការនៃគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់សម្រាប់ក្រុងភ្នំពេញត្រូវកម្រិតដោយអនុក្រឹត្យ។

ចំពោះខេត្ត-ក្រុងនានា ត្រូវបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលដឹកនាំដោយអភិបាលខេត្ត-ក្រុង និងអង្គភាពបច្ចេកទេសខេត្ត-ក្រុងដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផង។ សមាសភាពឲ្យាស់លាស់ ព្រមទាំងដំណើរការនៃអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ក្រោយពីបានការយល់ព្រមរបស់គណៈកម្មាធិការជាតិនេះ។

**ជំពូកទី២ ឯកសារទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់**

មាត្រា៤

ឯកសារទាំងឡាយដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំតាមករណីនីមួយៗ ឱ្យសមស្របទៅតាមស្ថានភាព លក្ខណៈពិសេសនៃទឹកដីខេត្ត-ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ ដល់បរិស្ថានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច។

មាត្រា៥

គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុងនីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍនៃរាជធានី ខេត្ត-ក្រុងរបស់ខ្លួន។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងកំណត់ដោយអនុក្រឹត្យ។

ដើម្បីការពារទ្រព្យបេតិកភណ្ឌ ការពារបរិស្ថាន និងដើម្បីធានាអភិវឌ្ឍសេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានភារៈរៀបចំប្លង់គោលសម្រាប់តំបន់ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត។

## ជំពូកទី៣ ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់

មាត្រា៦

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវរៀបចំឡើងសម្រាប់រាជធានី ខេត្ត-ក្រុង។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន។

មាត្រា៧

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវតែបញ្ជាក់ឱ្យច្បាស់លាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សម្រាប់ការពារជាតិ សម្រាប់កសិកម្ម សម្រាប់ពាណិជ្ជកម្ម សម្រាប់ឧស្សាហកម្ម សម្រាប់សិប្បកម្ម វប្បធម៌ ទេសចរណ៍ សាសនា ព្រមទាំងសម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខារសាធារណៈ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសម្រាប់សាងសង់។

មាត្រា៨

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវគោរពតាមប្លង់គោល ដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ។

មាត្រា៩

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់សម្រាប់រាជធានី និងខេត្ត-ក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុង រួចត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ទៀត។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈទាំងពួងផង។

មាត្រា១០

រាជរដ្ឋាភិបាលរៀបចំបទប្បញ្ញត្តិពិសេស និងសេវាភាពនគរូបនីយកម្មដើម្បីការពារ និងលើកតម្លៃរមណីយដ្ឋាន ឬអចលនវត្ថុណាក៏ដោយដែលនឹងផ្តល់នូវអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព ឬបច្ចេកទេស។ បញ្ជីអចលនវត្ថុ រមណីយដ្ឋានទាំងនោះនឹងកំណត់ដោយអនុក្រឹត្យ។

ការរុះរើការផ្លាស់ប្តូរទម្រង់ និងការគ្រប់គ្រងអចលនវត្ថុ និងរមណីយដ្ឋានទាំងនោះ ត្រូវកំណត់ដោយច្បាប់ស្តីពីការការពារបេតិកភណ្ឌ។

បទប្បញ្ញត្តិពិសេស និងសេវាភាពនគរូបនីយកម្មដើម្បីការពារ និងលើកតម្លៃរមណីយដ្ឋាន ឬអចលនវត្ថុដែលផ្តល់ផលប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព ឬបច្ចេកទេសត្រូវចារិកក្នុងប្លង់គោលរៀបចំទឹកដី នគរូបនីយកម្ម និងអភិវឌ្ឍន៍ និងចារិកក្នុងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់។

រាជរដ្ឋាភិបាលកំណត់ដោយអនុក្រឹត្យនូវបញ្ជីអចលនវត្ថុ ដែលមានប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព និងបច្ចេកទេស ដើម្បីធានាការគ្រប់គ្រងអចលនវត្ថុទាំងនេះ តាមបញ្ញត្តិច្បាប់ស្តីពីការការពារបេតិកភណ្ឌ។

## ជំពូកទី៤ ការងារ និងសំណង់

មាត្រា១១

រាល់ការកកាយ រុករក ឬស្ទង់ដែលមានការប៉ះពាល់ដល់ខាងផ្នែកបុរាណវិទ្យាចាំបាច់ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

រាល់ការសាងសង់ ក្នុងករណីជួបប្រទះនូវវត្ថុអ្វីមួយដែលមានអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ឬប្រវត្តិសាស្ត្រ អ្នកទទួលខុសត្រូវការដ្ឋានត្រូវមានកាតព្វកិច្ចរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចឱ្យបានជ្រាបភ្លាមៗ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ឈប់ ផ្អាកសំណង់ជាបន្ទាន់។

មាត្រា១២

រាល់បុគ្គល ឬស្ថាប័នឯកជនក៏ដូចជាអាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនឱ្យសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈដូចតទៅ៖

-ទីប្រជុំទុកទឹក និងទំនប់ទឹក

-ទីប្រជុំជីករ៉ែ និងតំបន់ព្រៃឈើ

-រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រ

-សួនច្បារ ឧទ្យានសាធារណៈ និងតំបន់អភិវឌ្ឍន៍

ដីក្នុងតំបន់សងខាងផ្លូវ ដីក្នុងតំបន់សងខាងផ្លូវដែក និងដីក្នុងតំបន់សងខាងផ្លូវទឹកធំៗ និងភាគពាយ័ព្យ

-ទន្លេ សមុទ្រ ព្រែក ស្ទឹង ព្រលាយតាំងភ្លៅព្រាំង

-ជាទួលទៅលើដីតាំងឡាយណាដែលមានច្បាប់កំណត់មិនឱ្យសង់។

លក្ខខណ្ឌនៃការគ្រប់គ្រងតំបន់ទាំងនោះ លក្ខខណ្ឌសំណង់ ឬតាំងទីលំនៅជុំវិញព្រំប្រទល់ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា១៣

ការសាងសង់ និងការតាំងទីត្រូវធ្វើឡើងដោយគោរពតាមឯកសារដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ គោរពតាមប្លង់គោលដែលមានចែងក្នុងមាត្រា៤ និង៥នៃច្បាប់នេះ។

មាត្រា១៤

រាល់ការសាងសង់ រាល់ការកែប្រែទិដ្ឋភាព ឬការកែប្រែការប្រើប្រាស់សំណង់ណាមួយ ត្រូវមានការអនុញ្ញាតពីរាជធានីមានសមត្ថកិច្ច។ ពាក្យស្នើសុំអនុញ្ញាតសាងសង់ ត្រូវមានឯកសារ និងប្លង់ចាំបាច់។ នីតិវិធីក្នុងការអនុវត្តមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា១៥

ឯកសារ និងប្លង់ចាំបាច់សម្រាប់ភ្ជាប់ពាក្យសុំអនុញ្ញាតសាងសង់សំណង់ធំៗ ត្រូវរៀបចំឡើងដោយស្ថាបត្យករខ្មែរមានសញ្ញាប័ត្រ ឬជនណាដែលបានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច។ លក្ខខណ្ឌដែលទាមទារអំពីសញ្ញាប័ត្រ និងទាមទារការទទួលស្គាល់ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា១៦

ពាក្យសុំអនុញ្ញាតសាងសង់ត្រូវយកមកដាក់សុំដោយម្ចាស់កម្មសិទ្ធិដី ឬអ្នកបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ។ ពាក្យសុំអនុញ្ញាតនេះត្រូវមានភ្ជាប់មកជាមួយផងនូវឯកសារបញ្ជាក់អំពីកម្មសិទ្ធិរបស់ម្ចាស់ដី។

មាត្រា១៧

មិនអនុញ្ញាតឱ្យសាងសង់នូវសំណង់ណា ក្នុងលក្ខណៈដែលមិនសមស្របនឹងប្លង់គោល ឬប្លង់ប្រើប្រាស់ដីធ្លី និងសំណង់។

មិនអនុញ្ញាតឱ្យសាងសង់ បើគម្រោងសាងសង់នោះមានការប៉ះពាល់ដល់សន្តិសុខសាធារណៈ ប៉ះពាល់ដល់បរិស្ថាន ប៉ះពាល់ដល់អនាម័យសាធារណៈ សំណង់ ឬអចលនវត្ថុដែលមានសារៈប្រយោជន៍

ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាព បច្ចេកទេស ឬប៉ះពាល់ដល់តំបន់ដែលមានធនធានធម្មជាតិ ។

មិនអនុញ្ញាតឱ្យសាងសង់ បើសិនជាពុំមានការរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារសាធារណៈឱ្យបានគ្រប់គ្រាន់ និងគម្រោងសំណង់ដែលស្នើសុំ ។

មាត្រា១៨

ក្នុងករណីពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ អាជ្ញាធរខេត្ត-ក្រុងត្រូវបង្កើតគណៈកម្មាធិការដើម្បីពិនិត្យពាក្យសុំ និងចេញលិខិតអនុញ្ញាតសាងសង់ ។

មាត្រា១៩

ចំពោះគម្រោងសំណង់រដ្ឋបាល អង្គភាពដែលស្នើសុំសាងសង់ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ។ ការអនុញ្ញាតនោះអាចផ្តល់បានតែចំពោះសំណង់ណាដែលមានលក្ខណៈចាំបាច់សម្រាប់ដំណើរការផ្នែករដ្ឋបាល ។ ការអនុញ្ញាតនេះមិនអាចនាំឱ្យមានការផ្លាស់ប្តូរនូវការប្រើប្រាស់ដីធ្លីដែលបានកំណត់មកហើយ ហើយក៏មិនអាចកែប្រែនូវលក្ខណៈសាធារណៈ និងអត្ថប្រយោជន៍ទូទៅនៃតំបន់នេះឡើយ ។

មាត្រា២០

សំណង់ទាំងឡាយណាដែលអ្នកវិនិយោគទុនឯកជន បានសាងសង់នៅលើដីរបស់រដ្ឋស្របតាមកិច្ចសន្យាណាមួយ ត្រូវប្រគល់មកឱ្យរដ្ឋវិញពេលផុតកំណត់ចែងក្នុងកិច្ចសន្យានោះ ។

មាត្រា២១

បើគ្មានមូលហេតុត្រឹមត្រូវដែលបានបញ្ជាក់ក្នុងច្បាប់នេះ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យពាក្យសុំសាងសង់ ឬចេញលិខិតអនុញ្ញាតសាងសង់ ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលមួយយ៉ាងយូរ៤៥ថ្ងៃទេនោះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ក៏ត្រូវផ្តន្ទាទោសផងដែរ ចំពោះភ្នាក់ងារណាដែលបានពិនិត្យគម្រោងសាងសង់ និងចេញលិខិតអនុញ្ញាតសាងសង់ដែលមិនស្របនឹងបទប្បញ្ញត្តិ ។

ភ្នាក់ងារត្រួតពិនិត្យលើសំណង់ដែលពុំបានជំទាស់ ពេលដែលខ្លួនឃើញសំណង់លើការដ្ឋានណាមួយមិនគោរពតាមគម្រោងដែលអនុញ្ញាត ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ទណ្ឌកម្មផ្នែករដ្ឋបាល ដែលត្រូវយកមកអនុវត្តចំពោះភ្នាក់ងារដែលមានកំហុសដូចបានរៀបរាប់ខាងលើនេះ ត្រូវកំណត់ដោយច្បាប់រដ្ឋបាល ។

ចំណែកឯអ្នកសាងសង់ដែលមិនគោរពលិខិតអនុញ្ញាតសាងសង់ទេនោះ នឹងត្រូវទទួលបង្គាប់ឱ្យរុះរើកែសំណង់ឱ្យស្របតាមលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេល៣០ថ្ងៃ យ៉ាងយូរគិតចាប់ពីថ្ងៃទទួលលិខិតបញ្ជាផ្ទេរការ ។

មន្ត្រីរាជការណាដែលរកឃើញពិរុទ្ធនឹងត្រូវដាក់របាយការណ៍ប្រកាន់ចំពោះមុខតុលាការ ។ នៅពេលពិនិត្យឃើញបានសំណង់ខុសច្បាប់ ការដ្ឋានត្រូវបញ្ឈប់ ហើយជាបន្ទាន់ សម្ភារៈ និងឧបករណ៍សំណង់នៅទីនោះត្រូវទទួលរឹបអូសតាមបង្គាប់តុលាការ ។ ក្នុងករណីដែលអ្នកសាងសង់ទទួលរងគ្រោះដោយមិនមែនជាកំហុសរបស់ខ្លួន អ្នករងគ្រោះអាចប្រើសិទ្ធិរបស់ខ្លួនដើម្បីប្តឹងទៅតុលាការទារជំងឺចិត្ត ។

មាត្រា២២

ម្ចាស់សំណង់ មុនពេលវាយកម្ទេចសំណង់របស់ខ្លួនដែលមានស្រាប់ ត្រូវបានលិខិតអនុញ្ញាតរុះរើពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន ។

បែបបទនៃការរុះរើវាយកម្ទេចសំណង់នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាត ឱ្យរុះរើវាយកម្ទេចសំណង់អាចត្រូវបដិសេធបាន ក្នុងលក្ខណៈដែលការរុះរើកម្ទេចសំណង់នោះមានទាក់ទិននឹងបញ្ហាសង្គមកិច្ច បច្ចេកទេស និងបេតិកភណ្ឌដែលរដ្ឋបានកត់ត្រា ។

មាត្រា២៣

បទប្បញ្ញត្តិទាំងឡាយណាដែលមាននៅក្នុងច្បាប់ពីមុនស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខា និង ហត្ថលេខា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានបង្គំទូលថ្វាយ និងជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ វិចិត្រសិល្បៈ រៀបចំដែនដី និងនគរូបនីយកម្ម

ហត្ថលេខា

វណ្ណ ម៉ូលីវណ្ណ

វាយឡើងវិញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ១៦២៣សជណ/កស

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៤

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ជម្រាបមក
ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

កម្មវត្ថុ៖ ករណីសំណើសុំពិនិត្យ និងកែសម្រួលឯកសារពាក់ព័ន្ធដីធ្លី

យោង៖ លិខិតលេខ៣២៩៧កសក/មសរ ចុះថ្ងៃទី៥-៨-៩៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ព្រះរាជចំណារសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ ចុះថ្ងៃទី២៦-៩-១៩៩៤

-ចំណារសម្តេច នាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី២៧-៩-១៩៩៤

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការរដ្ឋមន្ត្រីសូមជម្រាបឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចឯកភាពជាគោលការណ៍ តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការកែសម្រួលឯកសារពាក់ព័ន្ធនឹងដីធ្លីមានដូចខាងក្រោម៖

-ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លី

-សៀវភៅចុះបញ្ជីអចលនវត្ថុ

-កំណត់ហេតុវង្វេតដី

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ

ប៉ុន្តែពង្រីកឱ្យបានធំនូវ Colonne ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ( សូមកុំដាក់ស្រុកកំណើត ) ។

សូមឯកឧត្តមទទួលការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

# ឧបសម្ព័ន្ធទី៥

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខ** : ២៧ អ.ន.ក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលទឹក

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ និងការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៩៩ ។

# **សំរេច**

# **ជំពូកទី ១**

# **បទបញ្ញត្តិទូទៅ**

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឱ្យមានការបំពុលទឹកនៅតាមតំបន់សាធារណៈ ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក-"***តំបន់ទឹកសាធារណៈ***" គឺសំដៅទៅលើតំបន់ទឹកសំរាប់ប្រើប្រាស់ជាសាធារណៈ ដូចជា : ទន្លេ ស្ទឹង ជ្រោះ អូរ ព្រែក បឹង ស្រះ អណ្តូង ត្រពាំង ថ្លុក សមុទ្រ ពាម ដោយរាប់បញ្ចូលទាំងប្រព័ន្ធប្រឡាយធារាសាស្ត្រ និងផ្លូវទឹកដទៃទៀតដែលសំរាប់ប្រើប្រាស់ជាសាធារណៈ និងទឹកក្រោមដី ។

ខ-"***ប្រភពបំពុល***" គឺសំដៅទៅលើទីតាំងអាគារទាំងឡាយណា រួមទាំងលំនៅស្ថាន និងអាគាររដ្ឋបាលសាធារណៈ ទីបរិវេណ មធ្យោបាយដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្ម ដែលបញ្ចេញសំណល់រាវ សារធាតុពុល ឬសារធាតុដែលបង្កអោយមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តី ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ

គ-"***សំណល់រាវ***" គឺសំដៅទៅលើវត្ថុរាវ ដែលបញ្ចេញពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងបណ្តាញលូសាធារណៈ ទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី ។

ឃ-"***ទឹកល្អូ***" គឺសំដៅទៅលើទឹកកខ្វក់ ដែលបញ្ចេញពីលំនៅស្ថាន និងអាគារសាធារណៈ ។

ង-"***សំណល់រឹង***" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល ។

ច-"***សំរាម***" គឺសំដៅទៅលើសារធាតុ ឬរបស់រឹង ដែលលែងប្រើប្រាស់ ហើយត្រូវបានបញ្ចេញចោលពីលំនៅស្ថាន និងអាគារសាធារណៈ ។

ឆ-"***សារធាតុបំពុល***" គឺសំដៅទៅលើសារធាតុរឹង រាវ ឬឧស្ម័ន ឬសំណល់គ្រប់ប្រភេទដែលធ្វើឱ្យមានការប្រែប្រួលនូវធាតុផ្សំ ឬលក្ខណៈរបស់ទឹក ដូចជា ធ្វើឱ្យប្រែប្រួលនូវ លក្ខណៈរូប លក្ខណៈគីមី ឬលក្ខណៈជីវសាស្ត្ររបស់ទឹក នៅពេលបញ្ចេញ ឬចាក់វាចោលចូលទៅក្នុងទឹកដោយចេតនាក្តី ឬអចេតនាក្តី ។

ជ-"**បរិមាណសារធាតុបំពុល**" គឺសំដៅទៅលើបន្ទុក ឬចំណុះសារធាតុបំពុល រួមទាំងកំដៅដែលមាននៅក្នុងសំណល់រាវ ដែលត្រូវបានបញ្ចេញចោលពីប្រភពបំពុល ចូលទៅក្នុងតំបន់ទឹក សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ឈ-"**សារធាតុប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅសារធាតុ ដែលបណ្តាលអោយមានគ្រោះថ្នាក់ទៅដល់សរីរាង្គមានជីវិត ឬធ្វើអោយខូច ឬបាក់បែកវត្ថុសំភារៈ អាគារ ឬបណ្តាលអោយប៉ះពាល់ ឬមហន្តរាយដល់បរិស្ថាន ។ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## បញ្ញត្តិលើការបញ្ចេញសំណល់
## និងសារធាតុប្រកបដោយគ្រោះថ្នាក់

**មាត្រា ៤.-**

ក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

ក្នុងករណីចាំបាច់ និងតំរូវការទៅតាមតំបន់នីមួយៗ ក្នុងការការពារសុខភាពមនុស្ស និងការអភិរក្សជីវចំរុះ ក្រសួងបរិស្ថាន ត្រូវរៀបចំក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក សំរាប់អនុវត្តលើប្រភពបំពុល ដែលតាំងនៅជុំវិញតំបន់ទឹកសាធារណៈនោះ ។

ក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវដោយឡែក ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ មាត្រា ៥ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦.-**

ហាមឃាត់ជាដាច់ខាតនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តតាមក៏រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំក៏រិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុលនៅក្នុងសំណល់រាវ ដែលអាចអនុញ្ញាតឱ្យបញ្ចេញពីប្រភពបំពុលនានា ចូលទៅក្នុងតំបន់ទឹកសាធារណៈដែលត្រូវការពារ ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និង ការអភិរក្សជីវៈចំរុះ ។

ក៏រិតស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៨.-**

ហាមឃាត់ជាដាច់ខាតនូវការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ទៅក្នុងតំបន់ទឹក

សាធារណៈ ឬប្រព័ន្ធលូសាធារណៈ ។

ហាមឃាត់ជាដាច់ខាតនូវការទុកដាក់ ឬការចាក់ចោលសំរាម សំណល់រឹង ឬសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យមានការបំពុលទឹកតំបន់ទឹកសាធារណៈ ។

**មាត្រា ៩.-**

ហាមឃាត់ជាដាច់ខាតនូវការបង្ហូរទឹកលូចេញពីលំនៅស្ថាន ឬពីអាគារសាធារណៈ ចូលទៅក្នុងតំបន់ទឹកសាធារណៈ ដោយពុំឆ្លងកាត់ប្រព័ន្ធលូសាធារណៈ ឬប្រព័ន្ធច្រោះសំអាតនានា ។

## ជំពូកទី ៣

## ការសុំអនុញ្ញាតបញ្ចេញសំណល់រាវ

**មាត្រា ១០.-**

ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវផ្ញើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១១.-**

ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ហើយដែលចែកចេញជាពីរប្រភេទ ដូចតទៅ :

ក-ប្រភពបំពុលប្រភេទថ្នាក់ទី១ តំរូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង ១០ ម៉ែត្រគូបក្នុងមួយថ្ងៃដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សំរាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ ។

ខ-ប្រភពបំពុលប្រភេទថ្នាក់ទី២ ចាំបាច់តំរូវអោយមានការសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ១២.-**

ការសុំអនុញ្ញាតលើការបញ្ចេញចោល ឬការដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃដូចមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុល ទាំងគំរោងថ្មី និងទាំងគំរោងកំពុងដំណើរការ លើកលែងតែគំរោងប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោងនោះត្រូវបានអនុម័ត នឹងត្រូវបានរួចផុតពីការតំរូវឱ្យសុំការអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ ។

**មាត្រា ១៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះដែលមានបំណងធ្វើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកាន់កន្លែងដទៃ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

-អោយបានមុន ៤០ថ្ងៃសំរាប់គំរោងនៅភ្នំពេញ និង ៦០ថ្ងៃ សំរាប់គំរោងនៅតាមខេត្ត ក្រុងនៃការចាប់ផ្តើម

ដំណើរការ សំរាប់ប្រភពបំពុលដែលជាគំរោងថ្មី ។

-អោយបានក្នុងរយៈពេល ៣០ថ្ងៃ សំរាប់ប្រភពបំពុលនៅភ្នំពេញ និង ៩០ថ្ងៃសំរាប់ប្រភពបំពុលនៅតាមខេត្ត ក្រុង ក្រោយពេលទទួលបានការណែនាំពីក្រសួងបរិស្ថាន សំរាប់ប្រភពបំពុលដែលកំពុងដំណើរការ ។

**មាត្រា ១៤.–**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកាន់កន្លែងដទៃ នឹងត្រូវបានផ្តល់ជូន ប្រសិនបើបែបបទនៃការសុំអនុញ្ញាតនោះត្រូវបានបំពេញទៅតាមគោលការណ៍ណែនាំបច្ចេកទេស ដែលកំនត់ដោយក្រសួង បរិស្ថាន ។

**មាត្រា ១៥.–**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដែលទទួលបានការអនុញ្ញាតពីក្រសួងបរិស្ថានអោយបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃ ហើយមានបំណងចង់ធ្វើការផ្លាស់ប្តូរប្រព័ន្ធបញ្ចេញសំណល់រាវរបស់ខ្លួន ត្រូវដាក់ពាក្យ សុំការអនុញ្ញាតជាថ្មី ទៅក្រសួងបរិស្ថានអោយបានមុន ៣០ថ្ងៃ នៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូរ ។

**មាត្រា ១៦.–**

បុគ្គលដែលជួល ឬអ្នកកាន់កាប់បន្តប្រភពបំពុលពីម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើមដែលបានទទួលការ អនុញ្ញាតពីក្រសួងបរិស្ថានឱ្យបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅទីដទៃត្រូវអនុវត្តបន្តអោយបានត្រឹមត្រូវនូវចំនុច ដែលបានកំណត់នៅក្នុងពាក្យសុំការអនុញ្ញាត ដែលម្ចាស់កម្មសិទ្ធិដើម ឬអ្នកទទួលខុសត្រូវដើម បានដាក់ជូនទៅក្រសួង បរិស្ថាន ។

ម្ចាស់កម្មសិទ្ធិថ្មី ឬអ្នកទទួលខុសត្រូវថ្មីនៃប្រភពបំពុល ត្រូវផ្តល់សេចក្តីជូនដំណឹងពីការជួល ឬការកាន់កាប់បន្ត របស់ខ្លួនទៅក្រសួងបរិស្ថាន ក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ក្រោយពីមានការជួល ឬកាន់កាប់បន្តនោះ ។

**មាត្រា ១៧.–**

លិខិតអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃ ដែលបានផ្តល់ជូនទៅឱ្យ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល នឹងត្រូវបានដកហូតជាបណ្តោះអាសន្ន ឬជាស្ថាពរ បន្ទាប់ពីមានការពិគ្រោះ យោបល់ជាមុនជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ប្រសិនបើម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះប្រព្រឹត្ត ល្មើសធ្ងន់ធ្ងរ និងមាត្រាណាមួយនៃមាត្រា ១៤ មាត្រា ១៥ ឬមាត្រា ១៦ នៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤

## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៨.–**

ការត្រួតពិនិត្យនូវរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុល ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន

**មាត្រា ១៩.-**

ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់រាវ នៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២០.-**

ការវិភាគគំរូតាងសំណល់រាវ ដែលយកបានមកពីប្រភពបំពុលក្នុងពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ច ត្រូវធ្វើនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២១.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវបង់ថ្លៃវិភាគសំណល់រាវរបស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំនូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសំណល់រាវរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២៣.-**

ចំពោះប្រភពបំពុល ដូចមានចែងក្នុងមាត្រា ១១ នៃអនុក្រឹត្យនេះ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវ :

ក-ទទួលខុសត្រូវក្នុងការកំណត់យកនូវវិធីសាស្ត្រធ្វើប្រព្រឹត្តកម្មសំអាតនិងបញ្ចេញសំណល់រាវរបស់ខ្លួន ដើម្បីឱ្យឆ្លើយតបទៅ និងកំរិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ និងកំរិតកំណត់ស្តង់ដារបរិមាណសារធាតុបំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

ខ-មានសំភារៈ និងមធ្យោបាយគ្រប់គ្រាន់សំរាប់រារាំង ឬទប់ស្កាត់ការបំពុលតំបន់ទឹកសាធារណៈនៅពេលដែលមានគ្រោះថ្នាក់ដោយចៃដន្យបង្កឡើងពីប្រភពបំពុលរបស់ខ្លួន ។

គ-ទទួលខុសត្រូវក្នុងការដំឡើងឧបករណ៍ សំរាប់ធ្វើការវាស់នូវចរន្តហូរ កំហាប់ និងបរិមាណសារធាតុបំពុលដែលមាននៅក្នុងសំណល់រាវរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ។ លទ្ធផលនៃការវាស់ស្ទង់ ត្រូវផ្ញើជារបាយការណ៍មកកាន់ក្រសួងបរិស្ថានរៀងរាល់ ៣ខែម្តង ។

**មាត្រា ២៤.-**

ក្នុងករណីដែលរកឃើញថា ការបញ្ចេញសំណល់រាវពីប្រភពបំពុលណាមួយ ពុំបានឆ្លើយតបទៅ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ ឬពុំឆ្លើយតបទៅ និងកំរិតស្តង់ដារបរិមាណសារធាតុ

បំពុល ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ក្រសួងបរិស្ថានត្រូវ ៖

ក-ចេញបញ្ជាជាលាយលក្ខណ៍អក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់ណាមួយ ប្រសិនបើសកម្មភាពល្មើសនោះមិនទាន់បង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

ខ-ចេញបញ្ជាជាលាយលក្ខណ៍អក្សរ តម្រូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្ន រហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬប៉ះពាល់ដល់គុណភាពទឹក ។

## ជំពូកទី ៥
## ការត្រួតពិនិត្យការបំពុលទឹក
## នៅតាមតំបន់ទឹកសាធារណៈ

**មាត្រា ២៥.-**

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹកមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៤ នៃអនុក្រឹត្យនេះ ។

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទីសាធារណៈ សំរាប់ការពារសុខភាពសាធារណៈមានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ២៦.-**

ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំពីស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ ។

**មាត្រា ២៧.-**

ក្រសួងបរិស្ថាន ត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពទឹក និងវាយតំលៃពីស្ថានភាពគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៨.-**

ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ពីស្ថានភាពគុណភាពទឹក និងស្ថានភាពនៃការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៩.-**

ក្នុងករណីរកឃើញថា តំបន់ទឹកសាធារណៈត្រូវទទួលរងការបំពុល ដែលបង្កអោយមានការគំរាមកំហែងដល់ជីវិតមនុស្ស ឬជីវៈចំរុះ ក្រសួងបរិស្ថាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់នេះ និងត្រូវចាត់

វិធានការទប់ស្កាត់ការបំពុលទឹក និងស្តារនូវគុណភាពទឹកតំបន់ទឹកសាធារណៈនោះ ។

## ជំពូកទី ៦

## នីតិវិធីនៃការធ្វើអធិការកិច្ច

**មាត្រា ៣០.-**

នៅពេលចុះធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តន៍តាមនីតិវិធីដូចចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកម្មរបស់ខ្លួន នៅពេលចូលក្នុងបរិវេណ ឬទីកន្លែងប្រភពបំពុលដើម្បីអធិការកិច្ច យកគំរូតាង ឬពិនិត្យកត់ត្រា

ខ-កំណត់ហេតុ និងរបាយការណ៍តំបូងនៃការត្រួតពិនិត្យ ឬការយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុ សំរាប់ប្រើប្រាស់ជាវត្ថុតាង

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣១.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបង្ហូរបញ្ចេញនូវសំណល់រាវ ដែលមានផ្ទុកសារធាតុពុល បង្កឱ្យមានគ្រោះថ្នាក់សុខភាពមនុស្សសត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កអោយមានការបំពុលតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិចូលធ្វើអធិការកិច្ច នៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣២.-**

ក្នុងករណីមានឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយ នៃការបំពុលទឹកនៅតំបន់ទឹកសាធារណៈ ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧប្បទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣៣.-**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កឱ្យមានការបំពុលទឹក មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូល ឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនទាន់បង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

ខ-ប្រមូល និងឃាត់ទុកភស្តុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលទឹកធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាពមនុស្សសត្វ ឬរុក្ខជាតិ ឬទ្រព្យសម្បត្តិសាធារណៈ ។

## ជំពូកទី ៧

## ទោសបញ្ញត្តិ

### មាត្រា ៣៤.-

ការរំលោភល្មើសទៅ និងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

### មាត្រា ៣៥.-

កំណត់ហេតុចោទប្រកាន់បទល្មើស ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តន៏តាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ ។

### មាត្រា ៣៦.-

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិត និងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

## **ជំពូកទី ៨**

## **អវសានបញ្ញត្តិ**

**មាត្រា ៣៧.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៩.-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

**កន្លែងទទួល**

-ខុទ្ទកាល័យព្រះមហាក្សត្រ

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៣៨

-កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

## តារាងឧបសម្ព័ន្ធ ១

## ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់

១-សមាសធាតុសរីរាង្គអាឡូសែន និងសារធាតុដែលអាចបង្កើតបានជាសមាសធាតុសរីរាង្គអាឡូសែនទាំងនោះ នៅក្នុងបរិស្ថានទឹក

២-សមាសធាតុសរីរាង្គផូស្វរ

៣-សមាសធាតុសរីរាង្គទីន

៤-សារធាតុដែលបង្កអោយមានជំងឺមហារីក

៥-បារត និងសមាសធាតុរបស់វា

៦-កាត់មួម និងសមាសធាតុរបស់វា

៧-សមាសធាតុប្រេងអសរីរាង្គដែលមិនបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

៨-សមាសធាតុសំយោគដែលមិនបំបែកធាតុ ដែលអាចអណ្តែតនៅលើផ្ទៃទឹក រឺលិចក្នុងទឹកហើយដែលអាចជ្រាបចូលទៅក្នុងការប្រើប្រាស់ទឹក

៩-សារធាតុវិទ្យុសកម្ម

១០-លោហៈ និងសមាធាតុ របស់វាដូចជា :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម(Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរិយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |

១១-សមាសធាតុសរីរាង្គពុលមិនបំបែកធាតុស៊ីលីស្យូម

១២-សមាសធាតុអសរីរាង្គផូស្វរ

១៣-សមាសធាតុប្រេងជាអសរីរាង្គបំបែកធាតុ និងពពួកអ៊ីដ្រូកាបូនៃសមាសធាតុប្រេងឆៅ

១៤-សមាសធាតុស៊ីអានីត និងភ្លុយអរ

១៥-សារធាតុដែលមានឥទ្ធិពលលើអុកស៊ីសែន ដូចជា អាម៉ូញ៉ាក់ នីទ្រីត ។ល។

# តារាងឧបសម្ព័ន្ធ ២

## កំរិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ពីប្រភពបំពុលចូលទៅ ក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុលដែលអាចអនុញ្ញាតឱ្យបញ្ចេញ | |
|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈដែលត្រូវបានការពារ | តំបន់ទឹកសាធារណៈនិងលូ |
| 1 | សីតុណ្ហភាព | $^{0}C$ | <45 | <45 |
| 2 | pH | | 6-9 | 5-9 |
| 3 | $BOD_5$ | mg/l | <30 | <80 |
| 4 | COD | mg/l | <50 | <100 |
| 5 | សារធាតុរឹងអណ្តែតក្នុងទឹក | mg/l | <60 | <120 |
| 6 | សារធាតុរឹងដែលរលាយក្នុងទឹក | mg/l | <1000 | <2000 |
| 7 | ប្រេង ឬខ្លាញ់ | mg/l | <5.0 | <15 |
| 8 | សាប៊ូ | mg/l | <5.0 | <15 |
| 9 | ផេណុល | mg/l | <0.1 | <1.2 |
| 10 | នីត្រាត | mg/l | <10 | <20 |
| 11 | ក្លរក្នុងទំរង់សេរី | mg/l | <1.0 | <2.0 |
| 12 | ក្លរជាអ៊ីយ៉ុង | mg/l | <500 | <700 |
| 13 | ស៊ុលផាត | mg/l | <300 | <500 |
| 14 | ស៊ុលហ្វីត | mg/l | <0.2 | <1.0 |
| 15 | ផូស្វាត | mg/l | <0.3 | <6.0 |
| 16 | ស៊ីអានីត ($CN^{-1}$) | mg/l | <0.2 | <1.5 |
| 17 | បារ្យ៉ូម (Ba) | mg/l | <4.0 | <7.0 |
| 18 | អាសេនិច (As) | mg/l | <0.10 | <1.0 |
| 19 | សំណប៉ាហាំង(Sn) | mg/l | <2.0 | <8.0 |
| 20 | ដែក (Fe) | mg/l | <1.0 | <20 |
| 21 | បរ(B) | mg/l | <1.0 | <5.0 |
| 22 | ម៉ង់កាណែស(Mn) | mg/l | <1.0 | <5.0 |
| 23 | កាត់ម្ញ៉ូម(Cd) | mg/l | <0.1 | <0.5 |

| | | | | |
|---|---|---|---|---|
| 24 | ក្រូម$(Cr)^{+3}$ | mg/l | <0.2 | <1.0 |
| 25 | ក្រូម$(Cr)^{+6}$ | mg/l | <0.05 | <0.5 |
| 26 | ទង់ដែង(Cu) | mg/l | <0.2 | <1.0 |
| 27 | សំណ(Pb) | mg/l | <0.1 | <1.0 |
| 28 | បារត(Hg) | mg/l | <0.002 | <0.05 |
| 29 | នីកែល(Ni) | mg/l | <0.2 | <1.0 |
| 30 | សេលេញ៉ូម(Se) | mg/l | <0.05 | <0.5 |
| 31 | ប្រាក់(Ag) | mg/l | <0.1 | <0.5 |
| 32 | ស័ង្កសី(Zn) | mg/l | <1.0 | <3.0 |
| 33 | ប៉ូលីបដែន(Mo) | mg/l | <0.1 | <1.0 |
| 34 | អាម៉ូញាក់$(NH_3)$ | mg/l | <5.0 | <7.0 |
| 35 | អុកស៊ីសែនដែលរលាយក្នុងទឹក | mg/l | >2.0 | >.1.0 |
| 36 | ប៉ូលីក្លរ៉ូ បីផេនីល(PCB) | mg/l | <0.003 | <0.003 |
| 37 | កាល់ស្យូម(Ca) | mg/l | <150 | <200 |
| 38 | ម៉ាញ៉េស្យូម(Mg) | mg/l | <150 | <200 |
| 39 | កាបូនតេត្រាក្លរ | mg/l | <3 | <3 |
| 40 | អ៊ិចសាក្លរបង់សែន | mg/l | <2 | <2 |
| 41 | ដេដេតេ | mg/l | <1,3 | <1,3 |
| 42 | អង់ឌ្រីន | mg/l | <0,01 | <0,01 |
| 43 | ឌីអលឌ្រីន | mg/l | <0,01 | <0,01 |
| 44 | អេនឌ្រីន | mg/l | <0,01 | <0,01 |
| 45 | អ៊ីសូឌ្រីន | mg/l | <0,01 | <0,01 |
| 46 | ពែក្លរអេទីឡែន | mg/l | <2,5 | <2,5 |
| 47 | អ៊ិចសាក្លរប៊ុយតាឌីអែន | mg/l | <3 | <3 |
| 48 | ក្លរហ្វម | mg/l | <1 | <1 |
| 49 | 1,2 ឌីក្លរអេទីឡែន | mg/l | <2,5 | <2,5 |
| 50 | ទ្រីក្លរអេទីឡែន | mg/l | <1 | <1 |
| 51 | ទ្រីក្លរបង់សែន | mg/l | <2 | <2 |
| 52 | អ៊ិចសាក្លរស៊ីក្លូអ៊ិចសែន | mg/l | <2 | <2 |

**កំណត់សំគាល់** : ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការរៀបចំក៏រិតកំណត់ស្តង់ដារថ្នាំពុលកសិកម្ម ដែលបញ្ចេញពីប្រភពបំពុល ។

## តារាងឧបសម្ព័ន្ធ ៣

ប្រភេទនៃប្រភពបំពុល ដែលតំរូវអោយមានការសុំអនុញ្ញាតិពីក្រសួងបរិស្ថាន

មុននឹងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួន ឬដឹកទៅទីដទៃ

| ល.រ | ប្រភេទប្រភពបំពុល | កំរិតថ្នាក់ប្រភេទ |
|---|---|---|
| 1 | -ទីតាំងផលិតអាហារ និងសាច់កំប៉ុង | ទី១ |
| 2 | -ទីតាំងផលិតបន្លែ និងផ្លែឈើកំប៉ុង | ទី១ |
| 3 | -ទីតាំងកែច្នៃផលនេសាទ | ទី១ |
| 4 | -ទីតាំងក្លាសេ និងបង្កក | ទី១ |
| 5 | -ទីតាំងផលិតម្សៅមី | ទី១ |
| 6 | -ទីតាំងផលិតស្ករស | ទី១ |
| 7 | -ទីតាំងផលិតទឹកស្អាត | ទី១ |
| 8 | -ទីតាំងផលិតស្មូនរបស់ប្រើប្រាស់ពីដី | ទី១ |
| 9 | -ទីតាំងផលិតភេសជ្ជៈ និងស្រាបៀរ | ទី១ |
| 10 | -ទីតាំងផលិតអាល់កុល និងស្រា | ទី១ |
| 11 | -ទីតាំងផលិតចំណីសត្វ | ទី១ |
| 12 | -ទីតាំងផលិតប្រេង និងខ្លាញ់ | ទី១ |
| 13 | -ទីតាំងផលិតដំបែ និងមេស្រា | ទី១ |
| 14 | -ទីតាំងផលិតនំ និងស្ករគ្រាប់ | ទី១ |
| 15 | -ទីតាំងផលិតបារី | ទី១ |
| 16 | -ទីតាំងកាត់ដេរគ្មានក្រឡុកបោក | ទី១ |
| 17 | -សណ្ឋាគារ | ទី១ |
| 18 | -ភោជនីយដ្ឋាន | ទី១ |
| 19 | -ទីតាំងកសិដ្ឋានចិញ្ចឹមសត្វ | ទី១ |
| 20 | -ទីតាំងសត្តឃាត | ទី១ |
| 21 | -ទីតាំងយានដ្ឋាន និងកន្លែងលាងរថយន្ត | ទី១ |
| 22 | -ទីតាំងមជ្ឈមណ្ឌលលក់ដុំ និងទីផ្សារ | ទី១ |
| 23 | -ទីតាំងមន្ទីរពេទ្យ និងសម្ភព | ទី១ |
| 24 | -ទីតាំងផលិតរបស់ផ្លាស្ទិក-កៅស៊ូកង់ | ទី១ |
| 25 | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវលំនៅស្ថាន | ទី១ |
| 26 | -ទីតាំងផលិតជ័រការ | ទី១ |
| 27 | -ទីតាំងបង្កក និងកែច្នៃជ័រក្រែប | ទី១ |

| | | |
|---|---|---|
| 28 | -ទីតាំងផលិតកែវ-ដប | ទី១ |
| 29 | -ទីតាំងផលិតស៊ីម៉ងត៍ | ទី១ |
| 30 | -ការដ្ឋានយកថ្ម | ទី១ |
| 31 | -ការដ្ឋានយកគ្រួស | ទី១ |
| 32 | -ទីតាំងផលិតក្តារបន្ទះ | ទី១ |
| 33 | -ទីតាំងផលិត ឬកែច្នៃជីគីមីកសិកម្ម | ទី១ |
| 34 | -ទីតាំងលាយបេតុង និងផលិតសំភារៈសំណង់ជាបេតុង | ទី១ |
| 35 | -នាំវាំដឹកសារធាតុភាវ | ទី២ |
| 36 | -ទីតាំងផលិតអាសេទីឡែន | ទី២ |
| 37 | -ទីតាំងសំលាប់ស្បែក | ទី២ |
| 38 | -ទីតាំងផលិតសាប៊ូ និងផលិតមេសាប៊ូ | ទី២ |
| 39 | -ទីតាំងស្ថានីយ៍ និងឃ្លាំងស្តុកប្រេងឥន្ធនៈ | ទី២ |
| 40 | -ទីតាំងកប់ ឬចាក់ចោលសំណល់រឹង | ទី២ |
| 41 | -ទីតាំងតំបាញ ឬជ្រលក់ពណ៌ | ទី២ |
| 42 | -ទីតាំងកាត់ដេរមានក្រឡុកបោក | ទី២ |
| 43 | -ទីតាំងផលិតក្រដាស និងម្សៅក្រដាស | ទី២ |
| 44 | -ទីតាំងបោះពុម្ពទស្សនាវដ្តី និងឯកសារផ្សេងៗ | ទី២ |
| 45 | -ទីតាំងលាងសំអាតត្បូងថ្ម និងរ៉ែ | ទី២ |
| 46 | -ទីតាំងផលិតថ្មពិល —អាគុយ | ទី២ |
| 47 | -ទីតាំងផលិតថ្នាំពណ៌អសរីរាង្គ | ទី២ |
| 48 | -ទីតាំងផលិត និងតំឡើងគ្រឿងអេឡិចត្រូនិច | ទី២ |
| 49 | -ទីតាំងផលិតជ័រក្រាលថ្ន | ទី២ |
| 50 | -ទីតាំងផលិតហ្វីលថត និងថ្នាំលាងហ្វីល | ទី២ |
| 51 | -ទីតាំងផលិតសារធាតុគីមីសរីរាង្គ | ទី២ |
| 52 | -ទីតាំងផលិតឱសថ | ទី២ |
| 53 | -ទីតាំងផលិតសារធាតុសរីរាង្គប្រើសំរាប់លាង | ទី២ |
| 54 | -ទីតាំងផលិត និងលាយថ្នាំពុលកសិកម្ម | ទី២ |
| 55 | -ទីតាំងផលិត ចំរាញ់ប្រេងកាត | ទី២ |
| 56 | -ទីតាំងផលិតដែក និងដែកថែប | ទី២ |
| 57 | -ទីតាំងផលិតលោហៈធាតុដែលមិនមែនដែក | ទី២ |
| 58 | -ទីតាំងផលិតរបស់របរលោហៈ | ទី២ |

| | | |
|---|---|---|
| 59 | -ទីតាំងក្លូម៉េរបស់លោហៈធាតុដែលមិនមែនដែក | ទី២ |
| 60 | -ទីតាំងដុតរឺកែច្នៃសំណល់រឹង | ទី២ |
| 61 | -ទីតាំងប្រព្រឹត្តកម្មសំអាតដី | ទី២ |
| 62 | -ទីតាំងកែច្នៃសំណល់ប្រេង | ទី២ |
| 63 | -ទីតាំងប្រព្រឹត្តកម្មសំអាតសំណល់រាវឧស្សាហកម្ម | ទី២ |
| 64 | -មន្ទីរពិសោធន៍ និងមជ្ឈមណ្ឌលស្រាវជ្រាវ | ទី២ |
| 65 | -រោងចក្រអគ្គិសនី | ទី២ |
| 66 | -ទីតាំងកែច្នៃឈើ | ទី២ |
| 67 | -ការដ្ឋានស្រែបង្គា | ទី២ |

# តារាងឧបសម្ព័ន្ធ ៤

កម្រិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ

សំរាប់អភិរក្សជីវៈចំរុះនៅក្នុងទឹក

## ១.សំរាប់ទន្លេ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | $BOD_5$ | mg/l | 1-10 |
| 3 | សារធាតុរឹងអណ្តែតលើទឹក(SS) | mg/l | 25-100 |
| 4 | កម្រិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម(Coliform) | MPN/100ml | <5000 |

## ២.សំរាប់បឹង និងអាងស្តុកទឹក

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 6,5-8,5 |
| 2 | COD | mg/l | 1-8 |
| 3 | សារធាតុរឹងអណ្តែតលើទឹក(SS) | mg/l | 1-15 |
| 4 | កម្រិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 5 | កូលីហ្វម(Coliform) | MPN/100ml | <1000 |
| 6 | អាសូតសរុប(Total Nitrogen) | mg/l | 0,1-0,6 |
| 7 | ផូស្វរសរុប(Total Phosphorus) | mg/l | 0,005-0,05 |

## ៣.សំរាប់ទឹកសមុទ្រ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដារ |
|---|---|---|---|
| 1 | pH | | 7,0-8,3 |
| 2 | COD | mg/l | 2-8 |
| 3 | កម្រិតរលាយអុកស៊ីសែន(DO) | mg/l | 7,5-2,0 |
| 4 | កូលីហ្វម(Coliform) | MPN/100ml | <1000 |
| 5 | សមាសធាតុប្រេង(Oil content) | mg/l | 0 |
| 6 | អាសូតសរុប (Total Nitrogen) | mg/l | 0,2-1,0 |
| 7 | ផូស្វរសរុប (Total Phosphorus) | mg/l | 0,02-0,09 |

# តារាងឧបសម្ព័ន្ធ ៥

កំរិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ

សំរាប់ការពារសុខភាពសាធារណៈ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កំរិតស្តង់ដារ |
|---|---|---|---|
| 1 | កាបូនតេត្រាក្លរួ | µg/l | <12 |
| 2 | អ៊ិចសាក្លរបង់សែន | µg/l | <0,03 |
| 3 | ដេដេតេ | µg/l | <10 |
| 4 | អង់ឌ្រីន | µg/l | <0,01 |
| 5 | ឌីអលឌ្រីន | µg/l | <0,01 |
| 6 | អែនឌ្រីន | µg/l | <0,005 |
| 7 | អ៊ីសូឌ្រីន | µg/l | <0,005 |
| 8 | ពែក្លរួអេទីឡែន | µg/l | <10 |
| 9 | អ៊ិចសាក្លរប៊ុយតាឌីអែន | µg/l | <0,1 |
| 10 | ក្លរហ្វម | µg/l | <12 |
| 11 | 1,2ឌីក្លរអេទីឡែន | µg/l | <10 |
| 12 | ទ្រីក្លរអេទីឡែន | µg/l | <10 |
| 13 | ទ្រីក្លរបង់សែន | µg/l | <0,4 |
| 14 | អ៊ិចសាក្លរស៊ីក្លូអ៊ិចសែន | µg/l | <0,05 |
| 15 | បង់សែន | µg/l | <10 |
| 16 | តេត្រាក្លរអេទីឡែន | µg/l | <10 |
| 17 | កាត់ម្ញូម | µg/l | <1 |
| 18 | បារតសរុប | µg/l | <0,5 |
| 19 | បារតសរីរាង្គ | µg/l | 0 |
| 20 | សំណ | µg/l | <10 |
| 21 | ក្រូមវ៉ាឡង់ ៦ | µg/l | <50 |
| 22 | អាសេទិច | µg/l | <10 |
| 23 | សេលេញ៉ូម | µg/l | <10 |
| 24 | ប៉ូលីក្លរ៉ូ ប៊ីផេនីល(PCB) | µg/l | 0 |
| 25 | ស៊ីអានីត ($CN^{+}$) | µg/l | <0,005 |

# ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ
# ស្តីពី
# ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០០។

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំលេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័តនិងអចល័តទាំងឡាយដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំលេងនៅក្នុងបរិយាកាស ។

**មាត្រា ៣.-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក -"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំលេងគ្រប់ភេទ ។

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំលេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណង់ ឧស្ម័ន ចំហាយទឹកអ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុឆេះ" គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗទៀត ដែលមានប្រតិកម្មចំហេះ

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសាធារបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤.-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងឧបសម្ព័ន្ធ ២ ។

**មាត្រា ៥.-**

កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៦.-**

ក្នុងករណីចាំបាច់ កំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះ នឹងត្រូវពិនិត្យកែសំរួលរៀងរាល់ប្រាំឆ្នាំម្តងតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧.-**

កំរិតកំណត់ស្តង់ដារបញ្ចេញសំលេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតកំណត់ស្តង់ដារសំលេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ៨.-**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៩.-**

ហាមឃាត់ដាច់ខាតនូវការបង្កអោយមានសំលេង ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧ ។

**មាត្រា ១០.-**

ការនាំចូល និងផលិតនូវសារធាតុឆេះ ដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាប៊ួប្រហើរ ត្រូវឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងឧសម្ព័ន្ធ ៨ ។

**មាត្រា ១១.-**

ហាមឃាត់ដាច់ខាតការនាំចូល ប្រើប្រាស់ ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ដែលយានយន្ត និងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំលេងមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និងឧបសម្ព័ន្ធ ៥ ។

**មាត្រា ១២.-**

ហាមដាច់ខាតការបង្ហូរ ឬការធ្វើអោយលេចធ្លាយសារធាតុឆេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី ។

## ជំពូកទី ៣
## ការសុំអនុញ្ញាត

**មាត្រា ១៣.-**

ការបញ្ចេញសារធាតុបំពុល និងសំលេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវផ្ញើសេចក្ដីចំលងនៃពាក្យសុំនោះទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ១៤.-**

ការសុំអនុញ្ញាតនាំចូលសារធាតុឆេះ ត្រូវមានភ្ជាប់នូវលទ្ធផលវិភាគ ដែលបញ្ជាក់ពីបរិមាណជាតិពុលស្ពាន់ធ័រ សំណបង់សែន ឬអ៊ីដ្រូកាបួប្រហើរពីប្រភពដើមនៃការនាំចូល ឬការផលិត ។

**មាត្រា ១៥.-**

ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំលេងដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគំរោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ លើកលែងតែគំរោងដែលមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ ។

**មាត្រា ១៦.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលដូចមានចែងក្នុងមាត្រា ១៣ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន :

- អោយបានមុន ៤០ថ្ងៃ នៃការចាប់ផ្ដើមដំនើរការ សំរាប់គំរោងនៅភ្នំពេញ
- អោយបានមុន ៦០ថ្ងៃ នៃការចាប់ផ្ដើមដំនើរការ សំរាប់គំរោងនៅតាមខេត្ត ក្រុង ។

## ជំពូកទី ៤
## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៧.-**

ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុឆេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពអចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៨.-**

ការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័ន និងសំលេងពីប្រភពចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួងស្ថាប័នពាក់ព័ន្ធ ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង ។

**មាត្រា ១៩.-**

ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្ដីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសំលេង ។

**មាត្រា ២០.-**

ក្រសួងបរិស្ថានត្រូវចុះយកគំរូតាងនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាងដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២១.-**

នៅពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីបរិស្ថានអាចធ្វើការវិភាគគំរូតាងនៅនឹងកន្លែង ឬយកមកធ្វើនៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២២.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលត្រូវបង់ថ្លៃសំរាប់វិភាគតាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំនត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

**មាត្រា ២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសារធាតុបំពុលរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

**មាត្រា ២៤.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវ :

- ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និងឧបករណ៍សំរាប់កាត់បន្ថយសំលេង ដើម្បីឱ្យឆ្លើយតបទៅនឹងកំណត់កំរិតស្តង់ដារ
- ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុលដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវផ្ញើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ខែ ម្តង ។
- ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ ។

**មាត្រា ២៥.-**

ក្នុងករណីដែលរកឃើញថាការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេងពីប្រភពណាមួយពុំបានឆ្លើយតបទៅ និងកំរិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា ៥ មាត្រា ៧ នៃអនុក្រឹត្យនេះក្រសួងបរិស្ថានត្រូវ :

ក-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ

ខ-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្នរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬប៉ះពាល់ដល់គុណភាពបរិស្ថាន ។

## ជំពូកទី ៥

## ការត្រួតពិនិត្យគុណភាពខ្យល់

### មាត្រា ២៦.-

ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យតាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា ។

### មាត្រា ២៧.-

ក្រសួងបរិស្ថានត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពខ្យល់ និងវាយតំលៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈពីស្ថានភាពគុណភាព និងការបំពុលខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២៨.-

ក្នុងករណីរកឃើញថា តំបន់ណាមួយត្រូវទទួលរងការបំពុលខ្យល់ ដែលបង្កអោយមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬគុណភាពបរិស្ថាន ក្រសួងបរិស្ថានត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវស៊ើបអង្កេតរកប្រភពដែលបង្កអោយមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារនូវគុណភាពខ្យល់អោយបានប្រសើរឡើងវិញ ។

## ជំពូកទី ៦

## នីតិវិធីនៃការធ្វើអធិការកិច្ច

### មាត្រា ២៩.-

នៅពេលចុះធ្វើអធិការកិច្ចតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថានត្រូវអនុវត្តតាមនីតិវិធីដូចមានចែងខាង ក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬកន្លែងប្រភពបំពុលដើម្បីធ្វើអធិការកិច្ចយកគំរូតាង ឬពិនិត្យកំណត់ត្រា ។

ខ-កំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ចដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់ពត៌មាន ឬឯកសារនានាដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុសំរាប់ប្រើជាវត្ថុតាង ។

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣០.-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសំលេង ឬរំញ័របង្កអោយមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣១.-**

ក្នុងករណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនៃការបំពុលខ្យល់ ឬការរំខានដោយសំលេង ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនពតិមានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣២.-**

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កអោយមានការបំពុលខ្យល់ ឬការរំខានដោយសំលេង មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបើបទល្មើសនោះមិនបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ទៅដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

ខ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៣.-**

ការរំលោភល្មើសទៅ និងអនុក្រឹត្យនេះនឹងត្រូវទទួលពិន័យ និងផ្តន្ទាទោសដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និងមាត្រា ២៥ ជំពូក ទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៤.-**

កំណត់ហេតុចោទប្រកាន់បទល្មើសចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំង

ឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥.-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## **ជំពូកទី ៨**

## **អវសានប្បញ្ញត្តិ**

**មាត្រា ៣៦.-**

បទញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៨.-**

អនុក្រឹត្យនេះចូលជាធរមានគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ១

## កំរិតកំណត់ស្តង់ដារគុណភាពខ្យល់

| ល.រ | ប៉ារ៉ាម៉ែត្រ | រយៈពេល១ម៉ោង ជាមធ្យម mg/m3 | រយៈពេល៨ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល២៤ម៉ោង ជាមធ្យម $mg/m^3$ | រយៈពេល ១ឆ្នាំ ជាមធ្យម$mg/m^3$ |
|---|---|---|---|---|---|
| 1 | កាបូនឌីអុកស៊ីត CO | 40 | 20 | | |
| 2 | អាសូតឌីអុកស៊ីត$NO_2$ | 0,3 | | 0,10 | |
| 3 | ស្ពាន់ធ័រឌីអុកស៊ីត$SO_2$ | 0,5 | | 0,30 | 0,10 |
| 4 | អូសូន $0_3$ | 0,2 | | | |
| 5 | សំណ Pb | | | 0,005 | |
| 6 | សារធាតុរឹងអណ្តែតក្នុងខ្យល់ TSP | | | 0,33 | 0,10 |

### កំណត់សំគាល់

-កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ធ្វើការវាយតំលៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់ ។

-វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន

-TSP Total Suspended Particulate

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ២

## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់

| ល.រ | ឈ្មោះសារធាតុគីមី | រូបមន្តគីមី | កំរិតអតិបរមា (mg/m$^3$) |
|---|---|---|---|
| 1 | អានីលីន | $C_6H_5NH_2$ | 0,03 |
| 2 | អាម៉ូញាក់ | $NH_3$ | 0,2 |
| 3 | អាស៊ីត អាសេទិច | $CH_3COOH$ | 0,2 |
| 4 | អាស៊ីតស៊ុលផួរិច | $H_2SO_4$ | 0,3 |
| 5 | អាស៊ីតនីទ្រិច | $HNO_3$ | 0,4 |
| 6 | បង់សែន | $C_6H_6$ | 1 |
| 7 | បង់ស៊ីឌីន | $NH_2C_6H_4C_6H_4NH_2$ | គ្មាន |
| 8 | កាបូនឌីស៊ុលហ្វិត | $CS_2$ | 0,02 |
| 9 | ក្លរ៉ូហ្វម | $CHCL_3$ | 0,01 |
| 10 | កាបូនតេត្រាក្លរិត | $CCL_4$ | 3 |
| 11 | ភាគល្អិតដែលមាន asbestor | | គ្មាន |
| 12 | ដេ ដេ តេ | $C_8H_{11}CL$ | 0,5 |
| 13 | ហ្វម៉ល់ដេអ៊ីត | HCOH | 0,012 |
| 14 | អ៊ីដ្រូសែន អាសេនិច | $AsH_3$ | 0,002 |
| 15 | អ៊ីដ្រូសែន ស៊ីអានីត | HCN | 0,01 |
| 16 | អ៊ីដ្រូសែន ភ្លុយអរិច | HF | 0,002 |
| 17 | អ៊ីដ្រូសែនស៊ុលហ្វិត | $H_2S$ | 0,001 |
| 18 | ផេណុល | $C_6H_5OH$ | 0,01 |
| 19 | ស៊ីរេន | $C_6H_5CHCH_2$ | 0,003 |
| 20 | តេត្រាក្លរូអេទីឡែន | $C_2Cl_4$ | 0,1 |
| 21 | សំណតេត្រាអេទិល | $Pb(C_2H_5)_4$ | 0,005 |
| 22 | ទ្រីក្លរូអេទីឡែន | $CLCHCCL_2$ | 0,2 |
| 23 | តូលុយអែន | $C_9H_5CH_3$ | 0,4 |
| 24 | វិនិក្លរួ | $CLCHCH_2$ | 0,05 |

| | | | |
|---|---|---|---|
| 25 | អាសេទិច (សមាសធាតុអសរីរាង្គ) | As | 0,00001 |
| 26 | កាត់ម្ញូម(សមាសធាតុលោហ: និងអុកស៊ីត) | Cd | 0,003 |
| 27 | ក្រូម(លោហ: និងសមាសធាតុ) | Cr | 0,0015 |
| 28 | នីកែល (លោហ: និងសមាសធាតុ) | Ni | 0,0001 |
| 29 | បារត(លោហ: និងសមាសធាតុ) | Hg | 0,0001 |
| 30 | ប្រេងសាំង | | 5 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់ ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៣

## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញ ពីប្រភពអចលនៈ ចូលទៅក្នុងបរិយាកាស

| ល.រ | ប៉ារ៉ាម៉ែត | កំរិតអតិបរមានៃការបញ្ចេញ |
|---|---|---|
| 1 | ភាគល្អិតនៅក្នុងផ្សែង បញ្ចេញពីប្រភព : | |
| | -ឡដុត | 400 mg/$m^3$ |
| | -រោងចក្រផលិតលោហធាតុ | 400 mg/$m^3$ |
| | -រោងចក្រស៊ីម៉ង់ត៍ កំបោរ និងថ្មស្មុយ | 400 mg/$m^3$ |
| | -រោងចក្របេតុងអាស្វាល់ | 500 mg/$m^3$ |
| 2 | ធូលី ដែលមានភ្ជាប់ : | |
| | -សារធាតុ ស៊ីលីកាត $Si0_2$ | 100 mg/$m^3$ |
| | -សារធាតុ Asbetos | 27 µg/$m_3$ |
| | -សារធាតុគីមីអសរីរាង្គ : | |
| 3 | អាលុយមីញ៉ូម AL | (ធូលី) ៣០០ mg/$m^3$ .(Al) 50 mg/$m^3$ |
| 4 | អាម៉ូញាក់ $NH_3$ | 100 mg/$m^3$ |
| 5 | អង់ទីម៉ូន Sb | 25 mg/$m^3$ |
| 6 | អាសេទិច As | 20 mg/$m_3$ |
| 7 | បេរីល្យ៉ូម Be | 10 µg/$m_3$ |
| 8 | ក្លរ CL | 20 mg/$m_3$ |
| 9 | អ៊ីដ្រូសែនក្លរីត HCL | 200 mg/$m_3$ |
| 10 | អ៊ីដ្រូសែនភ្លុយអរីត HF | 10 mg/$m_3$ |
| 11 | អ៊ីដ្រូសែនស៊ុលភីត $H_2F$ | 2 mg/$m_3$ |
| 12 | កាត់ម្ញ៉ូម Cd | 1 mg/$m_3$ |
| 13 | ទង់ដែង Cu | (ធូលី) ៣០០mg/$m_3$ (Cu) 20 mg/$m_3$ |
| 14 | សំណ Pb | (ធូលី) ១០០ mg/$m_3$ (Pb) 30 mg/$m_3$ |
| 15 | ស័ង្កសី Zn | 30 mg/$m_3$ |
| 16 | បារត Hg | 0,1 mg/$m_3$ |
| 17 | កាបូនម៉ូណូអុកស៊ីត Co | 1000 mg/$m_3$ |

| | | |
|---|---|---|
| 18 | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 500 $mg/m^3$ |
| 19 | អាសូតអុកស៊ីត( គ្រប់ប្រភេទ) NOx | 1000 $mg/m^3$ |
| 20 | អាសូតអុកស៊ីត( ចេញពីការផលិតអាស៊ីត)NOx | 2000 $mg/m^3$ |
| 21 | អាស៊ីតស៊ុលផួរិច $H_2SO_4$ | 35 $mg/m^3$ |
| 22 | អាស៊ីតនីទ្រិច $HNO_3$ | 70 $mg/m^3$ |
| 23 | ស្ពាន់ធ័រទ្រីអុកស៊ីត ($SO_3$) | 35 $mg/m^3$ |
| 24 | អាស៊ីតផូស្វរិច ($H_3PO_4$) | 3 $mg/m^3$ |
| | សារធាតុគីមីសរីរាង្គ : | |
| 25 | អាសេទីឡែនតេត្រាប្រូមីត $CHBr_2CHBr_2$ | 14 $mg/m^3$ |
| 26 | អាក្រូឡេអ៊ិន $CH_2CHCHO$ | 1,2 $mg/m^3$ |
| 27 | អានីលីន $C_6H_5NH_2$ | 19 $mg/m^3$ |
| 28 | បង់ស៊ីឌីន $NH_2C_6H_4C_6H_4NH_2$ | None |
| 29 | បង់សែន $C_6H_6$ | 80 $mg/m^3$ |
| 30 | ក្លរបង់ស៊ីល $C_6H_5CH_2Cl$ | 5 $mg/m^3$ |
| 31 | ប៊ុយទីលឡាមីន $CH_3(CH_2)_2CH_2NH_2$ | 15 $mg/m^3$ |
| 32 | ក្រេសូល (O-,m-,P-) $CH_3C_6H_4OH$ | 22 $mg/m^3$ |
| 33 | ក្លរបង់សែន $C_6H_5Cl$ | 350 $mg/m^3$ |
| 34 | ក្លរហ្វម $CHCl_3$ | 240 $mg/m^3$ |
| 35 | ក្លរពិគ្រីន $CCl_3NO_2$ | 0,7 $mg/m^3$ |
| 36 | O-ឌីក្លរបង់សែន $C_6H_4Cl_2$ | 300 $mg/m^3$ |
| 37 | 1.1-ឌីក្លរអេតាន $CHCl_2CH_3$ | 400 $mg/m^3$ |
| 38 | ឌីមេទីលស៊ុលហ្វាត $(CH_3)_2SO_4$ | 0,5 $mg/m^3$ |
| 39 | ឌីមេទីលអ៊ីដ្រាហ្ស៊ីន $(NH_3)_2NNH_2$ | 1 $mg/m^3$ |
| 40 | ឌីនីត្រូបង់សែន (O-,m-,P-) $C_6H_4(NO_2)_2$ | 1 $mg/m^3$ |
| 41 | អេទីឡែនឌីអាមីន $NH_2CH_2\text{-}CH_2NH_2$ | 30 $mg/m^3$ |
| 42 | អេទីឡែន ក្លរអ៊ីឌ្រីន $CH_2ClCH_2OH$ | 16 $mg/m^3$ |
| 43 | អេទីឡែន អុកស៊ីត $CH_2OCH_2$ | 20 $mg/m^3$ |
| 44 | ហ្វ័រម៉ាល់ដេអ៊ីដ HCHO | 6 $mg/m^3$ |
| 45 | មេទីលអាគ្រីឡាត $CH_2CHCOOCH_3$ | 35 $mg/m^3$ |
| 46 | មេតាណុល $CH_3OH$ | 260 $mg/m^3$ |
| 47 | មេទីលប្រូមីត $CH_3Br$ | 80 $mg/m^3$ |

| | | |
|---|---|---|
| 48 | ម៉ូណូមេទីលអានីលីន $C_6H_5NHCH_3$ | 9 mg/m$^3$ |
| 49 | នីត្រូបង់សែន $C_6H_5NO_2$ | 5 mg/m$^3$ |
| 50 | នីត្រូគ្លីសេរីន $C_3H_5(NO_2)_3$ | 5 mg/m$^3$ |
| 51 | នីត្រូតូលូអែន $NO_2C_6H_4CH_3$ | 30 mg/m$^3$ |
| 52 | ផេណុល $C_6H_5OH$ | 19 mg/m$^3$ |
| 53 | ផេនីលអ៊ីដ្រាហ្ស៊ីន $C_6H_5NHNH_2$ | 22 mg/m$^3$ |
| 54 | ពីរីនឌីន $C_5H_5N$ | 30 mg/m$^3$ |
| 55 | ពីរ៉ែន $C_{16}H_{10}$ | 15 mg/m$^3$ |
| 56 | គ្វីណូន $C_6H_4O_2$ | 0,4 mg/m$^3$ |
| 57 | ស្ទីរ៉ែន $C_6H_5CHCH_2$ | 420 mg/m$^3$ |
| 58 | 1,1,2,2-តេត្រាក្លរូអេតាន $Cl_2HCCHCl_2$ | 35 mg/m$^3$ |
| 59 | តេត្រាក្លរូមេតាន $CCl_4$ | 65 mg/m$^3$ |
| 60 | តូលូអែន $C_6H_5CH_3$ | 750 mg/m$^3$ |
| 61 | តេត្រានីត្រូមេតាន $C(NO_2)_4$ | 8 mg/m$^3$ |
| 62 | តូលូអ៊ីឌីន $CH_3C_6H_4NH_2$ | 22 mg/m$^3$ |
| 63 | តូលូអែន 2.4- ឌីអ៊ីសូស៊ីអាណាត $CH_3C_6H_3(NCO)_2$ | 0,7 mg/m$^3$ |
| 64 | ទ្រីក្លរូអេទីឡែន $ClCHCCl_2$ | 110 mg/m$^3$ |
| 65 | ស៊ីលីឌីន $(CH_3)_2C_6H_3NH_2$ | 50 mg/m$^3$ |
| 66 | វីនីលក្លរីត $CH_2CHCl$ | 150 mg/m$^3$ |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៤

## កំរិតកំណត់ស្តង់ដារ នៃការបញ្ចេញឧស្ម័នពីប្រភពអចល័ត

| ល.រ | ប្រភេទយានយន្ត | ប្រភេទប្រេងឥន្ធនៈ | កំរិតនៃការបញ្ចេញ | | | | |
|---|---|---|---|---|---|---|---|
| | | | CO (%) | | HC(ppm) | | ផ្សែងខ្មៅ % |
| | | | ក | ខ | ក | ខ | |
| 1 | ទោចក្រយានយន្តដែលមានចំហេះ២វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 3000 | |
| 2 | ទោចក្រយានយន្តដែលមានចំហេះ៤វគ្គ | ប្រេងសាំង | 4,5 | 4 | 10.000 | 2400 | |
| 3 | យានយន្តគ្រប់ប្រភេទ | ប្រេងសាំង | 4,5 | 4 | 1200 | 800 | |
| 4 | យានយន្តគ្រប់ប្រភេទ | ប្រេងម៉ាស៊ូត | | | | | ៥០ |

### កំណត់សំគាល់

កំរិតកំណត់ស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យការបញ្ចេញឧស្ម័នពីប្រភពអចល័តចូលទៅក្នុងបរិយាកាស ។

ក-គឺសំដៅលើយានយន្តគ្រប់ប្រភេទដែលប្រើប្រាស់ហួសរយៈពេល ៥ឆ្នាំ គិតពីឆ្នាំដែលផលិត ។

ខ-គឺសំដៅទៅលើយានយន្តគ្រប់ប្រភេទដែលបាននាំចូលថ្មីក្នុងរយៈពេល ប្រាំឆ្នាំដំបូងគិតចាប់ពីឆ្នាំដែលផលិត ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៥

# កំរិតកំណត់ស្តង់ដារអតិបរមា ដែលអនុញ្ញាតបញ្ចេញសំលេងនៅលើផ្លូវសាធារណៈ ពីប្រភពយានយន្ត

| ល.រ | **ប្រភេទយានយន្ត** | កំរិតអតិបរមា (dB (A)) |
|---|---|---|
| 1 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)< 125 $Cm^3$ | 85 |
| 2 | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)≥ 125 $Cm^3$ | 90 |
| 3 | **ត្រីចក្រយានយន្ត** | 90 |
| 4 | រថយន្តធុនតូច រថយន្តដឹកអ្នកដំណើរ ១២ នាក់ | 80 |
| 5 | រថយន្តដឹកអ្នកដំណើរ ≥ ១២ នាក់ | 85 |
| 6 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ < 3,5 តោន | 85 |
| 7 | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ > 3,5 តោន | 88 |
| 8 | រថយន្តដឹកទំនិញដែលមានកំលាំង ≥ 150 kw | 89 |
| 9 | គ្រឿងយន្តផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ | 91 |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតបញ្ចេញសំលេងពីប្រភពយានយន្តគ្រប់ប្រភេទ ដែលកំពុងធ្វើចរាចរលើផ្លូវសាធារណៈ ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៦

## កំរិតកំណត់ស្តង់ដារសំលេងអតិបរមា ដែលអនុញ្ញាតនៅតំបន់ សាធារណៈ និងតំបន់លំនៅដ្ឋាន (dB(A))

| ល.រ | ទីតាំង | អំឡុងពេល | | |
|---|---|---|---|---|
| | | ពីម៉ោង ៦ព្រឹកដល់ ម៉ោង ១៨ល្ងាច | ពីម៉ោង ១៨ល្ងាចដល់ ម៉ោង ២២យប់ | ពីម៉ោង២២យប់ ដល់ម៉ោង ៦ព្រឹក |
| 1 | តំបន់ស្ងប់ស្ងៀម<br>-មន្ទីរពេទ្យ<br>-បណ្ណាល័យ<br>សាលារៀន<br>មតេយ្យសាលា | 45 | 40 | 35 |
| 2 | តំបន់លំនៅដ្ឋាន<br>-សណ្ឋាគារ ទីកន្លែង រដ្ឋបាល<br>-ភូមិគ្រឹះ ផ្ទះល្វែង | 60 | 50 | 45 |
| 3 | តំបន់ពាណិជ្ជកម្ម សេវាកម្ម និងចំរុះ | 70 | 65 | 50 |
| 4 | ឧស្សាហកម្មធន់ស្រាល លាយចំរុះ នៅក្នុងតំបន់លំនៅដ្ឋាន | 75 | 70 | 50 |

### កំណត់សំគាល់

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងពីប្រភព ឬសកម្មភាពណាមួយ ដែលបញ្ចេញសំលេងចូលក្នុងតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន ។

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៧

## កំរិតកំណត់ស្តង់ដារសំរាប់ត្រួតពិនិត្យសំលេង

## ក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម

| កំរិតសំលេង (dB(A)) | រយៈពេលអតិបរមា (ម៉ោង) | កំណត់បង្ហាញ |
|---|---|---|
| 75 | 32 | ត្រូវផ្តល់ឧបករណ៍ការពារត្រចៀកដល់អ្នកបំរើការដែលធ្វើការនៅកន្លែងមានសំលេងលើសពី 80dB (A) |
| 80 | 16 | |
| 85 | 8 | |
| 90 | 4 | |
| 95 | 2 | |
| 100 | 1 | |
| 105 | 0,5 | |
| 110 | 0,25 | |
| 115 | 0,125 | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំលេងនៅក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម ។

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក

ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

# តារាងឧបសម្ព័ន្ធ ៧

## កំរិតកំណត់ស្តង់ដារ ជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ូប្រហើរ ដែលអនុញ្ញាតឱ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម

| ល.រ | សារធាតុចំហេះ | ស្ពាន់ធ័រ(S) | សណ(Pb) | បង់សែន | អ៊ីដ្រូកាប៊ូប្រហើរ |
|---|---|---|---|---|---|
| 1 | ប្រេងខ្មៅ | 1,0% | | | |
| 2 | ប្រេងម៉ាស៊ូត | 0,2% | | | |
| 3 | ប្រេងសាំង | | 0,15ក្រាម/លីត្រ | 3,5% | 50% |
| 4 | ធ្យូងថ្ម | 1,5% | | | |

**កំណត់សំគាល់**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ត្រួតពិនិត្យជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ូប្រហើរ ដែលអនុញ្ញាតអោយមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម ។

# ឧបសម្ព័ន្ធទី៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

## សម្រេច
## ជំពូកទី១
## បទបញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលរាជធានី ក្រុងនិងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចមានក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥ .-**

ក្រសួងបរិស្ថាន មានតួនាទីដឹកនាំ និងជំរុញកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយសហការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ
- ផ្តល់ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណៈ ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារ គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការអប់រំក្នុងនិងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៦.-**

ក្រសួងមហាផ្ទៃ មានតួនាទីជំរុញដល់កិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- គាំទ្រនិងសហការជាមួយក្រសួងបរិស្ថាន និងអ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍសមត្ថភាព និងការចែករំលែកបទពិសោធន៍អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល និងកៀរគរការគាំទ្រនានាទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ផ្តល់អន្តរាគមន៍ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៧.-**

រដ្ឋបាលខេត្តត្រូវផ្តល់ការគាំទ្រ និងការសម្របសម្រួល ព្រមទាំងជំរុញកិច្ចប្រតិបត្តិការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់ណែនាំនិងជំរុញការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកា

ប្រចាំឆ្នាំសម្រាប់គ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- ជំរុញ និងគាំទ្រការបង្កើតសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន
- កៀរគរធនធាន មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រដល់រដ្ឋបាលក្រុង ស្រុកលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- គាំទ្រ និងជំរុញការអប់រំ និងការផ្សព្វផ្សាយតាមគ្រប់រូបភាពដល់សាធារណជនអំពីសារប្រយោជន៍នៃការញែកសំរាម សំណល់រឹងទីប្រជុំជន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- សម្របសម្រួលដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំនិងប្រើប្រាស់រួមគ្នានូវសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៨.-**

មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលរាជធានី ខេត្តលើការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមានភារកិច្ចដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋអំពីអនាម័យបរិស្ថានតាមរយៈការអប់រំ និងធ្វើការផ្សព្វផ្សាយអំពីការទុកដាក់ ការសម្អាត ការញែក ការកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការចូលរួមប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមផ្តល់យោបល់បច្ចេកទេសលើសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធនឹងដំណើរការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងសកម្មភាពកែច្នៃសំរាម សំណល់រឹងប្រជុំជន
- ជំរុញការអនុវត្តវិធានការច្បាប់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងចូលរួមការអនុវត្តវិធានការពិន័យអន្តរការណ៍លើបទល្មើសពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន និង
- រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំអំពីស្ថានភាព និងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកមានតួនាទីក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រង និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមរយៈការដាក់ចេញជាដីកា ឬលិខិតបទដ្ឋាននានា
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលបានរៀបចំនៅក្នុងមូលដ្ឋាន និង
- អប់រំនិងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថាន អំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកនីមួយៗអាចស្នើសុំបង្កើតអង្គភាព ឬការិយាល័យជាក់លាក់ចំណុះរដ្ឋបាលរបស់ខ្លួនសម្រាប់ទទួលខុសត្រូវលើកិច្ចការនេះ ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន ដើម្បីធានាដល់ប្រសិទ្ធភាព និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១១.-**

រដ្ឋបាលរាជធានីត្រូវផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលសង្កាត់។

រដ្ឋបាលក្រុង ស្រុកអាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១២.-**

រដ្ឋបាលខណ្ឌត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួល និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងរាជធានី និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តមុខងារដែលបានទទួលក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួម និងសហការអនុវត្តនូវកម្មវិធីនានានៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និង
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូលនិងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៣.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវទទួលខុសត្រូវអនុវត្តនូវមុខងារដែលបានទទួលប្រតិភូកម្ម និងបំពេញតួនាទីជួយគាំទ្រ និងសម្របសម្រួលកិច្ចដំណើរការសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង អនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
- ចូលរួមអប់រំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ច
- ចូលរួមផ្តល់យោបល់លើការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមតាមដានការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសេវាសម្អាតប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមសហការពង្រឹងការអនុវត្តវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដាក់ចេញលិខិតបទដ្ឋានសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

## ជំពូកទី៣
## ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា១៥.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវអនុវត្តការញែក និងការវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៦.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់ មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬមិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៧.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។

**មាត្រា១៨.-**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា១៩.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន ។

ដីកា ឬលិខិតបទដ្ឋានខាងលើនេះ ត្រូវរៀបចំឡើងដោយអនុលោមតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសជាធរមាន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ដូចមានចែងក្នុងកថាខ័ណ្ឌខាងលើឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២០.-**

ត្រូវបានហាមឃាត់ជាដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការទប់ស្កាត់ការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**មាត្រា២១.-**

រូបវន្តបុគ្គល និងនីតិបុគ្គលដែលប្រើប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធីទៅឱ្យអ្នកផ្តល់សេវាប្រមូលក្នុងមូលដ្ឋាន ទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២២.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់ចែងឱ្យមានធុងសំរាមសាធារណៈ និងត្រូវរៀបចំឱ្យមានសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតពីការលក់ដូរនៅតាមដងផ្លូវ និងទីសាធារណៈ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម មណ្ឌលកំសាន្តត្រូវរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណ សម្រាប់ការបោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន។

**មាត្រា២៣.-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

- ទុកដាក់ឱ្យបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន និង
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់សេវា សម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុងមូលដ្ឋាន និងត្រូវបង់ថ្លៃតាមការកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។

**មាត្រា២៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រមូល និងដឹកជញ្ជូន។

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវកំណត់ពេលវេលាដែលអាចអនុញ្ញាតឱ្យបញ្ចេញសំរាម សំណល់រឹងទីប្រជុំជនយកទៅដាក់នៅកន្លែងស្តុកសំរាមបណ្តោះអាសន្ន និងត្រូវចាត់វិធានការរារាំងការយកសំរាម សំណល់រឹងទៅបញ្ចេញនៅកន្លែងស្តុកសំរាមបណ្តោះអាសន្នខុសពេលវេលាដែលបានកំណត់។

**មាត្រា២៥.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងនានា និងបុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្របសម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងបរិវេណគ្រប់គ្រងរបស់ខ្លួនរង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ។

**មាត្រា២៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការបន្ទាន់ចំពោះករណីមានការកកស្ទះសំរាម សំណល់រឹងទីប្រជុំជនដែលបណ្តាលមកពីភាពអសកម្មនៃអ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនដោយប្រើប្រាស់គ្រប់មធ្យោបាយតាមដែលអាចធ្វើបានក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដោះស្រាយភាពកកស្ទះ។

ចំពោះការចំណាយក្នុងប្រតិបត្តិការខាងលើ គឺជាបន្ទុកផ្ទាល់របស់អ្នកផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងទីប្រជុំជននោះ។

**ប្រការ២៧.-**

ការធ្វើអាជីវកម្មបូម ដឹកជញ្ជូន និងការបោះចោលសំណល់ភក់ពីអាងស៊ីបទិក ត្រូវមានការអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌបន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា២៨.-**

ក្រសួងបរិស្ថានត្រូវផ្តល់ការណែនាំអំពីបច្ចេកទេសគ្រប់គ្រងដោយឡែក សម្រាប់ប្រភេទសំណល់គ្រោះថ្នាក់ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

បញ្ជីសំណល់គ្រោះថ្នាក់ដែលបង្កើតតាមលំនៅឋាន ស្ថាប័នឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍មានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

សំណល់រឹងឧស្សាហកម្មនិងសំណល់គ្រោះថ្នាក់ដែលបង្កើតចេញពីសកម្មភាពផលិតកម្មនៃរោងចក្រ អាជីវកម្មរ៉ែ និងពីប្រភពដទៃទៀតក្រៅពីទីតាំង ឬប្រភពដែលមានចែងក្នុងមាត្រា២៨នៃអនុក្រឹត្យនេះ ត្រូវគ្រប់គ្រងដោយក្រសួងបរិស្ថាន ដែលកំណត់ដោយបទបញ្ញត្តិដោយឡែក។

## ជំពូកទី៥
## សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣០.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងសេវាសម្អាត ប្រមូល និងដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសុវត្ថិភាពបរិស្ថាន។

**មាត្រា៣១.-**

ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន រដ្ឋបាលរាជធានី ក្រុង ស្រុកអាចៈ

ក. រៀបចំ និងប្រតិបត្តិការដោយរដ្ឋបាលរបស់ខ្លួនផ្ទាល់នូវមុខងារមួយផ្នែក ឬទាំងស្រុងនៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ខ. ធ្វើកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ដែលមានព្រំប្រទល់រដ្ឋបាលជាប់គ្នា ក្នុងការផ្តល់សេវារួមជាមួយគ្នា។

គ. ផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូន ឬ/និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនទៅឱ្យផ្នែកឯកជន ជាអ្នកទទួលបន្ទុកអនុវត្ត។

ឃ. ផ្ទេរមុខងារមួយផ្នែកឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ឬផ្តល់សិទ្ធិទៅឱ្យសហគមន៍អនុវត្តនូវមុខងារណាមួយ ឬមួយចំនួននៃមុខងារគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

**មាត្រា៣២.-**

ការផ្តល់សិទ្ធិធ្វើសេវាសម្អាត ឬ/និងប្រមូល ឬ/និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនត្រូវមានរយៈពេលមិនលើសពី១០ឆ្នាំក្នុងកិច្ចសន្យាមួយលើក និងត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មជាធរមាន។

**មាត្រា៣៣.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយផ្អែកលើកម្រៃសេវាអតិបរមា ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនសម្រាប់អនុវត្តនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាប្រសិទ្ធភាព និងគុណភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- កំណត់កម្រៃសេវាផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង កម្រិតប្រាក់ចំណូល បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលត្រូវបញ្ចេញ និង
- ត្រូវមានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា៣៤.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវកំណត់អំពីវិធានការ និងនីតិវិធីសមស្រប មានតម្លាភាព និងមានប្រសិទ្ធភាពសម្រាប់ការប្រមូល ការគ្រប់គ្រង និងការទូទាត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋបាលខណ្ឌ ឃុំ សង្កាត់ ស្ថាប័ន និងអ្នកពាក់ព័ន្ធ។

ចំណូលដែលប្រមូលបានពីសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាចំណូលផ្ទាល់របស់

រដ្ឋបាលរាជធានី ក្រុង ស្រុកសាមី។

រដ្ឋបាលរាជធានី ក្រុង ស្រុកអាចប្រើប្រាស់ថវិការបស់ខ្លួន ឬថវិកាពីប្រភពផ្សេងទៀត សម្រាប់គាំទ្របន្ថែមលើការចំណាយសម្រាប់ការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥.-**

ក្នុងករណីមានសំណើពីសហគមន៍ អង្គការ ឬប្រជាពលរដ្ឋសុំការអនុញ្ញាតប្រមូលយកសំរាម សំណល់រឹងទីប្រជុំជនមកប្រើប្រាស់ក្នុងប្រយោជន៍ណាមួយ រដ្ឋបាលរាជធានី ក្រុង ស្រុក ដោយមានការពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានរាជធានី ខេត្តអាច ៖

ក. ពិនិត្យផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនសម្រាប់យកទៅធ្វើការកែច្នៃធ្វើជីកំប៉ុស្តិ៍ ផលិតឧស្ម័ន ប្រសិនបើសកម្មភាពប្រមូលយកសំរាមសំណល់រឹងនោះ មិនធ្វើឱ្យប៉ះពាល់ដល់ផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅនៃមជ្ឈដ្ឋានជុំវិញ និងបរិស្ថាន។

ខ. ផ្តល់ការអនុញ្ញាតឱ្យធ្វើការប្រមូល និងដឹកជញ្ជូនសំរាម សំណល់កម្ទេចកម្ទី និងដីចេញពីសកម្មភាពការដ្ឋានផ្លូវថ្នល់ សំណង់អគារ ឬលំនៅឋាន ដែលមិនមានលាយឡំសំរាម សំណល់រឹងទីប្រជុំជន និងមិនមានផ្ទុកឬលាយឡំជាមួយសំណល់គ្រោះថ្នាក់ ដើម្បីយកទៅចាក់បំពេញរណ្តៅដីកម្មសិទ្ធិសហគមន៍ អង្គការ ឬជីឯកជន។

## ជំពូកទី៦
## វិធានការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

**មាត្រា៣៦.-**

រដ្ឋបាលរាជធានី ក្រុង ស្រុកត្រូវធ្វើការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យស្របតាមទីតាំងស្ថានភាពភូមិសាស្ត្រជាក់ស្តែងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុក ការកំណត់ជ្រើសរើសទីកន្លែងសម្រាប់គម្រោងរៀបចំទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន ត្រូវមានការឯកភាពពីរដ្ឋបាលខេត្ត។

រាល់គម្រោងស្នើសុំបង្កើតទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវស្នើសុំការពិនិត្យ សម្រេចពីក្រសួងបរិស្ថានលើបច្ចេកទេសរៀបចំទីលាន វិធានការការពារបរិស្ថានក្នុងពេលដំណើរការ និងពេលបិទបញ្ចប់ការប្រើប្រាស់ទីលាន និងរយៈពេលនៃការប្រើប្រាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**មាត្រា៣៧.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវដំណើរការទីលានរបស់ខ្លួនតាមលក្ខខណ្ឌបច្ចេកទេស និងវិធានការការពារបរិស្ថាន តាមការកំណត់របស់ក្រសួងបរិស្ថាន។

ក្នុងករណីកើតមានហេតុការណ៍បំពុលបរិស្ថានបង្កដោយដំណើរការនៃទីលាន ម្ចាស់ ឬអ្នកគ្រប់

គ្រងទីលានត្រូវចាត់វិធានទប់ស្កាត់ជាបន្ទាន់ និងត្រូវផ្តល់ព័ត៌មានជាបន្ទាន់ទៅរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ និងមន្ទីរបរិស្ថានរាជធានី ខេត្ត។

**មាត្រា៣៨.-**

ក្រសួងបរិស្ថាន និងរដ្ឋបាលរាជធានី ខេត្តត្រូវចុះធ្វើការតាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្តរបស់ម្ចាស់ទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នូវវិធានការទប់ស្កាត់និងកាត់បន្ថយផលប៉ះពាល់បរិស្ថានពីដំណើរការគ្រប់គ្រងទីលាន។

## ជំពូកទី៧
## ទោសបញ្ញត្តិ

**មាត្រា៣៩.-**

ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌក្នុងការញែក និងការវេចខ្ចប់ដោយឡែកនូវសំរាម សំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់ឡើងវិញឬកែច្នៃបាន ដូចមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ១០.០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤០.-**

បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈខុសពេលម៉ោងអនុញ្ញាតឱ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤១.-**

បុគ្គលដែលបានប្រើប្រាស់សេវាគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន ឬសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលរៀបចំ ឬកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា១៨ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤២.-**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាតយកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៣.-**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលរាជធានីឬខណ្ឌ ក្រុង ស្រុកហាមឃាត់ ដូចមានចែងក្នុងមាត្រា២០នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសំអាត

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៤.-**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសំអាត ប្រមូលនិងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងពិធីបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ
- ចំនួន ២.០០០.០០០ (ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៥.-**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងវាក្យខណ្ឌ២ មាត្រា២២នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤០០.០០០(បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**មាត្រា៤៦.-**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្ម ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និង ត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤៧.-**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កក់ពីប្រព័ន្ធលូ ឬពីអាងស៊ិបទិក ដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងមាត្រា២៧នៃអនុក្រឹត្យនេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤៨.-**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន លាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ លើកមុន។

**មាត្រា៤៩.-**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវរៀបចំសំណុំឯកសារប្ដឹងទៅសាលាដំបូងរាជធានី ខេត្ត។

**មាត្រា៥០.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចផាកពិន័យអន្តរការណ៍របស់មន្ត្រីមានសមត្ថកិច្ចរបស់រាជធានី ក្រុង ស្រុក ខណ្ឌ មានសិទ្ធិប្តឹងតវ៉ាទៅអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌសាមី។

អភិបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រាជធានី ក្រុង ស្រុក ខណ្ឌមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**មាត្រា៥១.-**

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវទទួលខុសត្រូវក្នុងការរៀបចំយន្តការសម្រាប់អនុវត្តវិធានការពិន័យអន្តរការណ៍ឱ្យមានប្រសិទ្ធភាព។

នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍នេះនឹងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។

## ជំពូកទី៨
## អន្តរបញ្ញត្តិ

**មាត្រា៥២.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវពិនិត្យការអនុវត្តកិច្ចសន្យាកន្លងមក និងធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីពិនិត្យ និងកែសម្រួលនូវកិច្ចសន្យាផ្តល់សេវាសំរាម សំណល់រឹងដែលកំពុងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេល១២(ដប់ពីរ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា ៥៣.-**

ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌ។

## ជំពូកទី៩
## អវសានបញ្ញត្តិ

**មាត្រា៥៤.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្ដេចក្រឡាហោម ស ខេង**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សាយ សំអាល់**

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

## ឧបសម្ព័ន្ធទី១
## សន្ទានុក្រម

១- **សំរាម** សំដៅដល់របស់របរប្រើប្រាស់ សម្ភារ ផលិតផលដែលបានបន្សល់ ឬបង្កើតពីសកម្មភាព និងជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ ដែលមិនមានផ្ទុកសារជាតុពុល ឬសំណល់គ្រោះថ្នាក់។

២- **សំណល់រឹងទីប្រជុំជន** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព អាជីវកម្ម ឬសេវាកម្មដែលមិនមានផ្ទុកសារជាតុពុល ឬសំណល់គ្រោះថ្នាក់។

៣- **សំណល់រឹងឧស្សាហកម្ម** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាព ផលិតកម្មនៃរោងចក្រ ឬសហគ្រាសដែលមិនមានផ្ទុកសារជាតុពុល ឬសំណល់គ្រោះថ្នាក់។

៤- **សំណល់គ្រោះថ្នាក់** សំដៅដល់វត្ថុធាតុរឹង រាវ ឧស្ម័ន សារធាតុវិទ្យុសកម្ម សារធាតុផ្ទុះ សារធាតុឆេះ សារធាតុចំលងជំងឺ ឬធ្វើឱ្យរលាក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម បង្កការពុល បង្កឱ្យមានជំងឺមហារីក ឬសារធាតុគីមីពុលដទៃទៀត ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬ ការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ ប្រភពសំណល់គ្រោះថ្នាក់អាចមានប្រភពមកពីលំនៅដ្ឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម សិប្បកម្ម រោងចក្រ សកម្មភាពកសិកម្ម និងអាជីវកម្មរ៉ែ។

៥- **ការទាញយកធនធាន** សំដៅដល់សកម្មភាពជម្រើស ឬប្រើប្រាស់សំរាម សំណល់រឹងធ្វើជាជីកំប៉ុស្ត៍ កែច្នៃ ទាញយកថាមពល ឬសារប្រយោជន៍នានា។

៦- **ការកែច្នៃ** សំដៅដល់សកម្មភាព ឬដំណើរការបំបែក ឬបំលែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

៧- **ការប្រើប្រាស់ឡើងវិញ** សំដៅដល់ការជម្រើសសំរាម សំណល់រឹងដែលអាចប្រើប្រាស់សារជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬការជួសជុលដោយនៅរក្សាទ្រង់ទ្រាយដើម។

៨- **ការញែក** សំដៅដល់ការបែងចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងនៅនឹងប្រភពបង្កើត សម្រាប់គោលបំណងការទាញយកធនធាន ឬដើម្បីសុវត្ថិភាពក្នុងការយកទៅចាក់នៅទីលាន។

៩- **ទីលាន** សំដៅដល់ទីកន្លែងដែលអាជ្ញាធរបានកំណត់ ឬរៀបចំតាមវិធានសុវត្ថិភាពបរិស្ថាន សម្រាប់ការចាក់សំរាម សំណល់រឹងទីប្រជុំជន។

១០- **ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់សកម្មភាព ឬវិធានការនៅក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលរួមមាន៖

ក). ការបន្ថយទំហំ ឬបរិមាណសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន ដូចជា ការដោះបំបែក ការកិនកម្ទេច ការរំលាយ ឬការដុតនៅក្នុងឡ។

ខ). ការដកយក ឬកម្ទេចចោលជាតិពុល សារធាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជម្ងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន។

**១១- ទីប្រជុំជន** សំដៅដល់ទីរួមក្រុង ទីរួមស្រុក ទីប្រជុំជនផ្សារ និងលំនៅដ្ឋាន រួមទាំងរមណីយដ្ឋាន មណ្ឌលកំសាន្ត តំបន់ទេសចរណ៍។

**១២- ទីតាំង** សំដៅដល់កន្លែងផលិតកម្ម អាជីវកម្ម សេវាកម្ម អគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម។

**១៣- អាងស៊ិបទិក** សំដៅដល់អាងស្តុកសំណល់បង្គន់អនាម័យបឋម។

**១៤- ពិន័យអន្តរការណ៍** សំដៅដល់ការតម្រូវជនប្រព្រឹត្តល្មើសទៅនឹងបញ្ញត្តិ ដែលមានចែងក្នុងអនុក្រឹត្យនេះ បង់ប្រាក់ពិន័យតាមកម្រិតទណ្ឌកម្មដែលបានប្រព្រឹត្តល្មើស។

**១៥- សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** សំដៅដល់សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

# ឧបសម្ព័ន្ធទី២

## សំណល់គ្រោះថ្នាក់ ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍

សំណល់គ្រោះថ្នាក់ដែលបង្កើតឡើងនៅតាមលំនៅឋាន ស្ថាប័ន ឬអាគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍រួមមាន៖

១- សំណល់អាគុយ និងថ្មពិល ឬថ្មសាកគ្រប់ប្រភេទ។

២- សំណល់គ្រឿងបរិក្ខារអគ្គីសនី និងអេឡិចត្រូនិក។

៣- សំណល់សំបកដប ឬកំប៉ុងដែលមានប្រឡាក់សារធាតុគីមី ឬថ្នាំពុលកសិកម្ម។

៤- សំណល់សំបកកង់យានយន្តគ្រប់ប្រភេទ។

៥- សំណល់ប្រេងម៉ាស៊ីន។

៦- សំណល់ថ្នាំលាបថ្នាំជ្រលក់ពណ៌ និងសម្ភារវេចខ្ចប់។

៧- សំណល់ទឹកខ្មៅបោះពុម្ព។

៨- សំណល់ដែលជាសមាសធាតុអាបេស្តូស។